ក្រសួងអប់រំ យុវជន និងកីឡា



# ការអនុវត្តការគ្រប់គ្រងតាមសាលារៀន

## ផែនការបង្រៀនជាជំនួយ
## សម្រាប់អ្នកសម្របសម្រួលក្នុងសិក្ខាសាលា


## សង្ខេប

ឯកសារនេះគឺជាសេចក្តីណែនាំទូទៅ សម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀន ដែលអាចត្រូវបានប្រើទៅតាមបរិបទទូទៅ។ ឯកសារនេះផ្តល់ជាផែនការបង្រៀនដល់អ្នកសម្របសម្រួលសម្រាប់ការបណ្តុះបណ្តាលពីគោលការណ៍គ្រប់គ្រងតាមសាលារៀន ដល់អ្នកពាក់ព័ន្ធទាំងឡាយនៅតាមសាលារៀន ហើយឯកសារនេះក៏ផ្តល់នូវឯកសារមេរៀនដល់សិក្ខាកាមចូលរួម ទុកជាឯកសារយោង នៅពេលពួកគេវិលត្រឡប់ទៅកាន់គេហដ្ឋានរបស់ពួកគេវិញផងដែរ។



## រៀបចំដោយ

ការិយាល័យកណ្តាលសាលារៀនជំនាន់ថ្មី



រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ខែមេសា ឆ្នាំ ២០២១

# ឯកសារសម្រាប់

# សិក្ខាកាម

## ឯកសារទី១៖ ស្វ័យវាយតម្លៃពីការគ្រប់គ្រងតាមសាលារៀន

**សេចក្ដីណែនាំ៖** សូមអានល្បះនីមួយៗខាងក្រោមហើយផ្ដល់និយមជាឧទាហរណ៍ផ្ទាល់ខ្លួនលើពាក្យ ការគ្រប់គ្រងតាមសាលារៀន តាមអ្វីដែលបានយល់។ សូមគូស (✓) ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ប្រសិនបើអ្នកគិតថាវាមិនត្រឹមត្រូវ។ ល្បះខាងក្រោមនេះមានបួនត្រឹមត្រូវនិងបួនមិនត្រឹមត្រូវ។

| | | |
|---|---|---|
| ១ | ☐ពិត ☐ មិនពិត | SBM លើកកម្ពស់គណនេយ្យភាពដោយរួមបបញ្ចូលវិធីសាស្ត្រជាក់ លាក់ដើម្បីវាយតម្លៃលទ្ធផលសាលារៀន។ |
| ២ | ☐ពិត ☐ មិនពិត | SBM គឺជាយុទ្ធសាស្ត្រគ្រប់គ្រងដែលអាចឱ្យសាលារៀនអនុវត្តតាមយ៉ាងតឹងរ៉ឹងទៅនឹងច្បាប់ និងគោលនយោបាយកំណត់ដោយថ្នាក់កណ្ដាល។ |
| ៣ | ☐ពិត ☐មិនពិត | SBM គឺជាយុទ្ធសាស្ត្រគ្រប់គ្រងដែលការសម្រេចធ្វើឡើងនៅកម្រិតសាលារៀន និងនៅតាមមូលដ្ឋានដូចជាក្រុមប្រឹក្សាឃុំ/សង្កាត់។ |
| ៤ | ☐ពិត ☐ មិនពិត | SBM គឺជាយុទ្ធសាស្ត្រគ្រប់គ្រងដើម្បីកែលម្អអប់រំដោយការផ្ទេរការសម្រេចចិត្តសំខាន់ៗពីថ្នាក់កណ្ដាលមកថ្នាក់សាលារៀននីមួយៗ |
| ៥ | ☐ពិត ☐ មិនពិត | វាជាការលំបាកក្នុងការអនុវត្ត SBM នៅក្នុងប្រព័ន្ធអប់រំបែបមជ្ឈការ។ |
| ៦ | ☐ពិត ☐ មិនពិត | SBMគឺជាយុទ្ធសាស្ត្រគ្រប់គ្រងដែលអំណាចសម្រាប់គ្រប់ទិដ្ឋភាពប្រតិបត្តិ របស់សាលារៀនរៀនគឺផ្ទេរពីគណៈគ្រប់គ្រងសាលារៀនទៅសមាជិកសហគមន៍។ |
| ៧ | ☐ពិត ☐ មិនពិត | SBMលើកកម្ពស់ស្វ័យភាព គណនេយ្យភាព និងកម្មសិទ្ធិភាពរបស់សាលារៀន។ |
| ៨ | ☐ពិត ☐ មិនពិត | សូចនាករលទ្ធផលរបស់សាលារៀនសម្រាប់ការអនុវត្ត SBM ត្រូវកំណត់នៅថ្នាក់កណ្ដាល។ |

### តើអ្នកធ្វើបានល្អកម្រិតណាដែរ?

នៅក្នុងការវាយតម្លៃលើកទី១ ខ្ញុំធ្វើបាន ___ ក្នុងចម្លើយត្រឹមត្រូវ៨។ នៅក្នុងការវាយតម្លៃលើកទី២ ខ្ញុំធ្វើបាន ___ ក្នុងចម្លើយត្រឹមត្រូវ ៨។

ឯកសារទី២: **និយមន័យសកលនៃការគ្រប់គ្រងតាមសាលារៀន និងបញ្ញត្តិដែលពាក់ព័ន្ធ។**

## លំហាត់តាមក្រុម

សូមអាននិយមន័យនៃការគ្រប់គ្រងតាមសាលារៀនខាងក្រោម ហើយឆ្លើយសំណួរតាមក្រុមតូចនីមួយៗ។

**និយមន័យសកលនៃការគ្រប់គ្រងតាមសាលារៀន**

*ការគ្រប់គ្រងតាមសាលារៀន* ***ផ្ទេរវិមជ្ឈការការគ្រប់គ្រង*** *ពីការិយាល័យកណ្តាលថ្នាក់ស្រុក មកសាលារៀននីមួយៗដើម្បីដាមធ្យោបាយមួយផ្តល់អំណាចដល់សាលារៀន - គណៈនាយក/នាយិកា គ្រូបង្រៀន មាតាបិតាសិស្ស សមាជិកសហគមន៍ ហើយនៅសាលារៀនខ្លះទៀត សិស្សធ្វើការគ្រប់គ្រងទៅលើអ្វីៗដែលកើតឡើងក្នុងសាលារៀន។ នេះជាការលើកកម្ពស់****ស្វ័យភាព****។ នៅពេលសាលារៀនមានស្វ័យភាពច្រើន វានឹងផ្តល់នូវ****សិទ្ធិអំណាច****ដល់អ្នកពាក់ព័ន្ធ និងផ្តល់****កម្មសិទ្ធិភាព****ច្រើនលើសាលារៀន។ អ្នកគាំទ្រSBM អះអាងថាការបង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធនៅកម្រិតសាលារៀនទៅលើការគ្រប់គ្រងសាលារៀននឹងបង្កើនសមត្ថភាពរបស់សាលាដើម្បីធ្វើការកែលម្អ។ នេះកើតឡើងពីព្រោះកម្មសិទ្ធិភាពបង្កើននូវ****គណនេយ្យភាព****ក្នុងចំណោមអ្នកពាក់ព័ន្ធដើម្បីសម្រេចស្ល****ង់ដាលទ្ធផលការងារ****ដែលពួកគេបានកំណត់។ អ្នកគាំទ្រមតិខាងSBM អះអាងថា តាមរយៈSBM គេប្រមូលយកការយល់ឃើញផ្សេងៗបានទូលំទូលាយ មកធ្វើការសម្រេចចិត្ត ដូច្នេះការសម្រេចចិត្តមានភាពល្អប្រសើរ ឆ្លើយតបនឹងតម្រូវការសហគមន៍មូលដ្ឋានរបស់សាលារៀន។*

## សំណួរពិភាក្សា

១. ផ្អែកលើនិយមន័យខាងលើ តើបញ្ញត្តិសំខាន់ៗណាខ្លះជួយជំរុញការគ្រប់គ្រង តាមសាលារៀន?

២. ហេតុអ្វីបានអ្នកបង្កើតទ្រឹស្តី SBM ជឿជាក់ថាអ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន មានតួនាទីល្អប្រសើរក្នុងការធ្វើការសម្រេចចិត្តនៅសាលារៀនរបស់ពួកគេជាង អ្នកធ្វើផែនការ

នៅថ្នាក់កណ្ដាល?
៣. តើការពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធឱ្យមាន "កម្មសិទ្ធិភាព" ជួយលើកកម្ពស់គណនេយ្យភាពលើលទ្ធផលការងារបានយ៉ាងដូចម្ដេច?
៤. តើអ្នកគិតថា សាលារៀនអាចមានស្វ័យភាពបានតាមមធ្យោបាយអ្វីខ្លះ?

៥. នៅពេលគិតពីស្វ័យភាព ការផ្ដល់សិទ្ធិអំណាច និងកម្មសិទ្ធិភាព តើអ្នកគិតថា មួយណា កើតមុនគេ? បន្ទាប់? ហើយនឹងចុងក្រោយ? សូមពន្យល់ចម្លើយរបស់អ្នក។

## ឯកសារទី៣ក៖ ការបង្កើតដ្យាក្រាមពីទំនាក់ទំនងរវាងបញ្ញត្តិ

### តើអ្វីទៅជា តារាងលំហូរព័ត៌មាន(Flowchart)?

គំនូសតាងលំហូរព័ត៌មានគឺជាដ្យាក្រាមដែលពណ៌នាអំពីដំណើរការឬប្រព័ន្ធនិងរបៀបដែលសមាសធាតុផ្សេងគ្នានៃដំណើរការ/ប្រព័ន្ធនោះទាក់ទងគ្នា។ គំនូសតាងលំហូរព័ត៌មានបង្ហាញពីហេតុនិងផលហើយត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងវិស័យជាច្រើន (ឧទាហរណ៍ វិទ្យាសាស្ត្រ អប់រំ ប្រវត្តិសាស្ត្រ។ល។ ដើម្បីចងក្រង សិក្សា ធ្វើផែនការអភិវឌ្ឍន៍ និងបង្ហាញនូវដំណើរការបែបស្មុគស្មាញក្នុងដ្យាក្រាមឱ្យកាន់តែច្បាស់ និងងាយយល់។

ឧទាហរណ៍នៃតារាងលំហូរព័ត៌មានប្រើប្រាស់ដើម្បីពន្យល់មូលហេតុដែលសិស្សបោះបង់ការសិក្សានៅកម្ពុជា៖




### សំណួរពិភាក្សា

១. តើអ្វីទៅជាលទ្ធផលចុងក្រោយនៅក្នុងដ្យាក្រាម?

២. តើមានមូលហេតុផ្ទាល់ប៉ុន្មានដែលនាំឱ្យមានការបោះបង់ការសិក្សា?

៣. តើមានមូលហេតុប្រយោលប៉ុន្មានដែលនាំឱ្យមានការបោះបង់ការសិក្សា?

៤. តើពាក្យអ្វីដែលតំណាងដោយសញ្ញាព្រួញនៅក្នុងតារាង ?
៥. តើអ្នកយល់អំពីបញ្ញត្តិនៃតម្លៃឱកាសដែរឬទេ ?
៦. តើមានកត្តាប៉ុន្មានដែលបង្កើតផលប៉ះពាល់ដល់តម្លៃឱកាស ?
៧. តើអ្នកយល់ថាទំនាក់ទំនងរវាងកត្តាទាំងនេះ និងតម្លៃឱកាស សមហេតុផលចំពោះអ្នកដែរឬទេ ? ហេតុអ្វីសមហេតុផល ឬហេតុអ្វីមិនសមហេតុផល ?

## លំហាត់តាមក្រុម

ផ្អែកលើការយល់របស់អ្នកលើនិយមន័យនៃការគ្រប់គ្រងតាមសាលារៀន និងបញ្ញត្តិសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងវិធីសាស្ត្រគ្រប់គ្រងនេះ **សូមបង្កើតតារាងលំហូរព័ត៌មានដែលបង្ហាញពីទំនាក់ទំនងបញ្ញត្តិ SBM នៅក្នុងបញ្ជីខាងក្រោមដើម្បីឈានទៅរកការកែលម្អប្រសិទ្ធភាពសាលារៀនដែលជាលទ្ធផលចុងក្រោយ។** ចំណងជើងតារាងលំហូរព័ត៌មានត្រូវបានបង្ហាញខាងក្រោម។

ពេលធ្វើលំហាត់នេះ សូមសរសេរបញ្ញត្តិនីមួយៗដែលរាយខាងក្រោមនៅលើក្រដាសដាច់ដោយឡែកពីគ្នា បន្ទាប់មកព្យាយាមភ្ជាប់បញ្ញត្តិទាំងនេះឱ្យសមហេតុផល ដោយបង្ហាញពីរបៀបដែលបញ្ញត្តិទាំងនេះពាក់ព័ន្ធគ្នា។ សូមប្រើ "សញ្ញាព្រួញ" ដូចបង្ហាញក្នុងឧទាហរណ៍ពីមុន អំពីបញ្ហាសិស្សបោះបង់ការសិក្សាដើម្បីភ្ជាប់ទៅនឹងបញ្ញត្តិនីមួយៗ។ សូមចងចាំថាបញ្ញត្តិមួយអាចភ្ជាប់ជាមួយបញ្ញត្តិច្រើន ឬច្រើនជាងមួយនៅពេលតែមួយ។ លទ្ធផលចុងក្រោយគឺ "ប្រសិទ្ធភាពសាលារៀនរៀនមានភាពរីកចម្រើន" ដែលបង្ហាញនៅក្នុងប្រអប់ពណ៌លឿង។

របៀបដែលការគ្រប់គ្រងតាមសាលារៀនជួយកែលម្អប្រសិទ្ធភាពសាលារៀន...

| | | |
|---|---|---|
| ការធ្វើវិមជ្ឈការសិទ្ធិអំណាច | អ្នកពាក់ព័ន្ធកំណត់ស្តង់ដាលទ្ធផលការងារដោយខ្លួនឯង | អ្នកពាក់ព័ន្ធមានកម្មសិទ្ធិភាពលើសាលារៀនកាន់តែច្រើន |
| នវានុវត្តន៍អប់រំកើនឡើង | អ្នកពាក់ព័ន្ធទទួលបានសិទ្ធិអំណាចដើម្បីធ្វើការសម្រេចចិត្តស្របតាមការយល់ដឹងរបស់ពួកគេលើបរិបទ | ការសម្រេចចិត្តកាន់តែល្អប្រសើរ |

| | | |
|---|---|---|
| ស្វ័យភាព សាលារៀន កើនឡើង | ប្រសិទ្ធភាពសាលារៀនមានភាពរីកចម្រើន | ពង្រឹងគណនេយ្យភាព សាលារៀន |

នៅពេលអ្នកបញ្ចប់តារាងលំហូរព័ត៌មាន សូមត្រៀមធ្វើបទបង្ហាញវាទៅកាន់ក្រុមផ្សេងទៀត ដោយពន្យល់ពីទំនាក់ទំនងរវាងបញ្ញត្តិនីមួយៗខាងលើ។ អ្នកចូលរួមក៏ត្រូវត្រៀមការពារគំនិតលើតារាងលំហូរព័ត៌មានរបស់ខ្លួន ប្រសិនបើវាខុសប្លែកពីអ្វីដែលក្រុមផ្សេងទៀតបានបង្កើត។

**ឯកសារទី៣ខ៖ តារាងលំហូរព័ត៌មានពិពណ៌នាពីទំនាក់ទំនងរវាងបញ្ញត្តិ SBM និងប្រសិទ្ធភាពសាលារៀន។**

របៀបដែលការគ្រប់គ្រងតាមសាលារៀនជួយកែលម្អប្រសិទ្ធភាពសាលារៀន....




សូមប្រៀបធៀបតារាងនេះជាមួយតារាងលំហូរព័ត៌មានដែលក្រុមអ្នកបានបង្កើត។ តើវាដូចគ្នាយ៉ាងដូចម្តេចដែរ? តើវាខុសគ្នាយ៉ាងដូចម្តេចដែរ? តើភាពខុសគ្នានេះបង្ហាញការយល់ដឹងខុសគ្នារវាងទំនាក់ទំនងបញ្ញត្តិយ៉ាងដូចម្តេច? តើអ្នកគិតថាតារាងរបស់អ្នកសមហេតុផលតិច ឬច្រើនជាងតារាងដែលបង្ហាញខាងលើ? ហេតុអ្វីសមហេតុផល ឬហេតុអ្វីមិនសមហេតុផល?

## ឯកសារទី៤៖ ហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងតាមសាលារៀន និងប្រតិមតិរបស់SBM?

### តើការគ្រប់គ្រងតាមសាលារៀនមានហានិភ័យអ្វីខ្លះ?

នៅក្នុងយុទ្ធសាស្ត្រអប់រំទាំងអស់តែងតែមានគុណសម្បត្តិ និងគុណវិបត្តិ។ យើងបានពិភាក្សារួចមកហើយពីគុណសម្បត្តិនៃ SBM។ ប៉ុន្តែមានហានិភ័យអ្វីខ្លះចំពោះការប្រើប្រាស់យុទ្ធសាស្ត្រការគ្រប់គ្រងតាមសាលារៀននេះ? ខាងក្រោមនេះគឺជាហានិភ័យមួយចំនួន៖

១. **ហានិភ័យនៃភាពអាណាធិបតេយ្យកើនឡើង៖** នៅពេលណាដែលថ្នាក់កណ្តាលលះបង់អំណាចនិងការគ្រប់គ្រង តែងតែមានហានិភ័យនៅថ្នាក់មូលដ្ឋានដែលមានលក្ខណៈអាក្រក់ជាងមុន។ នាយកសាលារៀនខ្លះប្រហែលជាមិនមានជំនាញភាពជាអ្នកដឹកនាំដើម្បីប្រើប្រាស់សេរីភាពថ្មីដោយប្រសិទ្ធភាពនោះទេ។ ពួកគេប្រហែលជាមិនដឹងពីរបៀបធ្វើប្រតិភូកម្មប្រកបដោយប្រសិទ្ធភាពឬអាចបង្កើតការមូលមតិគ្នាក្នុងចំណោមភាគីពាក់ព័ន្ធជាច្រើនដែលឥឡូវនេះមានតួនាទីធំក្នុងការសម្រេចចិត្ត។ បញ្ហាទាំងនេះត្រូវបានគេរំពឹងទុកនៅពេលដែលមនុស្សធ្លាប់ធ្វើការតាមទម្លាប់នៅក្នុងប្រព័ន្ធ "មជ្ឈការ" ឥឡូវនេះត្រូវផ្លាស់ប្តូរឥរិយាបថរបស់ពួកគេទៅធ្វើការនៅក្នុងប្រព័ន្ធ "វិមជ្ឈការ" ។ ការផ្លាស់ប្តូរឥរិយាបថបែបនេះច្រើនតែមិនងាយស្រួលសម្រាប់អ្នកពាក់ព័ន្ធសម្របតាមបានឆាប់រហ័សនោះទេ។ ដូចគ្នានេះដែរភាគីពាក់ព័ន្ធអាចរំលោភបំពានលើសេរីភាពថ្មី ដែលបានផ្តល់ឱ្យដោយការបន្ធូរបន្ថយការរឹតត្បិតដោយធ្វើតិច ជាងធ្វើច្រើន។

២. **ការសម្រេចចិត្តត្រូវការពេលវេលាច្រើន៖** នៅពេលណាដែលអ្នកណាម្នាក់អនុញ្ញាតឱ្យភាគីពាក់ព័ន្ធចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត វានឹងត្រូវការពេលវេលាច្រើនដើម្បីបង្កើតការមូលមតិគ្នាដែលជាផ្នែកមួយនៃដំណើរការសម្រេចចិត្ត។ នេះអាចធ្វើឱ្យយឺតយ៉ាវដល់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។ (គ្នាច្រើនអន្សមខ្លោច)

៣. **ភាពច្របូកច្របល់ពីតួនាទី និងការទទួលខុសត្រូវថ្មី៖** ដោយមានសិទ្ធិ និងអំណាចកាន់តែច្រើនហូរចូលទៅក្នុងដៃអ្នកពាក់ព័ន្ធថ្នាក់ក្រោម អ្នកពាក់ព័ន្ធមួយចំនួននឹងមានទំនួលខុសត្រូវខ្ពស់ក្នុងការបំពេញមុខងារថ្មីៗនោះទេ (ឧទាហរណ៍ ការជ្រើសរើសកម្មវិធីសិក្សា ការបង្កើតតេស្តការរៀបចំការអភិវឌ្ឍបុគ្គលិក។ល។)។ អ្នកពាក់ព័ន្ធជាច្រើននៅកម្រិតសាលារៀនប្រហែលជាមិនទាន់ត្រៀមខ្លួនសម្រាប់ការទទួលខុសត្រូវថ្មីនេះទេ ហើយប្រហែលជាមិនអាចបំពេញតាមការរំពឹងទុករបស់អ្នករៀបចំផែនការថ្នាក់កណ្តាលដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពដែរ។ នេះនឹងធ្វើឱ្យអន្តរាយ ជាជាងពង្រឹងសាលារៀន។

៤. **បង្កើនតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍបុគ្គលិក៖** ការបង្កើនការទទួលខុសត្រូវដែលធ្លាក់មកពីថ្នាក់លើមកអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានវានឹងបង្កើនតម្រូវការសម្រាប់ការគាំទ្រការអភិវឌ្ឍបុគ្គលិកដើម្បីឱ្យអ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋានអាចបំពេញភារកិច្ចថ្មីបាន។ នេះជាការពិតមួយ ជាពិសេសចំពោះគ្រូបង្រៀន និងអ្នកគ្រប់គ្រងដែលមានសមត្ថភាពនិងជំនាញដឹកនាំទាប។

## លំហាត់តាមក្រុម

ដោយពិចារណាលើហានិភ័យដែលបានពិពណ៌នាខាងលើ តើអ្នកគិតថាវិធានការអ្វីខ្លះដែលអាចប្រើដើម្បីកាត់បន្ថយបញ្ហានីមួយៗ? ធ្វើបញ្ជីខ្លីជាមួយសមាជិកក្រុមរបស់អ្នកហើយត្រៀមខ្លួនដើម្បីបង្ហាញដល់ក្រុមធំ។ ប្រើតារាងខាងក្រោមដើម្បីបង្ហាញដំណោះស្រាយរបស់អ្នក៖

| វិធានការដើម្បីកាត់បន្ថយហានិភ័យនៃការអនុវត្ត SBM | | | |
|---|---|---|---|
| ហានិភ័យទី១ | ហានិភ័យទី២ | ហានិភ័យទី៣ | ហានិភ័យទី៤ |
| •<br>•<br>• | •<br>•<br>• | •<br>•<br>• | •<br>•<br>• |

### តើអ្វីជាប្រតិមតិ? (ជម្រើស)

- ១. គោលការណ៍ដែលផ្ទុយនឹងមតិ។
- ២. សេចក្តីថ្លែងមួយដែលហាក់ដូចជាផ្ទុយគ្នាឬប្រឆាំងនឹងសុភនិច្ឆ័យ ក៏ប៉ុន្តែវាអាចជាការពិតដែរ។
- ៣. សេចក្តីថ្លែងដែលផ្ទុយពីខ្លួនឯងដែលដំបូងហាក់ដូចជាការពិត។

### ឧទាហរណ៍ខ្លះនៃប្រតិមតិ៖

**សេចក្តីថ្លែងនេះគឺជាការកុហក**

សេចក្តីថ្លែងនេះគឺជាប្រតិមតិដែលសមហេតុផល និងល្បីល្បាញបំផុត ព្រោះវាជាល្បះដ៏សាមញ្ញមួយ។ ពាក្យសាមញ្ញទាំង ៥ នេះគឺមានន័យផ្ទុយពីខ្លួនឯង៖ ប្រសិនបើសេចក្តីថ្លែងនេះជាការពិត នោះវាជាការកុហក ដែលមានន័យថាវាមិនពិត។ ប៉ុន្តែប្រសិនបើវាមិនពិត នោះវាជាការកុហកដែលមានន័យថាវាពិត។

***តើព្រះដ៏មានមហិទ្ធិឫទ្ធិអាចបង្កើតដុំថ្មធំមួយ ដែលទ្រង់មិនអាចលើកវាបានឬទេ?***

ព្រះត្រូវបានគេគិតថាមានអំណាចគ្រប់យ៉ាង។ គ្មានអ្វីដែលទ្រង់មិនអាចធ្វើបាននោះឡើយ។ ប៉ុន្តែប្រសិនបើទ្រង់បង្កើតដុំថ្មធំមួយដែលទ្រង់មិនអាចលើកបាននោះ មានន័យថាទ្រង់មិនមានអំណាចឡើយ។ ប៉ុន្តែប្រសិនបើទ្រង់មិនអាចបង្កើតដុំថ្មបែបនេះបាន នោះទ្រង់ក៏មិនមានអំណាចគ្រប់យ៉ាងបានដែរ ព្រោះនៅតែមានអ្វីដែលទ្រង់មិនអាចធ្វើបាន។ ដូច្នេះនេះគឺជាសេចក្តីថ្លែងមួយដែលជាប្រតិមតិ។



*គំនូរជណ្ដើរមាត្រដែលមានលក្ខណៈប្រតិមតិ*

រូបគំនូរខាងលើវាប្រឆាំងនឹងក្បួនធម្មតានៃការបកស្រាយទូទៅ។ ផ្ទៃលើ អាចជាបាតឬអាចជាផ្ទៃលើ វាអាស្រ័យលើទស្សនៈរបស់មនុស្សម្នាក់ៗ។

## សារៈសំខាន់នៃប្រតិមតិគ្នា

ប្រតិមតិគ្នាបែបតក្កត្រូវបានប្រើប្រាស់អស់ជាច្រើនសតវត្សមកហើយ ដើម្បីបង្ហាញពីភាពស្រពិចស្រពិលនៃតក្កវិជ្ជាមនុស្ស។ ថ្វីបើតក្កវិជ្ជាគឺជាឧបករណ៍ដ៏មានតម្លៃក៏ដោយពេលខ្លះវាអាចផ្តល់នូវមហន្តរាយទៅវិញ ដូចឧទាហរណ៍នៃ "សេចក្តីថ្លែងនេះគឺជាការកុហក" ។ ទស្សនវិទូ និងអ្នកមានជំនឿលើអធិធម្មជាតិ ជារឿយៗប្រើប្រតិមតិដើម្បីបញ្ជាក់ភស្តុតាង ថាមនុស្សជាតិស្វែងយល់ពិភពរបស់ពួកគេ តាមអព្ភន្តរញ្ញាណ និងតក្កវិជ្ជា។

## ប្រតិមតិនៃការគ្រប់គ្រងតាមសាលារៀននៅក្នុងប្រព័ន្ធអប់រំបែបមជ្ឈការ

ការគ្រប់គ្រងតាមសាលារៀនគឺជាវិធីវិមជ្ឈការលើការគ្រប់គ្រងសាលារៀន ដែលជារឿយៗត្រូវបានកំណត់ដោយអ្នករៀបចំផែនការពីថ្នាក់កណ្តាល ជាពិសេសនៅក្នុងប្រទេសដែលមានប្រព័ន្ធអប់រំបែបមជ្ឈការ។ នេះបង្ហាញថា វាជាបញ្ហាប្រឈមមួយសម្រាប់ប្រព័ន្ធបែបនេះ ដោយសារផ្នែកជាច្រើននៃប្រតិបត្តិការនៅក្នុងប្រព័ន្ធអប់រំនៅតែមានលក្ខណៈមជ្ឈការ (ឧទាហរណ៍ ការជួលបុគ្គលិក កម្មវិធីសិក្សា កាលវិភាគសាលារៀន ការធ្វើតេស្ត ការអភិវឌ្ឍវិជ្ជាជីវៈ ។ល។) ។ល។ ដូច្នេះ ការអនុវត្ត SBM នៅក្នុងប្រព័ន្ធអប់រំមជ្ឈការបង្កើតឱ្យមានប្រតិមតិគ្នា។ តើធ្វើដូចម្តេចដើម្បីលើកកម្ពស់ឥរិយាបថវិមជ្ឈការនៅក្នុងប្រព័ន្ធមួយដែលភាគច្រើនផ្តោតលើការធ្វើសេចក្តីសម្រេចបែបមជ្ឈការ?

## លំហាត់តាមក្រុម

ផ្អែកលើការសង្កេតខាងលើ សូមធ្វើការជាក្រុមតូចៗ ដើម្បីឆ្លើយសំណួរខាងក្រោម។ ហើយត្រៀមខ្លួនបង្ហាញចម្លើយរបស់អ្នក។

១. តើអ្នកគិតថាប្រតិមតិគ្នា SBM មានកម្រិតណានៅក្នុងប្រទេសកម្ពុជាណ? ពន្យល់ពីចម្លើយរបស់អ្នក (ឧ. តើមានទិដ្ឋភាពនៃការគ្រប់គ្រងបែបមជ្ឈការអ្វីខ្លះ នៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា ដែលមិនស្របតាមគោលការណ៍ SBM?)។

២. តើអ្នកគិតថាអាចអនុវត្ត SBM នៅសាលារៀនរបស់អ្នកក្នុងបរិយាកាសប្រតិបត្តិការបច្ចុប្បន្ននេះបានយ៉ាងដូចម្តេច? តើអ្វីដែលអាចដំណើរការបានល្អក្រោមគោលការណ៍ SBM ហើយអ្វីដែលមិនអាចដំណើរការល្អ? សូមលើកឧទាហរណ៍ជាក់លាក់មួយចំនួន។

## ឯកសារទី៥ក៖ ស្វ័យភាពសាលារៀន និងផ្នែកសំខាន់នៃប្រតិបត្តិការសាលារៀនដែលប៉ះពាល់ដោយការគ្រប់គ្រងតាមសាលារៀន។

### ការឱ្យនិយមន័យកម្រិតស្វ័យភាពរបស់សាលារៀន

នៅពេលនិយាយអំពីការគ្រប់គ្រងតាមសាលារៀនយើងតែងតែនិយាយអំពី "ស្វ័យភាពសាលារៀន" ដែលជាគុណសម្បត្តិដ៏សំខាន់។ អ្នកស្រាវជ្រាវយល់ស្របថាប្រសិទ្ធភាពរបស់សាលារៀនជារឿយៗត្រូវបានផ្សារភ្ជាប់ជាវិជ្ជមានជាមួយនឹងការបង្កើនស្វ័យភាពរបស់សាលារៀន ឬកម្រិតនៃសេរីភាពដែលសាលារៀនត្រូវធ្វើការសម្រេចចិត្តដោយខ្លួនឯង។ ការសម្រេចចិត្តទាំងនេះតែងតែកើតឡើងនៅក្នុងផ្នែកជាក់លាក់នៃប្រតិបត្តិការរបស់សាលារៀនរួមមាន៖

| ផ្នែកនៃប្រតិបត្តិការសាលារៀន |
|---|
| ១. ការគ្រប់គ្រងបុគ្គលិក |
| ២. ការគ្រប់គ្រងការបង្រៀន |
| ៣. ការគ្រប់គ្រងថវិកា |
| ៤. ការថែទាំ & ហេដ្ឋារចនាសម្ព័ន្ធ |
| ៥. រដ្ឋបាលសាលារៀន ការពិនិត្យតាមដាន & ការទំនាក់ទំនងសហគមន៍ |

Source: Di Gropello, E. (2006) *A comparative analysis of school-based management in Central America,* (Working Paper #72), Washington DC: World Bank.

### ស្វ័យភាពសាលារៀនផ្អែកតាមការយល់ឃើញរបស់អ្នកពាក់ព័ន្ធផ្សេងៗ . . . .

ស្វ័យភាពសាលារៀនសំដៅលើកម្រិតនៃសេរីភាពដែលសាលារៀនដើម្បីធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងផ្នែកជាក់លាក់មួយចំនួននៃប្រិតិបត្តិការសាលារៀន។ ប៉ុន្តែសេរីភាពនេះអាចមានន័យផ្សេងៗគ្នាទៅតាមអ្នកពាក់ព័ន្ធ។

**សម្រាប់ឪពុកម្ដាយសិស្ស** ស្វ័យភាពសាលារៀនទំនងមានន័យថា សាលារៀនត្រូវមានគណនេយ្យដល់ឪពុកម្ដាយសិស្សទាំងឡាយ ក្នុងការចូលរួមបញ្ចេញមតិលើរបៀបប្រើប្រាស់ធនធាន និងធ្វើឱ្យឪពុកម្ដាយសិស្សចូលរួមកាន់តែច្រើនក្នុងសកម្មភាពសាលារៀន។

**សម្រាប់គ្រូបង្រៀន** ស្វ័យភាពទំនងជាមានន័យថា សាលារៀនត្រូវផ្ដល់សិទ្ធិអំណាចកាន់តែច្រើនដល់ពួកគាត់ក្នុងការធ្វើការសម្រេចចិត្តអំពីការសិក្សារបស់សិស្ស។

**សម្រាប់អ្នកគ្រប់គ្រងសាលារៀន** ស្វ័យភាពទំនងជាមានន័យថា ពួកគាត់គួរមានសិទ្ធិអំណាចកាន់តែច្រើនក្នុងការធ្វើការសម្រេចចិត្តលើការរៀបចំសាលារៀន និងការប្រើប្រាស់ធនធានដោយមិនចាំបាច់សុំការអនុញ្ញាតពីថ្នាក់លើ។

## ស្វ័យភាពរបស់សាលារៀន និងបរិយាកាសអំណោយផលសម្រាប់ការអនុវត្ត SBM

នៅពេលដែលសាលារៀនមានស្វ័យភាពកាន់តែច្រើន វាកាន់តែមានភាពងាយស្រួលក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន។ នោះគឺ SBM ទាមទាឱ្យសាលារៀនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងនៅក្នុងផ្នែកផ្សេងៗជាច្រើន។ នៅពេលយើងនិយាយពី ស្វ័យភាពសាលារៀន ឬសេរីភាពមួយចំនួន ក្នុងការធ្វើការសម្រេចចិត្ត យើងសំដៅលើអ្វីដែលហៅថា "បរិយាកាសអំណោយផល"។ នៅក្នុងករណីនេះ បរិយាកាសអំណោយផលសំដៅលើកម្រិតសេរីភាពប្រតិបត្តិការរបស់សាលារៀនដែលគាំទ្រសមត្ថភាពរបស់សាលារៀនដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀនពេញលេញ។

## លំហាត់តាមក្រុម

ផ្នែកនីមួយៗនៃប្រតិបត្តិការសាលារៀនដែលបានពិភាក្សាខាងលើ ត្រូវបានកំណត់ដោយសកម្មភាពសំខាន់ៗមួយចំនួនដែលត្រូវបានរាយតាមលំដាប់ចៃដន្យនៅក្នុងប្រអប់ខាងក្រោម។ សរុបទៅមានសកម្មភាពផ្តាច់មុខចំនួន២៥ដែលត្រូវបានកំណត់អត្តសញ្ញាណ។ នៅក្នុងក្រុមរបស់អ្នកសូមគូរផ្នែកនៃតារាងប្រតិបត្តិការរបស់សាលារៀនខាងក្រោមនៅលើសន្លឹកក្រដាសផ្ទាំងធំមួយហើយចាត់ថ្នាក់សកម្មភាពនីមួយៗនៅក្រោមផ្នែកសមស្របនៃប្រតិបត្តិការសាលារៀន។

| **ផ្នែកនៃប្រតិបត្តិការសាលារៀន** | **សកម្មភាពសំខាន់ៗ** |
|---|---|
| ១. ការគ្រប់គ្រងបុគ្គលិក | •<br>• |
| ២. ការគ្រប់គ្រងការបង្រៀន | •<br>• |
| ៣. ការគ្រប់គ្រងថវិកា | •<br>• |
| ៤. ការថែទាំ & ហេដ្ឋារចនាសម្ព័ន្ធ | •<br>• |
| ៥. រដ្ឋបាលសាលារៀន ការពិនិត្យតាមដាន & ការទំនាក់ទំនងសហគមន៍ | •<br>• |

| | |
|---|---|
| ១. ការត្រួតពិនិត្យអ្នកទទួលខុសត្រូវផ្នែកថែតាំ<br>២. ការកំណត់វិធីបង្រៀន<br>៣. ការតាមដានវត្តមាន និងកំណត់ត្រាការសិក្សារបស់សិស្ស<br>៤. ការបង្កើតគ្រឿងលើកទឹកចិត្តសម្រាប់បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន<br>៥. ការរៀបចំការអភិវឌ្ឍវិជ្ជាជីវៈ<br>៦. ការកំណត់ម៉ោងសិក្សាតាមមុខវិជ្ជា<br>៧. ការកំណត់ថវិកាសាលារៀនភ្ជាប់ជាមួយតម្រូវការជាក់ស្តែង<br>៨. ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងសូចនាករ<br>៩. ការអង្គាសថវិកាពីសហគមន៍<br>១០. ការធ្វើរបាយការណ៍ពីលទ្ធផលការងារទៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ<br>១១. ការរក្សាកំណត់ត្រាហិរញ្ញវត្ថុ<br>១២. ការពិនិត្យតាមដាន និងវាយតម្លៃបុគ្គលិក<br>១៣. ការធ្វើរបាយការណ៍ចំណាយ<br>១៤. ការជ្រើសរើសសម្ភារឧបទេស និងសម្ភារៈសិក្សារបស់សិស្ស<br>១៥. ការជ្រើសរើសសៀវភៅសិក្សានិងកម្មវិធីសិក្សា<br>១៦. ការរៀបចំកិច្ចប្រជុំនៅសាលារៀនជាមួយបុគ្គលិកនិងអ្នកពាក់ព័ន្ធ<br>១៧. ការធ្វើលទ្ធកម្មសម្ភារ និងឧបករណ៍ដើម្បីថែទាំហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថាន<br>១៨. ការកំណត់ចក្ខុវិស័យសាលារៀនជាមូលដ្ឋានសម្រាប់ធ្វើផែនការ ការពិនិត្យតាមដាន និងការវាយតម្លៃ | ១៩. ការរៀបចំថ្នាក់រៀន (ឧ. គ្រឿងសង្ហារិម)<br>២០. ការរៀបចំបណ្តាញទំនាក់ទំនងទៀងទាត់ជាមួយសហគមន៍ក្នុងមូលដ្ឋាន (ឧ. ការប្រជុំជាមួយគណៈកម្មការទ្រទ្រង់សាលារៀន ឪពុកម្តាយសិស្ស ។ល។)<br>២១. ការធានាការកសាងហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានមានសុវត្ថិភាពនិងជាទីមេត្រីសម្រាប់ការសិក្សារបស់កុមារ<br>២២. ការសង្កេតថ្នាក់រៀន<br>២៣. ការរចនាហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថាន<br>២៤. ការកំណត់នីតិវិធីធ្វើតេស្ត និងវាយតម្លៃ<br>២៥. ការប្រមូល និងវិភាគព័ត៌មានស្ថិតិសម្រាប់ធ្វើរបាយការណ៍<br>២៦. ការផ្គត់ផ្គង់សម្ភារ និងសម្ភារការិយាល័យ<br>២៧. ការជ្រើសរើសនិងតែងតាំងបុគ្គលិកបង្រៀន និងរដ្ឋបាល<br>២៨. ការកំណត់ប្រតិទិនសាលារៀន<br>២៩. ការផ្តល់មូលនិធិដល់ការអភិវឌ្ឍវិជ្ជាជីវៈ<br>៣០. ការបើកប្រាក់ខែដល់បុគ្គលិកសាលារៀន |

## ឯកសារទី ៥ខ៖ ការធ្វើចំណែកថ្នាក់ទិដ្ឋភាពសំខាន់ៗនៃប្រតិបត្តិការសាលារៀន

ចូរពិនិត្យមើលចម្លើយរបស់អ្នកនៅក្នុងលំហាត់ពីមុន ជាមួយនឹងការធ្វើចំណែកថ្នាក់ទាំងឡាយដែលមានផ្តល់ជូននៅក្នុងតារាងខាងក្រោមនេះ។ សូមពិភាក្សាអំពីរាល់ភាពខុសគ្នាពីចំណែកថ្នាក់ទាំងឡាយដែលអ្នកបានធ្វើនៅក្នុងក្រុមរបស់អ្នក។

| ផ្នែកនៃប្រតិបត្តិការសាលារៀន | សកម្មភាពសំខាន់ៗ |
|---|---|
| ការគ្រប់គ្រងបុគ្គលិក | 1. ការជ្រើសរើស និងចាត់តាំងបុគ្គលិកបង្រៀន និងបុគ្គលិករដ្ឋបាល<br>2. ការបង្កើតគ្រឿងលើកទឹកចិត្តសម្រាប់បុគ្គលិកបង្រៀន និងមិនបង្រៀន<br>3. ការពិនិត្យតាមដាន និងវាយតម្លៃបុគ្គលិក<br>4. ការបើកប្រាក់ខែដល់បុគ្គលិកសាលារៀន<br>5. ការរៀបចំនូវការអភិវឌ្ឍវិជ្ជាជីវៈ |
| ការគ្រប់គ្រងការបង្រៀន | 6. ការកំណត់ម៉ោងបង្រៀនតាមមុខវិជ្ជា<br>7. ការជ្រើសរើសសៀវភៅសិក្សា និងកម្មវិធីសិក្សា<br>8. ការកំណត់វិធីបង្រៀន<br>9. ការកំណត់ប្រតិទិនសាលារៀន<br>10. ការកំណត់នីតិវិធីធ្វើតេស្ត និងវាយតម្លៃ<br>11. ការរៀបចំថ្នាក់រៀន ( ឧ. គ្រឿងសង្ហារិម )<br>12. ការជ្រើសរើសសម្ភារឧបទេស និងសម្ភារសិក្សាសម្រាប់សិស្ស |
| ការគ្រប់គ្រងថវិកា | 13. ការកំណត់ថវិកាសាលារៀនផ្សារភ្ជាប់ជាមួយតម្រូវការជាក់ស្តែង<br>14. ការផ្គត់ផ្គង់សម្ភារ និងសម្ភារការិយាល័យ<br>15. ការរក្សាទុកកំណត់ត្រាហិរញ្ញវត្ថុ<br>16. ការផ្តល់ថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ<br>17. ការធ្វើរបាយការណ៍ការចំណាយ |
| ការថែទាំ & ហេដ្ឋារចនាសម្ព័ន្ធ | 18. ការធានាការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានមានសុវត្ថិភាព និងជាទីមេត្រីសម្រាប់ការសិក្សារបស់កុមារ<br>19. ការធ្វើលទ្ធកម្មសម្ភារ និងឧបករណ៍ដើម្បីថែទាំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន<br>20. ការត្រួតពិនិត្យអ្នកទទួលខុសត្រូវផ្នែកថែទាំ<br>21. ការរចនាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន |

| | |
|---|---|
| **ការគ្រប់គ្រងសាលារៀន ការពិនិត្យតាមដាន & ទំនាក់ទំនងជាមួយសហគមន៍** | 22. ការកំណត់ចក្ខុវិស័យសាលារៀន ជាមូលដ្ឋានសម្រាប់ធ្វើផែនការ ការពិនិត្យតាមដាន និងវាយតម្លៃ<br>23. ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងសូចនាករ<br>24. ការរៀបចំកិច្ចប្រជុំនៅសាលារៀនជាមួយបុគ្គលិក & អ្នកពាក់ព័ន្ធ<br>25. ការត្រួតពិនិត្យវត្តមាន និងកំណត់ត្រាការសិក្សា<br>26. ការសង្កេតថ្នាក់រៀន<br>27. ការប្រមូល និងវិភាគព័ត៌មានស្ថិតិសម្រាប់ធ្វើរបាយការណ៍<br>28. ការរៀបចំបណ្ដាញទំនាក់ទំនងទៀតទាត់ជាមួយសហគមន៍ក្នុងមូលដ្ឋាន (ឧ. កិច្ចប្រជុំជាមួយគណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតា។ល។)<br>29. ការរៃអង្គាសថវិកាពីសហគមន៍<br>30. ការធ្វើរបាយការណ៍លទ្ធផលការងារជូនរដ្ឋាភិបាល & អ្នកពាក់ព័ន្ធ |

# ឯកសារទី ៦៖ ការប្រើប្រាស់តំណសម្ព័ន្ធនៃបរិយាកាសអំណោយផលដើម្បីយល់ដឹងកាន់តែប្រសើរអំពីកម្រិតស្វ័យភាពនៅក្នុងសាលារៀនមួយ

## តើតំណសម្ព័ន្ធ (Continuum)ជាអ្វី?

តំណសម្ព័ន្ធ គឺជាការជាប់ទាក់ទងគ្នាជា "សម្ព័ន្ធ" តាមលំដាប់លំដោយ បន្តគ្នា ឬជាវិឌ្ឍនភាពនៃតម្លៃ ឬធាតុទាំងឡាយដែលប្រែប្រួលទៅតាមកម្រិតតូចៗ ចាប់ពី "ខ្សោយ" ទៅ "ខ្លាំង"។

## ការពន្យល់អំពីតំណសម្ព័ន្ធនៃបរិយាកាសអំណោយផលដែលប៉ះពាល់ដល់ការអនុវត្ត SBM

ជាការសំខាន់ណាស់ដែលយើងត្រូវទទួលស្គាល់ថា SBM មានច្រើនសណ្ឋាន ហើយត្រូវបានអនុវត្តស្របតាមតំណសម្ព័ន្ធ ចាប់ពីកម្រិតខ្សោយទៅខ្លាំង ពោលគឺ ភាពខ្លាំងនៃការអនុវត្ត SBM អាចប្រែប្រួលពីកម្រិតខ្សោយទៅខ្លាំង។[1] សមត្ថភាពរបស់សាលារៀនមួយក្នុងការអនុវត្តឱ្យបានពេញលេញនូវគោលការណ៍ SBM គឺអាស្រ័យលើបរិបទក្នុងមូលដ្ឋាន និងបរិមាណនៃស្វ័យភាពដែលសាលារៀនមួយមានជាក់ស្តែង។ ឧទាហរណ៍ តើសាលារៀននោះមានសិទ្ធិអំណាចក្នុងការចំណាយថវិការបស់ខ្លួនដោយសេរីដែរឬទេ? តើសាលារៀននោះអាចប្តូរកម្មវិធីសិក្សាដែរឬទេ? តើនរណាគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)? តើសាលារៀននោះមានការគ្រប់គ្រងលើការជួលបុគ្គលិកច្រើនកម្រិតណា? បើសាលារៀនមានការគ្រប់គ្រងច្រើនលើផ្នែកទាំងនេះ មានន័យថា សាលារៀនអាចអនុលោមតាមគោលការណ៍ SBM បានល្អប្រសើរ។ ការគ្រប់គ្រងបានតិច បង្ហាញឱ្យឃើញថា កម្រិតនៃការអនុវត្ត SBM នឹងកាន់តែខ្សោយទៅៗ (សូមមើលរូបភាពខាងក្រោម)។




***តំណសម្ព័ន្ធនៃការអនុវត្ត SBM***

ដោយសារគោលការណ៍ SBM អាចអនុវត្តទៅបានស្របនឹងតំណសម្ព័ន្ធនៃបរិបទនៃការគោរព វាមានសារៈសំខាន់ណាស់សម្រាប់អ្នកពាក់ព័ន្ធក្នុងសាលារៀនធ្វើការវាយតម្លៃបរិបទក្នុងមូលដ្ឋាន ដែលជាបរិយាកាសអំណោយផលរបស់ខ្លួន ដើម្បីកំណត់ថាយើងអាចអនុវត្តគោលការណ៍SBMបានជាក់ស្តែងកម្រិតណា។

---

[1] **សម្គាល់៖** ការអនុលោមតាមគោលការណ៍ SBM មានកម្រិតខ្សោយ ពុំមែនសុទ្ធតែបង្ហាញថាគុណភាពអប់រំទាប ឬការអនុលោមតាមគោលការណ៍ SBM មានកម្រិតខ្លាំង ពុំមែនសុទ្ធតែជានានូវគុណភាពអប់រំខ្ពស់ឡើយ។

ដ្យាក្រាមខាងក្រោម បង្ហាញពីតំណសម្ព័ន្ធនៃកម្រិតខុសៗគ្នានៃសេរីភាពដែលសាលារៀនមួយត្រូវធ្វើសេចក្តីសម្រេចចិត្តនៅក្នុងផ្នែកគន្លឹះទាំងឡាយនៃប្រតិបត្តិការសាលារៀន ដូចដែលបានពិភាក្សាមកពីខាងដើម។ កាលណាសាលារៀនមានស្វ័យភាពក្នុងការសម្រេចចិត្តកាន់តែច្រើន មានបរិយាកាស "អំណោយផល" កាន់តែច្រើន នោះនឹងជំរុញឱ្យអនុវត្តគោលការណ៍ SBM បានពេញលេញ។

**តំណសម្ព័ន្ធនៃបរិយាកាសអំណោយផលដែលប៉ះពាល់ដល់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន**

**(១) បរិយាកាសអំណោយផលខ្សោយ៖** សាលារៀនមានសេរីភាពតិចតួច ឬគ្មានទាល់តែសោះ ក្នុងការសម្រេចចិត្តដោយខ្លួនឯង។ (០-៥)

**(២) បរិយាកាសអំណោយផលខ្សោយល្មម៖** សាលារៀនមានសេរីភាពខ្លះក្នុងការសម្រេចចិត្តដោយខ្លួនឯង ប៉ុន្តែនៅតែមានកម្រិតនៅឡើយ។ (៦-១១)

**(៣) បរិយាកាសអំណោយផលល្មម៖** សាលារៀនមានផ្នែកជាច្រើនដែលខ្លួនអាចធ្វើការសម្រេចចិត្តសំខាន់ៗ ជាពិសេស នៅពេលផ្នែកទាំងនេះទាក់ទងនឹងថវិកា បុគ្គលិក និងការគ្រប់គ្រងការបង្រៀន។ (១២-២១)

**(៤) បរិយាកាសអំណោយផលខ្លាំងល្មម៖** សាលារៀនមានសេរីភាពទូលំទូលាយគ្រាន់បើក្នុងការសម្រេចចិត្តនៅក្នុងផ្នែកជាច្រើន ទោះបីជានៅតែមានការដាក់កំហិតមួយចំនួនពីថ្នាក់លើក៏ដោយ។ (២២-២៧)

**(៥) បរិយាកាសអំណោយផលខ្លាំង៖** សាលារៀនមានសេរីភាពជាច្រើនក្នុងការសម្រេចចិត្តនៅក្នុងផ្នែកភាគច្រើន ឬគ្រប់ផ្នែកទាំងអស់នៃប្រតិបត្តិការសាលារៀន រួមមានផ្នែកដូចជា ការបង្រៀន បុគ្គលិក ការគ្រោងថវិកា ហេដ្ឋារចនាសម្ព័ន្ធ & ការគ្រប់គ្រងរដ្ឋបាល។ (២៨-៣២)

## ឯកសារទី៧៖ រង្វាយតម្លៃបរិយាកាសអំណោយផលនៅក្នុងសាលារៀនអ្នក

**សេចក្តីណែនាំ៖** ឧបករណ៍វាយតម្លៃខាងក្រោមនេះ នឹងជួយដល់អ្នកក្នុងការកំណត់ពីកម្រិតដែលបរិយាកាសប្រតិបត្តិការសាលារៀនរបស់អ្នកថានឹងមានអំណោយផលដល់អ្នកក្នុងការអនុវត្តគោលការណ៍ SBM ។ ដូចដែលបានកត់សម្គាល់នៅក្នុងឯកសារមុននេះ កាលណាសាលារៀនមានសេរីភាព ឬស្វ័យភាពកាន់តែច្រើននៅក្នុងបរិយាកាសប្រតិបត្តិការរបស់ខ្លួន សាលារៀននោះនឹងមានភាពងាយស្រួលកាន់តែច្រើន ដើម្បីអាចអនុវត្តគោលការណ៍នៃការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាព។ បន្ទាប់ពីបានឆ្លើយសំណួរទាំងឡាយនៅក្នុងឧបករណ៍ខាងក្រោមនេះ សូមគណនាពិន្ទុរបស់អ្នកដើម្បីកំណត់ទីតាំងសាលារៀនរបស់អ្នកនៅក្នុងតំណសម្ព័ន្ធនៃបរិយាកាសអំណោយផល ដូចមានបង្ហាញជូននៅក្នុងឯកសារទី ៦។

| ផ្នែកនៃប្រតិបត្តិការសាលារៀន | សំណួរស្វ័យវាយតម្លៃ<br>(បាទ/ចាស៎ = ១; ទេ=០) | បាទ/ចាស៎ | ទេ | ពិន្ទុរបស់អ្នក |
|---|---|---|---|---|
| ការគ្រប់គ្រងបុគ្គលិក | 1. តើសាលារៀនអ្នកអាចជ្រើសរើស/ជួលបុគ្គលិកដោយខ្លួនឯងបានដែរឬទេ ? | ___ | ___ | ពិន្ទុសរុបរង = ______ |
| | 2. តើសាលារៀនអ្នកអាចជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា & គ្រូបង្រៀនសហគមន៍បានដែរឬទេ | ___ | ___ | |
| | 3. តើសាលារៀនអ្នកអាចទូទាត់គ្រឿងលើកទឹកចិត្តជូនបុគ្គលិកខ្លួនបានដែរឬទេ ? | ___ | ___ | |
| | 4. តើអ្នកអាចពិនិត្យតាមដាន ផ្តល់ដំបូន្មាន និងដាក់វិន័យគ្រូបង្រៀនរបស់អ្នកបានដែរឬទេ ? | ___ | ___ | |
| | 5. តើអ្នកអាចបណ្តេញបុគ្គលិកចោលដោយសារការមិនអនុវត្តការងារបានដែរឬទេ ? | ___ | ___ | |
| | 6. តើអ្នកអាចរៀបចំសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀនរបស់អ្នកដោយខ្លួនឯងបានដែរឬទេ ? | ___ | ___ | |
| ការគ្រប់គ្រងការបង្រៀន | 7. តើអ្នកអាចប្តូរចំនួនម៉ោងដែលសិស្សសិក្សាក្នុងមួយថ្ងៃបានដែរឬទេ ? | ___ | ___ | ពិន្ទុសរុបរង = ______ |
| | 8. តើអ្នកអាចប្តូរកាលវិភាគដែលសាលារៀនត្រូវបើកដំណើរការសម្រាប់ការសិក្សា (ឧ. ចាប់ផ្តើមយឺតជាងមុន ចប់យឺតជាងមុន។ល។) បានដែរឬទេ ? | ___ | ___ | |
| | 9. ឧបមាថាអ្នកមានធនធាន តើអ្នកអាចប្តូរកម្មវិធីសិក្សា និងជ្រើសរើសសៀវភៅសិក្សាខុសពីសៀវភៅដែលអ្នកកំពុងប្រើបច្ចុប្បន្នដែរឬទេ ? | ___ | ___ | |
| | 10. តើអ្នកមានសិទ្ធិអំណាចក្នុងការបន្ថែមសម្ភារកម្មវិធីសិក្សាបំពេញបន្ថែមដើម្បីគាំទ្រដល់សៀវភៅសិក្សាបច្ចុប្បន្នរបស់អ្នកដែរឬទេ ? | ___ | ___ | |
| | 11. តើអ្នកអាចណែនាំវិធីបង្រៀនថ្មីៗ ដើម្បីឱ្យគ្រូបង្រៀនរបស់អ្នកធ្វើតាមដោយពុំចាំបាច់មានការប្រឹក្សាយោបល់ពីថ្នាក់លើដែរឬទេ ? | ___ | ___ | |

| ផ្នែកនៃប្រតិបត្តិការសាលារៀន | សំណួរស្វ័យវាយតម្លៃ (បាទ/ចាស់ = ១; ទេ=០) | បាទ/ចាស់ | ទេ | ពិន្ទុរបស់អ្នក |
|---|---|---|---|---|
| | 12. តើអ្នកអាចផ្តល់ថវិកាដើម្បីជួយឱ្យគ្រូបង្រៀនអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ខ្លួន (ឧ. សិក្សានៅក្នុងវគ្គសិក្សាពិសេសដែលអាចផ្តល់អត្ថប្រយោជន៍ដល់សាលារៀន) ដែរឬទេ? | __ | __ | |
| | 13. តើអ្នកមានសិទ្ធិអំណាចច្រើនទៅលើការរៀបចំខ្លឹមសារនៃសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈនៅសាលារៀនរបស់អ្នកដែរឬទេ? | __ | __ | |
| | 14. តើអ្នកអាចអភិវឌ្ឍ/រៀបចំវង្វាយតម្លៃសិស្សតាមវិធីទាំងឡាយដែលខុសគ្នាពីអ្វីដែលក្រសួងតម្រូវបច្ចុប្បន្ននេះដែរឬទេ? (ឧ. ប្រើប្រាស់តេស្តក្រដាស និងខ្មៅដៃ ដាក់បញ្ចូលកម្រងស្នាដៃជាផ្នែកនៃវង្វាយតម្លៃសិស្សរបស់អ្នក)? | __ | __ | |
| | 15. តើសាលារៀនអ្នកអាចចុះអនុស្សារណៈយោគយល់ (MoU) ជាមួយអង្គការ និងស្ថាប័នផ្សេងៗដើម្បីអភិវឌ្ឍការអប់រំនៅសាលារៀនរបស់អ្នក (ឧ. រៀបចំការផ្លាស់ប្តូរបុគ្គលិក រៀបចំពិព័ណ៌ការអប់រំពិសេស ទទួលអាហារូបករណ៍សម្រាប់សិស្ស និងបុគ្គលិក។ល។) ដែរឬទេ? | __ | __ | |
| | 16. តើសាលារៀនអ្នកអាចរៀបចំឡើងវិញនូវការរៀបចំគ្រឿងសង្ហារិមក្នុងថ្នាក់រៀនតាមរបៀបណាមួយដែលអ្នកចង់បានដែរឬទេ? | __ | __ | |
| | 17. តើសាលារៀនអ្នកអាចផ្គត់ផ្គង់សម្ភារសិក្សា និងសម្ភារបង្រៀនពិសេសដើម្បីគាំទ្រដល់សកម្មភាពក្នុងថ្នាក់រៀនដែរឬទេ | __ | __ | |
| ការគ្រប់គ្រងថវិកា | 18. តើសាលារៀនអ្នកអាចបន្ថែមផ្នែកទាំងឡាយនៃការចំណាយទៅលើថវិកាដំណើរការសាលារៀនអ្នក ដែលពុំមានបញ្ជាក់ច្បាស់នៅក្នុងថវិកាតាមជំពូកគណនីបច្ចុប្បន្ន (ឧ. ដំណើរទស្សនកិច្ចសិក្សា គ្រឿងលើកទឹកចិត្ត។ល។) ដែរឬទេ? | __ | __ | ពិន្ទុសរុបរង = ______ |
| | 19. តើអ្នកអាចប្រើប្រាស់ថវិកាសាលារៀនអ្នកដើម្បីផ្គត់ផ្គង់សម្ភារសិក្សា និងសម្ភារបង្រៀនពិសេសដោយពុំចាំបាច់មានការប្រឹក្សាយោបល់ពីថ្នាក់លើដែរឬទេ? | __ | __ | |
| | 20. តើអ្នកមានលទ្ធភាពប្រើប្រាស់ជំនួយថវិកាសាលារៀនដែលពុំមានរចនាសម្ព័ន្ធ និង/ឬបើកចំហដែរឬទេ? | __ | __ | |
| | 21. តើអ្នកអាចផ្តល់ថវិកាដល់ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកអ្នកជាមួយនឹងថវិកាសាលារៀនអ្នកដែរឬទេ? | __ | __ | |
| | 22. តើសាលារៀនអ្នកអាចបើកគណនីធនាគារផ្ទាល់ខ្លួនដោយពុំចាំបាច់មានការអនុញ្ញាតពីថ្នាក់លើដែរឬទេ? | __ | __ | |
| | 23. តើសាលារៀនអ្នកអាចសន្សំលុយនៅក្នុងគណនីធនាគាររបស់ខ្លួនអំឡុងថវិកាដែលមិនត្រូវបានប្រើប្រាស់ឬនៅសល់ ដែរឬទេ? | __ | __ | |
| ការថែទាំ & ហេដ្ឋារចនាសម្ព័ន្ធ | 24. តើអ្នកអាចចាត់វិធានការដែលធានាថា ហេដ្ឋារចនាសម្ព័ន្ធអគារ និងបរិស្ថានមានសុវត្ថិភាព និងជាទីមេត្រីសម្រាប់ការសិក្សារៀនសូត្ររបស់កុមារដែរឬទេ? | __ | __ | ពិន្ទុសរុបរង = ______ |

| ផ្នែកនៃប្រតិបត្តិការសាលារៀន | សំណួរស្វ័យវាយតម្លៃ (បាទ/ចាស៎ = ១; ទេ=0) | បាទ/ចាស៎ | ទេ | ពិន្ទុរបស់អ្នក |
|---|---|---|---|---|
| | 25. តើអ្នកអាចផ្គត់ផ្គង់សម្ភារ និងឧបករណ៍ដើម្បីថែទាំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានដែរឬទេ? | __ | __ | |
| | 26. តើអ្នកអាចជួល និងមើលការខុសត្រូវអ្នកថែទាំដែលទទួលបន្ទុកការថែទាំដែរឬទេ? | __ | __ | |
| | 27. នៅពេលទទួលថវិកាសម្រាប់ការសាងសង់ តើអ្នកអាចគូសប្លង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនឡើងវិញ ដោយផ្អែកលើគំរូថ្មីៗដែលអ្នករកបានដែរឬទេ? | __ | __ | |
| ការគ្រប់គ្រងសាលារៀន ការពិនិត្យតាមដាន & ទំនាក់ទំនងជាមួយសហគមន៍ | 28. តើអ្នកអាចបង្កើតឯកសារផែនការទាំងឡាយ ដែលកំណត់ចក្ខុវិស័យរបស់សាលារៀនអ្នកជាមូលដ្ឋានសម្រាប់ការធ្វើផែនការ ពិនិត្យតាមដាន និងវាយតម្លៃដែរឬទេ? | __ | __ | ពិន្ទុសរុបរង = ______ |
| | 29. តើអ្នកអាចបង្កើតផែនការអភិវឌ្ឍន៍សាលារៀន ដែលងាយស្រួលផ្តល់ថវិកាដោយកញ្ចប់ថវិកាដំណើរការសាលារៀនរបស់អ្នកដែរឬទេ? | __ | __ | |
| | 30. តើអ្នកអាចបង្កើតសូចនាករផ្ទាល់ខ្លួនអ្នកដើម្បីត្រួតពិនិត្យផែនការរបស់អ្នកដែរឬទេ? | __ | __ | |
| | 31. តើអ្នកអាចអង្កេតស្វែងរក និងវិភាគទានកម្លាំងពលកម្មពីសហគមន៍បានដែរឬទេ? | __ | __ | |
| | 32. តើអ្នកអាចកោះប្រជុំជាមួយមាតាបិតា និងសហគមន៍ដើម្បីពិភាក្សាបញ្ហាជាក់លាក់ដែរឬទេ? | __ | __ | |
| **សរុបរួម** | | | | __/៣២ |

## ការពិភាក្សាក្រុម៖ ការកំណត់នូវការរំពឹងទុករបស់អ្នក

នៅពេលអ្នកបានបញ្ចប់វង្វាយតម្លៃខាងលើរួចហើយ ចូរសាកល្បងកំណត់ទីតាំងដែលសាលារៀនរបស់អ្នកស្ថិតនៅក្នុងតំណសម្ព័ន្ធនៃបរិយាកាសអំណោយផល ដូចមានបង្ហាញនៅក្នុងឯកសារទី ៦។ នៅក្នុងក្រុមតូចៗរបស់អ្នក ចូរពិភាក្សាអំពីសំណួរទាំងឡាយខាងក្រោមហើយត្រូវប្រាកដថាអាចបង្ហាញចម្លើយរបស់អ្នកជាមួយក្រុមទាំងមូលនៅក្នុងអំឡុងពេលប្រជុំពេញអង្គ។

1. តើសាលារៀនភាគច្រើននៅក្នុងក្រុមរបស់អ្នកស្ថិតនៅក្នុងទីតាំងណាមួយ ក្នុងន័យបរិយាកាសអំណោយផលសម្រាប់ការអនុវត្ត SBM ?
2. តើមានសាលារៀនមួយចំនួនទទួលបានពិន្ទុប្រសើរជាង ឬអន់ជាងសាលារៀនអ្នកដែរឬទេ ? ដោយសារតែសាលារៀនទាំងអស់របស់អ្នកស្ថិតនៅក្នុងប្រព័ន្ធអប់រំដូចគ្នា តើហេតុអ្វីបានជាអ្នកយល់ថាមានពិន្ទុខុសគ្នា ?
3. ប្រសិនបើសាលារៀនអ្នកមានបរិយាកាសអំណោយផល "ខ្សោយ" តើមានទំនាក់ទំនងអ្វីខ្លះសម្រាប់ការអនុវត្តន៍ការគ្រប់គ្រងតាមសាលារៀន និងលក្ខណៈនៃផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក ?
4. ប្រសិនបើសាលារៀនអ្នកមានបរិយាកាសអំណោយផល "ល្មម ឬ ខ្លាំង" តើមានទំនាក់ទំនងអ្វីខ្លះសម្រាប់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងលក្ខណៈនៃផែនការអភិវឌ្ឍន៍សាលារៀនរៀនរបស់អ្នក ?

## ឯកសារទី៨ក៖ យន្តការតាមសាលារៀនដែលគាំទ្រដំណើរការ SBM

### ការពន្យល់បកស្រាយ៖

ការគ្រប់គ្រងតាមសាលារៀនមានន័យថា ដំណើរការមួយដែលការិយាល័យកណ្ដាល បោះបង់អំណាចមួយចំនួនរបស់ខ្លួន ហើយផ្ដល់វាជូនដល់សាលារៀននានា ដើម្បីឱ្យសាលារៀនទាំងនោះមានការគ្រប់គ្រងច្រើនជាងមុន ទៅលើដំណើរការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងការវិភាជធនធាន និងរចនាសម្ព័ន្ធសាលារៀន (ឧ. ស្វ័យភាព)។ ប៉ុន្តែ កំណើនការគ្រប់គ្រងនេះ ត្រូវតែអនុវត្តតាមវិធីមួយដែលធ្វើឱ្យសាលារៀន (ឧ. នាយកសាលារៀន គ្រូបង្រៀន) អាចទទួលខុសត្រូវចំពោះភាពជោគជ័យ ឬបរាជ័យ (ឧ. គណនេយ្យភាព)។

ដើម្បីឱ្យអំណាចដែលប្រគល់ដោយការិយាល័យកណ្ដាលជូនសាលារៀន អាចប្រើប្រាស់ដោយប្រសិទ្ធភាព ត្រូវតែមានរចនាសម្ព័ន្ធ និងដំណើរការមួយចំនួនក្នុងដៃ ដើម្បីឱ្យសាលារៀននោះត្រូវបានគ្រប់គ្រងតាមរបៀបមួយដែលកែលម្អប្រតិបត្តិការរបស់ខ្លួនផង ផ្ដល់សិទ្ធិអំណាចដល់គ្រប់អ្នកពាក់ព័ន្ធផង និងមានតម្លាភាពផង។

**នៅក្នុងករណីជាច្រើន សាលារៀនមានរចនាសម្ព័ន្ធ និងដំណើរការទាំងនេះក្នុងដៃរួចទៅហើយ ប៉ុន្តែវានៅតែពុំអាចដំណើរការបានល្អនៅឡើយ។ សារៈសំខាន់បំផុតនៃរចនាសម្ព័ន្ធ និងដំណើរការទាំងនេះ មានសង្ខេបនៅក្នុងដ្យាក្រាមខាងក្រោមនេះ។**

**សូមពិនិត្យឡើងវិញនូវតួនាទីនីមួយៗនៃរចនាសម្ព័ន្ធ/ដំណើរការទាំងនេះ ថាគួរដើរតួអ្វីខ្លះនៅក្នុងសាលារៀនរបស់អ្នក តាមស្ថានភាពជាក់ស្ដែងក្នុងសាលារៀនអ្នក និងអ្វីដែលអាចធ្វើបានដើម្បីកែលម្អវា។**

រចនាសម្ព័ន្ធ & ដំណើរការ ដែលគាំទ្រដល់ការគ្រប់គ្រងតាមសាលារៀន



**លំហាត់៖** លំហាត់នេះ ជួយឱ្យអ្នកទាំងអស់គ្នាយល់បានកាន់តែប្រសើរអំពីតួនាទីអ្វីខ្លះ ឬមុខងារអ្វីខ្លះដែលរចនាសម្ព័ន្ធ និងដំណើរការគួរដើរតួនាទីនៅក្នុងសាលារៀនដើម្បីឱ្យ SBM ដំណើរការ។ តួនាទី/មុខងារទាំងនេះមានសង្ខេបនៅខាងក្រោមតាមលំដាប់ចៃដន្យ។ នៅក្នុងក្រុមរបស់អ្នកចូរពិនិត្យឡើងវិញទៅលើតួនាទី និងមុខងារទាំងនេះរួចហើយរៀបចំវាទៅតាមរចនាសម្ព័ន្ធ ឬដំណើរការដែលវាឆ្លើយតបជាមួយឱ្យបានល្អបំផុត។ ចូរប្រើតារាងដែលមានផ្តល់ជូនខាងក្រោមដើម្បីបង្ហាញចម្លើយរបស់អ្នក។

**តួនាទី & មុខងារ**

1. ផ្តល់ជូនដំណើរការមួយដែលអ្នកពាក់ព័ន្ធអាចកំណត់បញ្ហា & រកដំណោះស្រាយបាន
2. ធានានូវអន្តរកម្ម និងកិច្ចសហការក្នុងចំណោមគ្រូបង្រៀន
3. ផ្តល់កម្លាំងពលកម្មជូនសាលារៀនសម្រាប់កិច្ចការជាក់លាក់មួយចំនួន (ឧ. ការថែទាំ ជួសជុល បំណិនជីវិត ។ល។)
4. ផ្សារភ្ជាប់ថវិកា/សកម្មភាពទៅនឹងគោលនយោបាយអប់រំ
5. បង្កើនស្វ័យភាព & គណនេយ្យភាពហិរញ្ញវត្ថុរបស់សាលារៀនដោយផ្តល់ជូនវេទិកាពិភាក្សា
6. ផ្តល់ជូនបណ្តាញមួយដើម្បីឱ្យសាលារៀនផ្តល់ធនធានដល់សិស្សានុសិស្ស ដើម្បីឱ្យពួកគេអាចធ្វើការកែលម្អទាំងឡាយនៅក្នុងសាលារៀននោះបាន
7. អនុវត្តផែនការរយៈពេលវែងសម្រាប់ SBM
8. ផ្តល់ជូនរចនាសម្ព័ន្ធសម្រាប់សកម្មភាពទាំងឡាយ ដែលនឹងត្រូវអនុវត្តដើម្បីអភិវឌ្ឍន៍សាលារៀន កំណត់នូវធនធានដែលត្រូវការ និងពន្យល់អំពីរបៀបដែលការវាយតម្លៃគួរតែធ្វើឡើង
9. លើកកម្ពស់ "គុណតម្លៃ" និង "បទដ្ឋាន" រួមក្នុងចំណោមអ្នកអប់រំ
10. ធ្វើវង្វាយតម្លៃសិស្សជាប្រចាំសម្រាប់ការសិក្សា & សមិទ្ធផលសិក្សា
11. រៃអង្គាសថវិកាពីសហគមន៍
12. ធានានូវការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀន
13. អនុវត្តសកម្មភាពដែលទាមទារនូវការចុះតាមសហគមន៍ (ឧ. យុទ្ធនាការចុះឈ្មោះចូលរៀន)
14. ធ្វើសវនកម្មថវិកាអប់រំ
15. ផ្តល់រចនាសម្ព័ន្ធមួយដើម្បីឱ្យសិស្សទទួលខុសត្រូវចំពោះសកម្មភាពមួយចំនួនក្នុងសាលារៀន
16. លើកទឹកចិត្តឱ្យមានការផ្តោតអារម្មណ៍យ៉ាងមុតមាំលើការសិក្សារបស់សិស្ស
17. ផ្តល់ជូនបណ្តាញទំនាក់ទំនងផ្ទាល់មួយសម្រាប់ការប្រាស្រ័យទាក់ទងរវាងសាលារៀន & សហគមន៍
18. អនុវត្តផែនការអភិវឌ្ឍន៍សាលារៀន
19. ផ្តល់កម្លាំងពលកម្មសិស្សតាមការរៀបចំ ដើម្បីឱ្យសាលារៀនគាំទ្រដល់មុខងារសំខាន់ៗមួយចំនួន (ឧ. បណ្ណាល័យ កីឡា)
20. ផ្តល់ជូនដំណើរការមួយដែលអ្នកពាក់ព័ន្ធសាលារៀនអាចពិភាក្សាគ្នាអំពីបញ្ហារួមនានាបាន
21. ជំរុញឱ្យមាន "កិច្ចសន្ទនាបែបឆ្លុះបញ្ចាំង" ក្នុងចំណោមអ្នកអប់រំ

**សេចក្ដីណែនាំ៖** ចូរសរសេរអំពីតួនាទី និងមុខងារដែលបានមកពីបញ្ជីខាងលើទៅតាមកន្លែងដែលសមស្របនៅក្នុងតារាងដែលមានបង្ហាញជូនខាងក្រោមនេះ។

| រចនាសម្ព័ន្ធ/ដំណើរការ | តួនាទី ឬមុខងារ |
|---|---|
| គណៈកម្មការគ្រប់គ្រងសាលារៀន | 1. ____<br>2. ____<br>3. ____<br>4. ____<br>5. ____<br>6. ____<br>7. ____ |
| គណៈកម្មការទ្រទ្រង់សាលារៀន | 1. ____<br>2. ____<br>3. ____<br>4. ____ |
| ក្រុមប្រឹក្សាសិស្ស | 1. ____<br>2. ____<br>3. ____ |
| ផែនការអភិវឌ្ឍន៍សាលារៀន | 1. ____<br>2. ____<br>3. ____ |
| សហគមន៍សិក្សាវិជ្ជាជីវៈ | 1. ____<br>2. ____<br>3. ____<br>4. ____ |

នៅពេលអ្នកបានបញ្ចប់លំហាត់ខាងលើនេះហើយ ចូរប្រៀបធៀបចម្លើយរបស់អ្នកជាមួយចម្លើយទាំងឡាយដែលមានផ្ដល់ជូននៅក្នុង ឯកសារទី ៨ខ ។ បន្ទាប់មក ចូរព្យាយាមឆ្លើយសំណួរខាងក្រោមនៅក្នុងក្រុមរបស់អ្នក។

## សំណួរ

1. តើចម្លើយរបស់ក្រុមអ្នកត្រូវគ្នាជាមួយនឹងចម្លើយនៅក្នុង ឯកសារទី ៨២ ដែរឬទេ? តើអ្នកយល់ស្របជាមួយភាពខុសគ្នាដែរឬទេ ឬអ្នកយល់ថាការធ្វើចំណែកថ្នាក់របស់អ្នកប្រសើរជាង? ចូរពន្យល់ចម្លើយរបស់អ្នក។
2. ប្រសិនបើអ្នកបានកំណត់តួនាទី និងមុខងារនៃរចនាសម្ព័ន្ធផ្សេងៗ ដែលខុសគ្នាពីចំណាត់ថ្នាក់ផ្លូវការ តើអ្នកយល់ថាអ្នកគួរតែត្រូវបានអនុញ្ញាតឱ្យរក្សាទុកចំណាត់ថ្នាក់ផ្ទាល់របស់អ្នកក្រោមគោលការណ៍ SBM ដែរឬទេ? ចូរពន្យល់។
3. ហេតុអ្វីបានជាអ្នកយល់ថា វាមានសារៈសំខាន់បំផុតក្នុងការមានរចនាសម្ព័ន្ធផ្សេងៗគ្នានៅក្នុងសាលារៀនដើម្បីធ្វើឱ្យ SBM ដំណើរការទៅបានល្អ?
4. តើមានសាលារៀនប៉ុន្មាននៅក្នុងក្រុមរបស់អ្នក ដែលមានរចនាសម្ព័ន្ធ/ដំណើរការទាំងអស់នេះនៅក្នុងដៃរួចហើយ (តើសាលារៀនប៉ុន្មានមានទាំងអស់ តើសាលារៀនប៉ុន្មានមាន ៣ ឬមាន ២ ។ល។)?
5. ផ្អែកលើការពិនិត្យឡើងវិញទៅលើតួនាទី និងមុខងារដែលមានផ្តល់ជូនក្នុងលំហាត់នេះ ចូរធ្វើការស្ទង់មតិសាលារៀននៅក្នុងក្រុមរបស់អ្នក និងបញ្ជាក់ថាតើមានសាលារៀនប៉ុន្មាន "សប្បាយចិត្តបំផុត" ជាមួយនឹងដំណើរការរបស់រចនាសម្ព័ន្ធ/ដំណើរការទាំងនេះ; តើមានសាលារៀនប៉ុន្មានដែលពេញចិត្តប៉ុន្តែនៅតែត្រូវការកែលម្អជាច្រើនទៀត; តើមានសាលារៀនប៉ុន្មានដែលមិនសប្បាយចិត្តទាល់តែសោះជាមួយនឹងដំណើរការបច្ចុប្បន្នរបស់រចនាសម្ព័ន្ធ/ដំណើរការទាំងនេះ។
6. ចំពោះសាលារៀនដែលមិនសប្បាយចិត្តជាមួយនឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន សហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន តើអាចធ្វើអ្វីខ្លះដើម្បីធ្វើការកែលម្អបាន?

**ចូរប្រើតារាងខាងក្រោមដើម្បីកត់ត្រាចម្លើយរបស់អ្នកសម្រាប់សំណួរទាំងឡាយខាងលើ៖**

| |
|---|
| **សំណួរទី ១៖** |
| **សំណួរទី ២៖** |

**សំណួរទី ៣៖**

**សំណួរទី ៤៖**

សាលារៀនដែលមានរចនាសម្ព័ន្ធ/ដំណើរការទាំងអស់នេះក្នុងដៃ៖ ______

សាលារៀនដែលមាន ៤ ក្នុងចំណោមរចនាសម្ព័ន្ធ/ដំណើរការទាំងនេះក្នុងដៃ៖ ______

សាលារៀនដែលមាន ៣ ក្នុងចំណោមរចនាសម្ព័ន្ធ/ដំណើរការទាំងនេះក្នុងដៃ៖ ______

សាលារៀនដែលមាន ១ ឬ ២ ក្នុងចំណោមរចនាសម្ព័ន្ធ/ដំណើរការទាំងនេះក្នុងដៃ៖ ______

សាលារៀនដែលពុំមានអ្វីសោះក្នុងចំណោមរចនាសម្ព័ន្ធ/ដំណើរការទាំងនេះក្នុងដៃ៖ ______

**សំណួរទី ៥៖**

ក្នុងករណីដែលរចនាសម្ព័ន្ធ/ដំណើរការទាំងបួនប្រព្រឹត្តទៅបានល្អនៅក្នុងសាលារៀននីមួយៗ សូមបញ្ជាក់អំពីកម្រិតនៃការពេញចិត្តរបស់សាលារៀននីមួយៗ៖

- "សប្បាយចិត្តបំផុត" ជាមួយនឹងដំណើរការនៃរចនាសម្ព័ន្ធ/ដំណើការទាំងនេះ៖ _____
- "ពេញចិត្ត ប៉ុន្តែនៅតែត្រូវការកែលម្អជាច្រើនទៀត"៖ _____
- សាលារៀនដែល "មិនសប្បាយចិត្តទាល់តែសោះ"៖ _____

**សំណួរទី ៦៖**

## ឯកសារទី ៨ខ៖ តួនាទី & មុខងារនៃយន្តការដែលគាំទ្រគោលការណ៍ SBM

### គណៈកម្មការគ្រប់គ្រងសាលារៀន

- បង្កើនស្វ័យភាព & គណនេយ្យភាពហិរញ្ញវត្ថុរបស់សាលារៀនដោយផ្តល់ជូនវេទិកាពិភាក្សា
- ធ្វើសវនកម្មថវិកាអប់រំ
- ផ្សារភ្ជាប់ថវិកា/សកម្មភាពទៅនឹងគោលនយោបាយអប់រំ
- ធានានូវការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀន
- អនុវត្តផែនការអភិវឌ្ឍន៍សាលារៀន
- អនុវត្តផែនការរយៈពេលវែងសម្រាប់ SBM
- ធ្វើវង្វាយតម្លៃសិស្សជាប្រចាំសម្រាប់ការសិក្សា & លទ្ធផលសិក្សា

### គណៈកម្មការទ្រទ្រង់សាលារៀន

- ផ្តល់ជូនបណ្តាញទំនាក់ទំនងផ្ទាល់មួយសម្រាប់ការប្រាស្រ័យទាក់ទងរវាងសាលារៀន & សហគមន៍
- រៃអង្គាសថវិកាពីសហគមន៍
- ផ្តល់កម្លាំងពលកម្មជូនសាលារៀនសម្រាប់កិច្ចការជាក់លាក់មួយចំនួន ( ឧ. ការថែទាំជួសជុល បំណិនជីវិត ។ល។ )
- អនុវត្តសកម្មភាពដែលទាមទារនូវការចុះតាមសហគមន៍ ( ឧ. យុទ្ធនាការចុះឈ្មោះចូលរៀន )

### ក្រុមប្រឹក្សាសិស្ស

- ផ្តល់រចនាសម្ព័ន្ធមួយដើម្បីឱ្យសិស្សទទួលខុសត្រូវចំពោះសកម្មភាពមួយចំនួនក្នុងសាលារៀន
- ផ្តល់ជូនបណ្តាញមួយដើម្បីឱ្យសាលារៀនផ្តល់ធនធានដល់សិស្សានុសិស្ស ដើម្បីឱ្យពួកគេអាចធ្វើការកែលម្អទាំងឡាយនៅក្នុងសាលារៀននោះបាន
- ផ្តល់កម្លាំងពលកម្មសិស្សតាមការរៀបចំ ដើម្បីឱ្យសាលារៀនគាំទ្រដល់មុខងារសំខាន់ៗមួយចំនួន ( ឧ. បណ្ណាល័យ កីឡា )

### ផែនការអភិវឌ្ឍន៍សាលារៀន

- ផ្តល់ជូនដំណើរការមួយដែលអ្នកពាក់ព័ន្ធសាលារៀនអាចពិភាក្សាគ្នាអំពីបញ្ហារួមនានាបាន
- ផ្តល់ជូនដំណើរការមួយដែលអ្នកពាក់ព័ន្ធអាចកំណត់បញ្ហា & រកដំណោះស្រាយបាន
- ផ្តល់ជូនរចនាសម្ព័ន្ធសម្រាប់សកម្មភាពទាំងឡាយ ដែលនឹងត្រូវអនុវត្តដើម្បីកែលម្អសាលារៀន កំណត់នូវធនធានដែលត្រូវការ និងពន្យល់អំពីរបៀបដែលការវាយតម្លៃគួរតែធ្វើឡើង

### សហគមន៍សិក្សាវិជ្ជាជីវៈ

- ជំរុញឱ្យមាន "កិច្ចសន្ទនាបែបឆ្លុះបញ្ចាំង" ក្នុងចំណោមអ្នកអប់រំ
- លើកទឹកចិត្តឱ្យមានការផ្តោតអារម្មណ៍យ៉ាងមុតមាំលើការសិក្សារបស់សិស្ស
- ធានានូវអន្តរកម្ម និងកិច្ចសហការក្នុងចំណោមគ្រូបង្រៀន
- លើកកម្ពស់ "គុណតម្លៃ" និង "បទដ្ឋាន" រួមក្នុងចំណោមអ្នកអប់រំ

# ឯកសារទី៩៖ គោលបំណង រចនាសម្ព័ន្ធ & ការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសាលារៀន

សន្មត់ថាគ្រប់សាលារៀនសុទ្ធតែមានគណៈកម្មការគ្រប់គ្រងសាលារៀន ហើយសាលារៀនសុទ្ធតែបានទទួលការបណ្តុះបណ្តាលអំពីរបៀបរៀបចំគណៈកម្មការគ្រប់គ្រង និងមុខងារនានារបស់គណៈកម្មការគ្រប់គ្រង។ ព័ត៌មានខាងក្រោមនេះផ្តល់ជូនជាការពិនិត្យឡើងវិញសម្រាប់អ្វីដែលគួរតែមាននៅក្នុងដៃ។




**គោលបំណងនៃគណៈកម្មការគ្រប់គ្រងសាលារៀនគឺ៖** ដើម្បីសហការ*ជាមួយមនុស្សក្នុងសហគមន៍ និងនាយកសាលារៀននៅតាមសាលារៀន ដើម្បីកែលម្អគុណភាពអប់រំ។* ការណ៍នេះងាយស្រួលនិយាយ ប៉ុន្តែពិបាកធ្វើ!

**ជាផ្លូវការ មានទំនួលខុសត្រូវ[2] សម្រាប់គណៈកម្មការគ្រប់គ្រងសាលារៀនចំនួន៧ចំណុច៖** (១) បង្កើនស្វ័យភាព & គណនេយ្យភាពហិរញ្ញវត្ថុរបស់សាលារៀន; (២) ធ្វើសវនកម្មថវិកាអប់រំ; (៣) ផ្សារភ្ជាប់ថវិកា/សកម្មភាពទៅនឹងគោលនយោបាយអប់រំ; (៤) ធានានូវការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀន; (៥) អនុវត្តផែនការអភិវឌ្ឍន៍សាលារៀន; (៦) អនុវត្តផែនការរយៈពេលវែងសម្រាប់ SBM; (៧) ធ្វើវង្វាយតម្លៃសិស្សជាប្រចាំសម្រាប់ការសិក្សា & លទ្ធផលសិក្សា។

**ការកំណត់សមាជិកភាពគណៈកម្មការគ្រប់គ្រងសាលារៀន៖** សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀនត្រូវជ្រើសរើសតាមរយៈដំណើរការបោះឆ្នោតមួយ ដែលរៀបចំឡើងដោយនាយកសាលារៀន និងអាជ្ញាធរពាក់ព័ន្ធ (ឧ. អាជ្ញាធរឃុំ-សង្កាត់ អាជ្ញាធរស្រុក-ខ័ណ្ឌ)។ យោងតាមគោលនយោបាយរដ្ឋាភិបាលអាណត្តិរបស់សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀនគឺមួយឆ្នាំ។ មានន័យថាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀនត្រូវជ្រើសរើសមួយឆ្នាំម្តង។ រចនាសម្ព័ន្ធ/តួនាទី/សមាសភាពនៃគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានសន្មត់ដូចតទៅនេះ។

| ទំហំនៃសាលារៀន | ចំនួនសមាជិកគណៈកម្មការគ្រប់គ្រង | មុខតំណែង | |
|---|---|---|---|
| សាលារៀនទំហំតូច | ៥ រូប | - ប្រធាន ១ រូប<br>- អនុប្រធាន ១ រូប<br>- គណនេយ្យករ ១ រូប | - បេឡាករ ១ រូប<br>- លេខាធិកា ១ រូប |
| សាលារៀនទំហំមធ្យម | ៧ រូប | - ប្រធាន ១ រូប<br>- អនុប្រធាន ២ រូប<br>- គណនេយ្យករ ១ រូប | - បេឡាករ ១ រូប<br>- លេខាធិកា ១ រូប<br>- សមាជិក ១ រូប |
| សាលារៀនទំហំធំ | ៩ រូប | - ប្រធាន ១ រូប<br>- អនុប្រធាន ២ រូប<br>- គណនេយ្យករ ១ រូប | - បេឡាករ ១ រូប<br>- លេខាធិកា ១ រូប<br>- សមាជិក ៣ រូប |

[2] ដកស្រង់ចេញពី Dr. Hang Chuon Naron, (2017) *Education Reform for Enhancing Quality Citizenship*។

**ការទទួលស្គាល់គណៈកម្មការគ្រប់គ្រងសាលារៀនជាផ្លូវការៈ** គណៈកម្មការគ្រប់គ្រងសាលារៀនក្នុងនាមជាក្រុមមួយដែលមានសមាជិកជាបុគ្គលិករបស់ខ្លួន ត្រូវតែមានការទទួលស្គាល់ជាផ្លូវការពីអាជ្ញាធរ។ គណៈកម្មការគ្រប់គ្រងសាលារៀនសម្រាប់សាលារៀនអនុវិទ្យាល័យ គួរទទួលស្គាល់ជាផ្លូវការពីអាជ្ញាធរថ្នាក់ឃុំ ឬសង្កាត់។ គណៈកម្មការគ្រប់គ្រងសម្រាប់សាលារៀនវិទ្យាល័យគួរទទួលស្គាល់ជាផ្លូវការពីអាជ្ញាធរថ្នាក់ស្រុក ក្រុង ឬខ័ណ្ឌ។

## ទំនួលខុសត្រូវលម្អិតនៃគណៈកម្មការគ្រប់គ្រងសាលារៀន

### *1. បង្កើនស្វ័យភាព & គណនេយ្យភាពហិរញ្ញវត្ថុរបស់សាលារៀនដើម្បីការអប់រំប្រកបដោយគុណភាព*

ក. គណៈកម្មការគ្រប់គ្រងសាលារៀន នឹងត្រូវបានបង្កើតឡើងដើម្បីអនុវត្តតាមគោលការណ៍ទាំងឡាយ (សូមមើលខាងក្រោម) ដែលទាក់ទងនឹងតួនាទី និងទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងសាលារៀន មាតាបិតា និងសមាជិកសហគមន៍ អំពីការគ្រប់គ្រងសាលារៀន។

ខ. គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័តផែនការអភិវឌ្ឍន៍សាលារៀន និងដាក់ជូនសំណើសុំបើកថវិកា SIP និងទទួលខុសត្រូវក្នុងការមើលការខុសត្រូវលើការអនុវត្តរបស់ខ្លួន។

គ. សាលារៀនរៀបចំគោលការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក រង្វាយតម្លៃគ្រូបង្រៀន ការជួល និងការបណ្តេញបុគ្គលិក ការពិនិត្យតាមដាន & វាយតម្លៃ (M&E)។

ឃ. ណែនាំឱ្យស្គាល់នូវប្រព័ន្ធគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ដោយអនុលោមតាមគោលការណ៍អភិបាលកិច្ចល្អ ជានានូវភាពសក្តិសិទ្ធិ និងប្រសិទ្ធភាព និងសម្រេចបាននូវវឌ្ឍនភាពដែលជាក់ស្តែងនៃលទ្ធផលសិក្សារបស់សិស្ស។

ង. សាលារៀនត្រូវផ្តល់តួនាទីសំខាន់ៗជូនគ្រូបង្រៀន សហគមន៍ អាជ្ញាធរ មាតាបិតា និងសិស្សានុសិស្សក្នុងការចូលរួមនៅក្នុងដំណើរការរៀបចំផែនការ និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន។

### *2. ធ្វើសវនកម្មថវិកាអប់រំដើម្បីការអប់រំប្រកបដោយគុណភាព*

ក. នាយកសាលារៀនប្រើថវិកា ដែលបានមកពីគ្រប់ប្រភពនានាទាំងអស់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន និងសម្រាប់ការកែលម្អវិធីបង្រៀន ដែលបានរៀបចំឡើងដើម្បីលើកកម្ពស់ការគោរពភាពចម្រុះ និងគុណតម្លៃរបស់មនុស្ស។

ខ. ពង្រឹងជំនាញគ្រប់គ្រងហិរញ្ញវត្ថុ អភិវឌ្ឍ និងរក្សាបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលច្បាស់លាស់។

គ. លើកកម្ពស់គណនេយ្យភាពសម្រាប់ការគ្រប់គ្រង និងការត្រួតពិនិត្យការប្រើប្រាស់ធនធាន តម្លាភាព សន្តិសុខ ភាពអាចទុកចិត្តបាន និងតម្លាភាព។

ឃ. បង្កើតនូវប្រអប់សំបុត្រតម្លាភាពមួយ ដើម្បីទទួលបានព័ត៌មាន ឬការតវ៉ាបណ្តឹងផ្សេងៗពីអ្នកពាក់ព័ន្ធ។

ង. ពង្រឹងប្រព័ន្ធអធិការកិច្ចផ្ទៃក្នុង ដោយផ្អែកលើស្វ័យវាយតម្លៃសាលារៀន និងការត្រួតពិនិត្យជាប្រចាំ។

ច. នាយកសាលារៀនកែលម្អការអនុវត្តការងាររបស់សាលារៀនជាមួយនឹងលទ្ធផលផ្ទៃក្រៅ និងដោះស្រាយលទ្ធផលសវនកម្ម។

### *3. ផ្សារភ្ជាប់ថវិកាជាមួយនឹងគោលនយោបាយអប់រំដើម្បីការអប់រំប្រកបដោយគុណភាព*

ក. នាយកសាលារៀន និងគ្រូបង្រៀនគួរខិតខំប្រឹងប្រែងក្នុងការអប់រំសិស្សឱ្យចេះគោរពបទបញ្ញាផ្ទៃក្នុងសាលារៀន កាលវិភាគ និងបង្រៀនអំពីសារៈសំខាន់នៃការគោរពច្បាប់ និងសណ្តាប់ធ្នាប់សង្គមតាមបច្ចេកទេសគ្រប់គ្រងផ្ទាល់ខ្លួន។

ខ. សាលារៀនណែនាំឱ្យស្គាល់អំពីផែនការថវិកា ដោយកំណត់អំពីចំនួនទឹកប្រាក់ដែលត្រូវការដើម្បីអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនយោងទៅតាមកាលវិភាគជាក់លាក់។

គ. គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន (SIP) ដោយត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពជាក់ស្តែង។

ឃ. សាលារៀនប្រើថវិកាអភិវឌ្ឍន៍សាលារៀន (SIP) សម្រាប់សកម្មភាពទាំងឡាយដូចជា៖

- បង្កើនការប្រើប្រាស់សម្ភារ និងបរិយាកាសសិក្សាល្អប្រសើរតាមរយៈសម្ភារ និងបរិក្ខា និងការគាំទ្រដល់សម្ភារបង្រៀន និងរៀន និងសកម្មភាពបង្រៀន។
- ពង្រឹងសមត្ថភាពគ្រូបង្រៀន។
- ជួយសម្រួលដល់កុមារងាយរងគ្រោះ សិស្សរៀនយឺត និងសិស្សដែលនឹងបោះបង់ការសិក្សា។
- បង្កើនអត្រាចុះឈ្មោះចូលរៀន អត្រាឆ្លងភូមិសិក្សា និងអត្រាបញ្ចប់ការសិក្សាគ្រប់កម្រិតថ្នាក់។

ង. ផ្តល់សេវាថែទាំសុខភាពដល់សិស្សគ្រប់កម្រិតថ្នាក់ទាំងអស់ (ការថែទាំសុខភាព សុវត្ថិភាពចំណីអាហារ និងហានិភ័យផ្សេងៗ)។

### *4. ធានានូវការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀនដើម្បីការអប់រំប្រកបដោយគុណភាព*

ក. គណៈកម្មការគ្រប់គ្រងសាលារៀនរៀបចំ និងអនុវត្តតាមផែនការអភិវឌ្ឍន៍សាលារៀនដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ រួមទាំងក្រុមប្រឹក្សាកុមារផងដែរ។

ខ. គណៈកម្មការគ្រប់គ្រងសាលារៀនពិនិត្យទៅលើការអនុវត្តការងារ និងតម្លាភាពរបស់សាលារៀន។

### *5. អនុវត្តការគ្រប់គ្រងតាមសាលារៀនដើម្បីការអប់រំប្រកបដោយគុណភាព*

ក. គណៈកម្មការគ្រប់គ្រងសាលារៀនផ្តល់ការគាំទ្រដល់ការបង្រៀន និងរៀន ក៏ដូចជាការកៀរគរធនធាន និងរៀបចំរបាយការណ៍វាយតម្លៃសាលារៀនផងដែរ។

ខ. គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័តលើសូចនាករ និងចំណុចដៅលទ្ធផលរយៈពេល ៣ ឆ្នាំរបស់សាលារៀន ផែនការអភិវឌ្ឍន៍សាលារៀន និងថវិកាប្រចាំឆ្នាំ ផ្តល់ការពិនិត្យទៅលើការវាយតម្លៃការបំពេញការងាររបស់សាលារៀនធៀបជាមួយនឹងស្តង់ដាប្រសិទ្ធភាពសាលារៀន និងគាំទ្រ ព្រមទាំងចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងការអង្គាសមូលនិធិសាលារៀន។

គ. គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័តរង្វាន់លើកទឹកចិត្តសម្រាប់បុគ្គលិកឆ្នើម ធ្វើការស្នើសុំវិធានការរដ្ឋបាលចំពោះបុគ្គលិកដែលមិនបំពេញការងារទៅកាន់ថ្នាក់ក្រោមជាតិ/ថ្នាក់ជាតិ អនុម័តរង្វាន់លើកទឹកចិត្តសម្រាប់ការបំពេញការងារបានល្អបំផុតរបស់នាយកសាលារៀន។

ឃ. គណៈកម្មការគ្រប់គ្រងសាលារៀនអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងរាយការណ៍អំពីវឌ្ឍនភាព។

### *6. អនុវត្តផែនការរយៈពេលវែងសម្រាប់ការគ្រប់គ្រងតាមសាលារៀន*

ក. នាយកសាលារៀនបង្កើតផែនការអភិវឌ្ឍន៍សាលារៀនរយៈពេលបីឆ្នាំវិលជុំ និងផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ ដោយកំណត់នូវសូចនាករធាតុចូល ធាតុចេញ និងផលសម្រេចបានរបស់សាលារៀនក៏ដូចជាប្រភពហិរញ្ញវត្ថុ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។

ខ. នាយកសាលារៀនជួយ សម្របសម្រួលដល់ការបង្កើត និងការដាក់ស្នើសូចនាករ និងចំណុចដៅផលសម្រេចរយៈពេល ៣ ឆ្នាំរបស់សាលារៀន និងផែនការអភិវឌ្ឍន៍សាលារៀន និងថវិកាប្រចាំឆ្នាំ។
គ. នាយកសាលារៀនដាក់ជូនលទ្ធផលនៃការវាយតម្លៃការបំពេញការងាររបស់សាលារៀនធៀបជាមួយនឹងស្តង់ដាប្រសិទ្ធភាពសាលារៀនជូនគណៈកម្មការគ្រប់គ្រងសាលារៀន។
ឃ. នាយកសាលារៀនចាត់ចែង ជួយ និងសម្របសម្រួលដល់គ្រប់សកម្មភាពអែអង្គាសមូលនិធិទាំងអស់របស់សាលារៀន។
ង. សាលារៀនប្រមូលទិន្នន័យ និងព័ត៌មានដាក់ស្តែងពីវាយតម្លៃសិស្ស វាយតម្លៃសមត្ថភាពគ្រូបង្រៀន វាយតម្លៃការបំពេញការងាររបស់សាលារៀន។
ច. សាលារៀនបង្កើតនូវវប្បធម៌ចែករំលែកព័ត៌មានមួយ ដោយកំណត់បញ្ហារួមគ្នាជាមួយគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ដើម្បីលើកកម្ពស់ការជឿទុកចិត្តមកលើសាលារៀនពីសហគមន៍ ការជឿទុកចិត្តក្នុងចំណោមបុគ្គលិកសាលារៀន និងជាពិសេសការជឿទុកចិត្តរបស់មាតាបិតាសិស្សមកលើគ្រូបង្រៀន។
ឆ. សាលារៀនរៀបចំផែនការ ថវិកា របាយការណ៍ និងរៀបចំការបំពេញការងាររបស់បុគ្គលិក។
ជ. សាលារៀនអនុវត្តកម្មវិធីសិក្សាតាមកម្មវិធីសិក្សាដែលបានណែនាំ និងកម្មវិធីសិក្សាបន្ថែម។
ឈ. នាយកសាលារៀនធ្វើប្រព័ន្ធគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក និងស្នើសុំការផ្តល់រង្វាន់លើកទឹកចិត្តជូនបុគ្គលិកដែលបំពេញការងារបានល្អបំផុត ក៏ដូចជាស្នើសុំវិធានការរដ្ឋបាលចំពោះបុគ្គលិកដែលមិនបំពេញការងារ។

### *7. ធ្វើវាយតម្លៃសិស្សជាប្រចាំសម្រាប់ការសិក្សា & សមិទ្ធផលសិក្សា*

ក. នាយកសាលារៀនជួយ និងសម្របសម្រួលដល់ការវាយតម្លៃការបំពេញការងាររបស់សាលារៀន ធៀបជាមួយនឹងស្តង់ដាប្រសិទ្ធភាពសាលារៀន។
ខ. នាយកសាលារៀនចងក្រងទិន្នន័យ និងព័ត៌មាន ព្រមទាំងបង្កើត និងដាក់ជូនរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសស្តីពីវាយតម្លៃ។
គ. នាយកសាលារៀនចងក្រងទិន្នន័យ និងព័ត៌មាន បង្កើត និងដាក់ជូនរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការសម្រេចបាននូវសូចនាករ និងចំណុចដៅផលសម្រេចរបស់សាលារៀន។
ឃ. ដាក់បញ្ចូលលទ្ធផលនៃការសិក្សារបស់សិស្សចូលទៅក្នុងរបាយរាយការណ៍សាលារៀន។
ង. គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័តលទ្ធផលដែលបានពីការវាយតម្លៃការបំពេញការងាររបស់សាលារៀនរៀន និងចារនៅលើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការសម្រេចបាននូវសូចនាករ និងចំណុចដៅផលសម្រេចរបស់សាលារៀនដែលទាក់ទងនឹងលទ្ធផលការសិក្សារបស់សិស្ស។

## ឯកសារទី១០៖ ការផ្ទៀងផ្ទាត់បញ្ហា និងមុខងាររបស់គណៈកម្មការគ្រប់គ្រងសាលារៀនដែលត្រូវដោះស្រាយបញ្ហា

**សេចក្តីណែនាំ៖** ចូរអានមុខងារសំខាន់ៗនីមួយៗដែលគណៈកម្មការគ្រប់គ្រងសាលារៀនគួរបំពេញ។ បន្ទាប់មកឆ្លុះបញ្ចាំងបញ្ហាមួយចំនួនដែលគណៈកម្មការនោះត្រូវដោះស្រាយតាមរយៈមុខងារទាំងនេះ។ ចូរសរសេរយ៉ាងតិច**មួយ** បញ្ហាក្នុងមួយមុខងារនៅក្នុងចន្លោះដែលមានផ្តល់ជូនខាងក្រោម។ មានឧទាហរណ៍គំរូមួយសម្រាប់អ្នកផងដែរ។

### *1. បង្កើនស្វ័យភាព & គណនេយ្យភាពហិរញ្ញវត្ថុរបស់សាលារៀន*

***បញ្ហាដែលត្រូវដោះស្រាយ៖*** សាលារៀនពុំបានដឹងពីបញ្ហាទាំងឡាយនៅក្នុងសាលារៀនរបស់ខ្លួន ហើយក៏ពុំមានផែនការច្បាស់លាស់សម្រាប់ដោះស្រាយវាដែរ។ (ឧទាហរណ៍)

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________

______________________________________________________________________

### *2. ធ្វើសវនកម្មថវិកាអប់រំ*

***បញ្ហាដែលត្រូវដោះស្រាយ៖*** សហគមន៍ពុំផ្តល់ការគាំទ្របន្ថែមដល់សាលារៀន ពីព្រោះពួកគេពុំដឹងថាសាលារៀននឹងប្រើថវិកាសម្រាប់អ្វីខ្លះឱ្យប្រាកដ ហើយក៏ពុំដឹងប្រាកដថាតើសាលារៀននោះនឹងពិតជាមានផលជះទៅលើសេវាអប់រំដែរឬយ៉ាងណាទេ។ (ឧទាហរណ៍)

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________

______________________________________________________________________

### *3. ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអប់រំ*

***បញ្ហាដែលត្រូវដោះស្រាយ៖*** សាលារៀនពុំដឹងថាតើសកម្មភាពណាមួយដែលខ្លួនបានធ្វើ ពិតជាធ្វើឱ្យសេវាអប់រំប្រសើរឡើងឬយ៉ាងណាទេ ពីព្រោះសាលារៀនពុំធ្លាប់បានមើលទិន្នន័យជាលក្ខណៈប្រព័ន្ធដើម្បីវាយតម្លៃភាពជោគជ័យឡើយ។ (ឧទាហរណ៍)

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________

______________________________________________________________________

### *4. ធានាការចូលរួមពីសហគមន៍នៅក្នុងការសម្របសម្រួលសាលារៀន*

***បញ្ហាដែលត្រូវដោះស្រាយ៖*** សហគមន៍ពុំជឿទុកចិត្តសាលារៀន ដូច្នេះហើយទើបសហគមន៍ពុំផ្តល់អាទិភាពលើការចូលរួមក្នុងសកម្មភាពនានារបស់សាលារៀនឡើយ។ (ឧទាហរណ៍)

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________

______________________________________________________________________

### *5. អនុវត្តការសម្របសម្រួលតាមសាលារៀន*

***បញ្ហាដែលត្រូវដោះស្រាយ៖*** <u>សាលារៀនកម្រនឹងពិចារណាអំពីចំណុចដៅ ឬសូចនាករដាក់លាក់ដែលត្រូវតាមដានផែនការរបស់ខ្លួនណាស់។</u> ( ឧទាហរណ៍ )

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________________

______________________________________________________________________________

### *6. អនុវត្តផែនការរយៈពេលវែងសម្រាប់ការសម្របសម្រួលតាមសាលារៀន*

***បញ្ហាដែលត្រូវដោះស្រាយ៖*** <u>សាលារៀនពុំពិចារណាអំពីផែនការ ឬដំណោះស្រាយរយៈពេលវែង។</u> ( ឧទាហរណ៍ )

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________________

______________________________________________________________________________

### *7. ធ្វើវង្វាយតម្លៃសិស្សជាប្រចាំ*

***បញ្ហាដែលត្រូវដោះស្រាយ៖*** <u>សាលារៀនពុំរៀបចំវង្វាយតម្លៃច្បាស់លាស់ទៅលើការសិក្សារបស់សិស្សដើម្បីកំណត់អំពីស្ថានភាពជាក់ស្តែងនៃការរៀនសូត្រនៅក្នុងសាលារៀននោះឡើយ។</u> ( ឧទាហរណ៍ )

***បញ្ហាដែលត្រូវដោះស្រាយ៖***

______________________________________________________________________________

______________________________________________________________________________

## ឯកសារទី ១១៖ ករណីសិក្សាដើម្បីលើកកម្ពស់ការដោះស្រាយបញ្ហា

**សេចក្តីណែនាំ៖** គណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានបង្កើតឡើងដើម្បីបង្កើនគណនេយ្យភាពរបស់សាលារៀនក្នុងន័យជួយដល់ការសម្របសម្រួលសាលារៀន ការអប់រំបរិយាបន្ន និងគុណភាពនៃការអប់រំ។ ចូរពិនិត្យឡើងវិញទៅលើបញ្ហាទាំងឡាយដែលបានរកឃើញនៅខាងក្រោមនេះ រួចហើយកំណត់នូវវិធានការមួយចំនួនដែលគណៈកម្មការគ្រប់គ្រងអាចពិចារណាដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលបានរកឃើញ។ នៅពេលកំណត់អំពីវិធានការដែលត្រូវចាត់ធ្វើ ចូរព្យាយាមធ្វើឱ្យបានជាក់លាក់តាមដែលអ្នកអាចធ្វើបាន។ ចូរធ្វើសកម្មភាពនេះជា**ក្រុមតូចៗ**។

| បញ្ហា | ដំណោះស្រាយ |
|---|---|
| 1. ក្រោយពេលប្រកាសលទ្ធផលប្រឡងបាក់ឌុប នាយកសាលារៀនបានជម្រាបដល់គណៈកម្មការគ្រប់គ្រងសាលារៀនថា ពុំមានភាពប្រសើរឡើងចំពោះលទ្ធផលសិក្សារបស់សិស្សលើសពីឆ្នាំមុនឡើយ។ | ______ |
| 2. អ្នកមើលថែសាលារៀន ដែលទទួលបន្ទុកជានានូវការថែទាំហេដ្ឋារចនាសម្ព័ន្ធ មិនដែលមកធ្វើការឱ្យបានទៀងទាត់ ហើយក៏មិនបានថែទាំអគារសិក្សា ឬទីធ្លាសាលារៀនឡើយ។ | ______ |
| 3. គណៈកម្មការគ្រប់គ្រងទទួលបានដំណឹងថា គ្រូបង្រៀនភាគច្រើនពុំបានប្រើបន្ទប់វិទ្យាសាស្ត្រដែលបានផ្តល់ជូននៅក្នុងមណ្ឌលធនធាន ហើយរាល់សម្ភារទាំងអស់ពុំទាន់មានការប្រើប្រាស់នៅឡើយ។ | ______ |
| 4. ហិរញ្ញិកបានរាយការណ៍ថា មូលនិធិដែលបានផ្តល់ជូនសម្រាប់ជាជំនួយសាលារៀន ពុំទាន់ត្រូវបានចំណាយ ហើយឆ្នាំសិក្សានឹងបញ្ចប់ក្នុងពេលដ៏ឆាប់បំផុត។ | ______ |

## ឯកសារទី១២៖ ទំនាក់ទំនងរវាងគណៈកម្មការគ្រប់គ្រងសាលារៀន និង ផែនការអភិវឌ្ឍន៍សាលារៀន

### មានសកម្មភាពសំខាន់ៗចំនួន ៥ សម្រាប់ឱ្យគណៈកម្មការគ្រប់គ្រងសាលារៀនធ្វើ ដែលទាក់ទងនឹងផែនការអភិវឌ្ឍន៍សាលារៀនគឺ៖

(១) វាយតម្លៃស្ថានភាពនៅសាលារៀន ដើម្បីឱ្យដឹងថាតើសាលារៀនមានលក្ខណៈអំណោយផលដល់សិស្សានុសិស្សក្នុងការទទួលបាននូវការអប់រំប្រកបដោយគុណភាពដែរឬទេ។

(២) ចូលរួមនៅក្នុងការបង្កើតផែនការអភិវឌ្ឍន៍សាលារៀនដោយផ្អែកលើវង្វាយតម្លៃរបស់ខ្លួន។

(៣) ធ្វើការអង្គាសមូលនិធិសម្រាប់ជាមូលនិធិបន្ថែមដើម្បីទ្រទ្រង់ដល់ផែនការអភិវឌ្ឍន៍សាលារៀនទៅតាមការចាំបាច់។

(៤) ចូលរួមនៅក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនព្រមទាំងកៀគរសមាជិកសហគមន៍ដទៃទៀតឱ្យចូលរួមផងដែរ។

(៥) វាយតម្លៃវឌ្ឍនភាពនៃផែនការអភិវឌ្ឍន៍សាលារៀននៅចុងឆ្នាំសិក្សា។

សកម្មភាពទាំងនេះកើតឡើងជាវដ្តប្រចាំឆ្នាំ ដែលមានន័យថា ត្រូវតែធ្វើសកម្មភាពទាំងនេះមួយឆ្នាំម្តង។ ការចាប់ផ្តើមឆ្នាំថ្មី គួរតែចាប់ផ្តើមជាមួយនឹងវង្វាយតម្លៃស្ថានភាពរបស់សាលារៀន។ ពីមួយឆ្នាំទៅមួយឆ្នាំ វង្វាយតម្លៃប្រចាំឆ្នាំគួរតែបង្ហាញឱ្យឃើញពីភាពប្រសើរឡើងនៅក្នុងសាលារៀន និងគុណភាពនៃការអប់រំ។ ដូចដែលបានលើកឡើងពីខាងដើម គណៈកម្មការគ្រប់គ្រងសាលារៀន ទទួលខុសត្រូវក្នុងការធ្វើឱ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនៅតាមសាលារៀន និងសមាជិកសហគមន៍ឱ្យបានទូលំទូលាយនៅក្នុងដំណើរការវាយតម្លៃ រៀបចំផែនការ និងការអនុវត្ត។

### ការកំណត់និយមន័យផែនការអភិវឌ្ឍន៍សាលារៀន (SIP) [3]

**គោលបំណងនៃដំណើរការ SIP ៖** ដើម្បីធានាថាអ្នកពាក់ព័ន្ធទាំងអស់នៅសាលារៀន និងនៅក្នុងសហគមន៍មានតំណាងទូលំទូលាយអំឡុងពេលបង្កើត និងពេលអនុវត្តផែនការ ដើម្បីកែលម្អសេវាអប់រំ។

**តើផែនការអភិវឌ្ឍន៍សាលារៀន (SIP) គឺជាអ្វី?** SIP គឺជាឯកសារផ្លូវការមួយដែលបានមកពីការឯកភាពគ្នារវាងសាលារៀន និងសហគមន៍ទៅលើសកម្មភាពជាអាទិភាពមួយចំនួន ដែលបានរកឃើញរួមគ្នាតាមរយៈការវិភាគដោយប្រុងប្រយ័ត្នទៅលើស្ថានភាព និងបញ្ហាប្រឈមនានាក្នុងមូលដ្ឋានចំពោះការសិក្សា។ SIP គឺជាសេចក្តីថ្លែងការណ៍អំពីការប្តេជ្ញាចិត្តធ្វើការរួមគ្នា ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមដែលបានរកឃើញ និងដើម្បីធានាថា សិស្សានុសិស្សទាំងអស់ទៅសិក្សានៅសាលារៀន និងទទួលបានចំណេះដឹង និងបំណិនជីវិតដែលត្រូវការដើម្បីជីវិតជោគជ័យ។[4]

[3] កែសម្រួលពីឯកសារគាំទ្រផែនការកែលម្អសាលារៀនឆ្នាំ ២០១៨ នៃគម្រោង SEIP ទំព័រទី ៤

[4] Ibid, p.

**បុគ្គលដែលគួរចូលរួមក្នុងការបង្កើតផែនការអភិវឌ្ឍន៍សាលារៀនមានដូចជា៖** អាជ្ញាធរសាលារៀន គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរសហគមន៍ នគរបាល ព្រះសង្ឃ បុគ្គលិកមណ្ឌលសុខភាព កុមារ / សិស្ស[5] មាតាបិតា និងសមាជិកសហគមន៍ទូទៅ។

**តើនរណាជាអ្នកអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន?** ទំនួលខុសត្រូវចំពោះការអនុវត្ត SIP អាស្រ័យទៅលើសកម្មភាពអ្វីមួយដែលកំពុងត្រូវបានអនុវត្ត។ ជាធម្មតា មានបុគ្គលម្នាក់ដែលត្រូវទទួលខុសត្រូវរួមក្នុងការធានាថា បានធ្វើសកម្មភាពចប់សព្វគ្រប់ ប៉ុន្តែមានបុគ្គលជាច្រើនរូបទៀតដែលចូលរួមពាក់ព័ន្ធជាក់ស្តែងនៅក្នុងការអនុវត្តសកម្មភាពនោះ។ ឧទាហរណ៍ ប្រសិនបើ "ការសាងសង់អគារបង្គន់អនាម័យមួយ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងឡាយនៅក្នុងផែនការនោះ វាទំនងជានឹងត្រូវធ្វើដោយក្រុមហ៊ុនសំណង់ ប៉ុន្តែស្ថិតក្រោមការមើលការខុសត្រូវរបស់នាយកសាលារៀន និង/ឬគណៈគ្រប់គ្រងសាលារៀន ឬអ្នកទទួលការចាត់តាំងពីគណៈកម្មការគ្រប់គ្រងសាលារៀន។ ចំពោះសកម្មភាពទាំងឡាយនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលត្រូវការថវិកា ហិរញ្ញិកនៃគណៈកម្មការគ្រប់គ្រងសាលារៀនត្រូវតែចូលរួមពាក់ព័ន្ធនៅក្នុងការគ្រប់គ្រង និងគិតគូរថវិកាដោយផ្អែកទៅលើប្រភពនៃថវិកានោះ។

[5] កុមារមិនគួរចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពរៀបចំផែនការជាមួយនឹងមនុស្សពេញវ័យឡើយ។ សាលារៀនគួរតែរៀបចំការប្រជុំដាច់ដោយឡែកដោយមានការចូលរួមពីកុមារតែប៉ុណ្ណោះ ដែលពួកគេអាចសម្តែងមតិផ្ទាល់ខ្លួនបានដោយសេរីច្រើនជាង តាមរយៈរូបភាព បណ្ណប្រកាស និងទម្រង់នៃការប្រាស្រ័យទាក់ទងផ្សេងៗ ដែលមនុស្សពេញវ័យអាចពិនិត្យមើលឡើងវិញដាច់ដោយឡែកពីគ្នា។

## ឯកសារទី១៣៖ ការឱ្យនិយមន័យដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

### លំហាត់

**សេចក្តីណែនាំ៖** ចូរអានសំណួរនីមួយៗខាងក្រោមរួចហើយផ្អែកតាមការយល់របស់អ្នកពេលនេះ សូមជ្រើសរើសចម្លើយដែលសមស្របបំផុត។ សូមត្រៀមខ្លួនពិភាក្សាអំពីជម្រើសចម្លើយរបស់អ្នកជាមួយនឹងក្រុមដទៃទៀត។

| | | |
|---|---|---|
| **សំណួរទី ១៖** តើដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមានគោលបំណងអ្វី? | | |
| ក) ដើម្បីធានាថា មានការចូលរួមពីអ្នកពាក់ព័ន្ធយ៉ាងទូលំទូលាយ (ឧ. សហគមន៍ គ្រូបង្រៀន មាតាបិតា ។ល។) ដែលជាអ្នកទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍សាលារៀនដើម្បីជាប្រយោជន៍របស់គ្រួសារទាំងឡាយនៅក្នុងមូលដ្ឋាន សហគមន៍ និងជាការរួមចំណែកចំពោះវត្ថុបំណងនៃការអភិវឌ្ឍជាតិផងដែរ។ | ខ) ដើម្បីបង្កើតនូវដំណើរការមួយដែលប្រគល់អំណាចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយធានាថា ធនធានហូរចូលទៅក្នុងសាលារៀនជាទៀងទាត់ ហើយអំណោយផលដល់សាលារៀនក្នុងការកែលម្អដំណើរការរបស់ខ្លួនយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាព។ | គ) ដើម្បីបង្កើតនូវគម្រោងពេលវេលាលម្អិតនៃសកម្មភាពសំខាន់ៗទាំងអស់ ដែលត្រូវធ្វើនៅសាលារៀនរៀន ដូចជា ការបង្ហូតទង់ជាតិ ការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ និងសកម្មភាពសំខាន់ៗផ្សេងទៀត ដែលអាចមានផលជះទៅលើការចុះឈ្មោះចូលរៀន និងការរៀនសូត្រនៅសាលារៀន។ |
| **សំណួរទី ២៖** តើផែនការអភិវឌ្ឍន៍សាលារៀន (SIP) គឺជាអ្វី? | | |
| ក) SIP គឺជាការវិភាគលម្អិតមួយអំពីពល់បញ្ហាទាំងអស់ដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សារៀនសូត្រនៅសាលារៀន អ្នកដែលទទួលបន្ទុកដោះស្រាយបញ្ហានោះ និងរបៀបដែលបញ្ហាទាំងនេះប៉ះពាល់លើសាលារៀន។ | ខ) SIP គឺជាផែនការការងារលម្អិតមួយដែលបញ្ជាក់ច្បាស់លាស់អំពីពេលដែលសកម្មភាពសំខាន់ៗនៅក្នុងសាលារៀនគួរធ្វើ ដូចជា ការបង្ហូតទង់ជាតិ ការបោសសម្អាតថ្នាក់រៀន និងសកម្មភាពសំខាន់ៗផ្សេងទៀត ក៏ដូចជាអ្នកដែលត្រូវទទួលខុសត្រូវចំពោះសកម្មភាពនីមួយៗ ព្រមទាំងចំនួនថវិកាដែលត្រូវការសម្រាប់ធ្វើវា។ | គ) SIP គឺជាឯកសារផ្លូវការមួយដែលបានមកពីការឯកភាពគ្នារវាងសាលារៀន និងសហគមន៍ទៅលើបញ្ហា និងដំណោះស្រាយអាទិភាពមួយចំនួន ដែលបានរកឃើញរួមគ្នាតាមរយៈការវិភាគដោយប្រុងប្រយ័ត្នទៅលើស្ថានភាព និងបញ្ហាប្រឈមនានាក្នុងមូលដ្ឋានចំពោះការសិក្សា។ |
| **សំណួរទី ៣៖** តើនរណាខ្លះគួរតែចូលរួមនៅក្នុងការបង្កើតផែនការអភិវឌ្ឍន៍សាលារៀន? | | |
| ក) ចម្បងជាងគេគឺ អ្នកគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ដោយមានអ្នកតំណាងមួយចំនួនមកពីសហគមន៍។ | ខ) ចម្បងជាងគេគឺ សមាជិកនៃគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ក៏ដូចជាសមាជិកសហគមន៍ដ៏ទូលំ | គ) ចម្បងជាងគេគឺ មន្ត្រីដែលមកពីការិយាល័យអប់រំស្រុក ក៏ដូចជានាយកសាលារៀន និងប្រធានក្រុមបច្ចេកទេសផងដែរ។ |

| | | |
|---|---|---|
| | ទូលាយ ដូចជា មេភូមិ មេឃុំ ឬចៅសង្កាត់។ល។ | |
| **សំណួរទី ៤៖ តើនរណាខ្លះគួរអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន?** | | |
| ក) ទំនួលខុសត្រូវក្នុងការអនុវត្ត SIP អាស្រ័យទៅលើសកម្មភាពអ្វីមួយដែលត្រូវអនុវត្ត។ ជាធម្មតាមានបុគ្គលម្នាក់ ដែលត្រូវបានចាត់តាំងដើម្បីឱ្យមានទំនួលខុសត្រូវរួមក្នុងការធានាថាបានធ្វើសកម្មភាពនោះ ប៉ុន្តែមានមនុស្សដទៃជាច្រើននាក់ទៀតដែលចូលរួមនៅក្នុងការអនុវត្តសកម្មភាពនោះជាក់ស្តែង។ | ខ) ទំនួលខុសត្រូវគួរតែចែករំលែកគ្នានៅក្នុងក្រុម យោងទៅតាមផ្នែកនៃជំនាញឯកទេស ប៉ុន្តែកិច្ចការជាក់ស្តែងនៃការអនុវត្តន៍ភាគច្រើនតែងតែធ្លាក់ទៅលើនាយកសាលារៀន និងនាយករង ក៏ដូចជាគ្រូបង្រៀនមួយចំនួនតូចផងដែរ។ | គ) សហគមន៍គួរដើរតួនាទីដ៏សកម្មបំផុតនៅក្នុងការអនុវត្ត SIP ដោយកៀរគរមាតាបិតាសិស្សឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីឱ្យកិច្ចការផ្សេងៗជាច្រើនដែលមានបញ្ជាក់នៅក្នុងផែនការអាចបែងចែកគ្នាបានយ៉ាងងាយស្រួលក្នុងចំណោមពួកគេ។ |

## ឯកសារទី១៤កៈ ការវាយតម្លៃចំណេះដឹងរបស់អ្នកអំពីបញ្ញត្តិ និងដំណើរការនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

សេចក្តីណែនាំៈ ចូរអានសំណួរទាំងឡាយខាងក្រោម ដើម្បីទទួលបាននូវគំនិតអំពីទីតាំងរបស់អ្នកលើការយល់ដឹងអំពីបញ្ញត្តិ និងដំណើរការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។ ចូរដាក់ពិន្ទុសម្រាប់ការយល់ដឹងរបស់អ្នកដោយស្មោះត្រង់ ដើម្បីឱ្យអ្នកសម្របសម្រួលអាចដឹងបានយ៉ាងល្អ ថាគាត់ត្រូវតែពន្យល់បកស្រាយ។ បន្ទាប់ពីបានឆ្លើយសំណួរ និងដាក់ពិន្ទុសំណួរនីមួយៗ ចូររាយការណ៍ពិន្ទុសរុបរបស់អ្នកទៅកាន់ប្រធានក្រុមរបស់អ្នក ដើម្បីឱ្យគាត់អាចកំណត់មធ្យមភាគវាជាមួយនឹងពិន្ទុរបស់សមាជិកក្រុមផ្សេងទៀត។

| ល.រ | សំណួរ | ពិន្ទុ |
|---|---|---|
| 1. | តើអ្នកពិពណ៌នាអំពីការយល់ដឹងទូទៅរបស់អ្នកអំពីបញ្ញត្តិនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| 2. | តើអ្នកពិពណ៌នាអំពីការអនុវត្តនូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅសាលារៀន/ខេត្តរបស់អ្នកយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| 3. | តើអ្នកបានឃើញ/អានឯកសារក្របខណ្ឌការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលបានអនុម័តដោយក្រសួងអប់រំហើយឬនៅ?<br>☐ ខ្ញុំបានឃើញវា និងបានអានវា (២)<br>☐ ខ្ញុំបានឃើញវា ប៉ុន្តែមិនបានអានវាទេ (១)<br>☐ ខ្ញុំពុំបានដឹងអំពីឯកសារនេះទេ (០) | |
| 4. | តើអ្នកពិពណ៌នាអំពីការយល់ដឹងរបស់អ្នកអំពីក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនរបស់ក្រសួងអប់រំយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| 5. | តើអ្នកពិពណ៌នាអំពីទំនុកចិត្តរបស់អ្នកក្នុងការរៀបចំប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំតាមសាលារៀន/ខេត្តរបស់អ្នកយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| | **ពិន្ទុសរុប** | |

**ពិន្ទុខ្ពស់បំផុតៈ** ១៤
**ពិន្ទុទាបបំផុតៈ** ៤
**ពិន្ទុមធ្យមៈ** ៩

## ឯកសារទី១៤ខ៖ វាក្យសព្ទ & និយមន័យអំពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (សំណួរ)

តាមគោលវិធីគ្រប់គ្រងសាលារៀន បណ្តាសាលារៀនត្រូវបានផ្តល់នូវសិទ្ធិអំណាចក្នុងការរៀបចំមាតិកានៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ និងស្វ័យអនុវត្តរបស់ខ្លួន។ ទោះជាយ៉ាងណា ដើម្បីធ្វើកិច្ចការនេះប្រកបដោយប្រសិទ្ធភាព អ្នកគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវតែយល់ដឹងឱ្យបានល្អអំពីបញ្ញត្តិ រចនាសម្ព័ន្ធ និងដំណើរការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។

**សេចក្តីណែនាំ៖** ផ្អែកលើចំណេះដឹងរបស់អ្នកអំពីក្របខណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ ចូរផ្គូរផ្គងវាក្យសព្ទដែលផ្តល់ជូនខាងក្រោមជាមួយនឹងនិយមន័យដែលផ្តល់ជូននៅក្នុងតារាងឱ្យបានសមស្រប។

| បញ្ញត្តិ រចនាសម្ព័ន្ធ និងដំណើរការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ | |
|---|---|
| • ប្រព័ន្ធគាំទ្រគរុកោសល្យប្រចាំសាលារៀន | • ស្វ័យវាយតម្លៃគ្រូបង្រៀន |
| • សកម្មភាពវិក្រឹតការគ្រូបង្រៀន (INSET) | • សហគមន៍សិក្សាវិជ្ជាជីវៈ |
| • ក្រុមបច្ចេកទេសគ្រូបង្រៀន | • គន្លងអាជីពគ្រូបង្រៀន |
| • វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ | • ការទទួលស្គាល់កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ |
| • កម្រងស្នាដៃវិជ្ជាជីវៈ | • ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) |
| • គណៈកម្មការសិក្សាវិជ្ជាជីវៈជាប្រចាំតាមសាលារៀន | • ផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ |

| វាក្យសព្ទ | និយមន័យ |
|---|---|
| **បញ្ញត្តិ** | |
| | ការបណ្តុះបណ្តាលឯកទេសយ៉ាងទូលំទូលាយ ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ដើម្បីជួយដល់គ្រូបន្ទុកថ្នាក់ និងនាយកសាលារៀនក្នុងការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង បំណិន សមត្ថភាព និងប្រសិទ្ធភាពវិជ្ជាជីវៈរបស់ខ្លួន។ គោលដៅចុងក្រោយនៃការបណ្តុះបណ្តាលនេះគឺដើម្បីកែលម្អការសិក្សារបស់សិស្សានុសិស្ស។ |
| **រចនាសម្ព័ន្ធរៀបចំ ឬស្ថាប័នដែលគាំទ្រ CPD** | |
| | នេះសំដៅដល់ការដាក់បុគ្គលដែលទទួលបានការបណ្តុះបណ្តាលល្អមួយរូបនៅក្នុងសាលារៀនរៀនជាអចិន្ត្រៃយ៍ ហៅថាគ្រូប្រឹក្សាគរុកោសល្យ ដែលមានតួនាទីចម្បងក្នុងការគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនដទៃទៀត។ តួនាទីរបស់គ្រូប្រឹក្សាគរុកោសល្យនៅក្នុងប្រព័ន្ធនេះខុសប្លែកពីតួនាទីរបស់មន្ត្រីនៃប្រព័ន្ធអប់រំផ្សេងទៀត (ឧ. អធិការអប់រំ ឬនាយកសាលារៀន) ពីព្រោះពួកគេមិនត្រឹមតែផ្តល់ប្រឹក្សាគរុកោសល្យជាផ្លូវការដល់គ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរក្សាការសម្ងាត់នូវរាល់ការសន្ទនាទាំងអស់ ដែលជាផ្នែកមួយនៃ "មិត្តភាពបច្ចេកទេស" ផងដែរ។ |
| | ក្រុមទាំងនេះជាផ្នែកនៃរចនាសម្ព័ន្ធក្រសួងអប់រំផ្លូវការ ដែលគ្រូបង្រៀនជាន់ខ្ពស់មួយរូបទទួលបាននូវតួនាទីដឹកនាំបច្ចេកទេសក្នុងចំណោមគ្រូបង្រៀនដទៃទៀតនៅក្នុងកម្រិតថ្នាក់របស់ |

| | |
|---|---|
| | ខ្លួន (នៅកម្រិតបឋមសិក្សា) ឬមុខវិជ្ជា (នៅកម្រិតមធ្យមសិក្សា)។ តួនាទីរបស់ពួកគេគឺរៀបចំការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ ថ្នាក់និទ្ទស្សន៍ និង សកម្មភាព CPD ផ្សេងៗ។ |
| | នេះគឺជាក្រុមអ្នកអប់រំដែលជួបគ្នាជាប្រចាំ ចែករំលែកជំនាញឯកទេស និងធ្វើការតាមបែបសហការគ្នាដើម្បីកែលម្អបំណិនក្នុងការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្ស។ |
| | នេះសំដៅទៅលើគណៈកម្មការនៅកម្រិតសាលារៀន ដែលរួមមានជាអាទិ៍ដូចជា អ្នកគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមួយចំនួនដែលនឹងត្រូវទទួលខុសត្រូវក្នុងការវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈ រៀបចំសកម្មភាព CPD តាមសាលារៀន ចូលរួមនៅក្នុងសិក្ខាសាលាវិក្រឹតការ (INSET) និងបង្កើតភាពជាដៃគូរជាមួយវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ |
| | បណ្ដាវិទ្យាស្ថាននៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលគ្រូកម្រិតបឋម និងកម្រិតមធ្យមសិក្សាតាមរយៈការបណ្តុះបណ្តាលដំបូង (PRESET) ក៏ដូចជាការគាំទ្រសកម្មភាព CPD តាមរយៈសកម្មភាពវិក្រឹតការ (INSET) ផងដែរ។ |
| **ដំណើរការដែលគាំទ្រ CPD** | |
| | នេះគឺជាដំណើរការបង្កើតការវិនិច្ឆ័យផ្សេងៗអំពីភាពសមរម្យ ឬប្រសិទ្ធភាពនៃចំណេះដឹង ការបំពេញការងារ ជំនឿ ផលិតផល ឬលទ្ធផលផ្ទាល់ខ្លួនរបស់នរណាម្នាក់ ដើម្បីអាចកែលម្អវា ឬធ្វើឱ្យវាប្រសើរឡើងបាន។ |
| | នេះសំដៅទៅលើគន្លងអាជីពផ្សេងៗ ដែលគ្រូបង្រៀនមួយរូបអាចនឹងជ្រើសរើស ខណៈពេលដែលពួកគេអភិវឌ្ឍខ្លួនចេញពីមុខតំណែងជាគ្រូបង្រៀនធម្មតាមួយរូបទៅជាឋានៈមួយខ្ពស់ជាងនេះ។ មានគន្លងបីដែលត្រូវដើរតាម៖ ១) គន្លងការបង្រៀន; ២) គន្លងភាពជាអ្នកដឹកនាំ; និង ៣) គន្លងអ្នកឯកទេសអប់រំ។ |
| | នេះមានន័យថាជាជានាលើសកម្មភាព និងការប្រតិបត្តិទាំងឡាយ ដែលគ្រូបង្រៀនចូលរួមដើម្បីបង្កើនគុណភាពចំណេះដឹងពួកគេ កែលម្អបំណិនក្នុងការបង្រៀនរបស់ពួកគេ និងបង្កលក្ខណៈឱ្យពួកគេមានប្រសិទ្ធភាពលើការងារកាន់តែច្រើនថែមទៀត។ ការធ្វើវិក្រឹតការ (INSET) តែងតែមានរូបភាពជាសិក្ខាសាលារៀន ប៉ុន្តែក៏មានជារូបភាពផ្សេងៗផងដែរ។ |
| | នេះគឺជាដំណើរការមួយ ដែលតាមរយៈនេះគ្រូបង្រៀនអាចទទួលបានក្រេឌីតផ្លូវការសម្រាប់ការចូលរួមវគ្គសិក្ខាសាលារៀនបណ្តុះបណ្តាល នៅពេលដែលអ្នកផ្តល់ការបណ្តុះបណ្តាលគឺជា CPD ដែលទទួលស្គាល់ដោយការិយាល័យគ្រប់គ្រង CPD (CPDMO) នៅរាជធានីភ្នំពេញ។ ក្រេឌីតទាំងនេះ អាចប្រើប្រាស់ដើម្បីវិវឌ្ឍខ្លួនទៅតាមរចនាសម្ព័ន្ធគន្លងអាជីពគ្រូបង្រៀនដែលអនុម័តដោយក្រសួងអប់រំ។ |
| | នេះគឺជាប្រវត្តិរូបគ្រូបង្រៀនមួយរូប ដែលមានសំណុំឯកសារទាំងឡាយដែលបានចងក្រងដោយគ្រូបង្រៀន ដែលរួមមានដូចជា ប្រវត្តិរូបសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព សញ្ញាបត្រ និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាដែលមានគុណវុឌ្ឍ និទ្ទេសពិសេស ឬរង្វាន់ទាំងឡាយដែលគ្រូបង្រៀនទទួលបាន រង្វាយតម្លៃ ផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ និងឯកសារផ្សេងៗទៀតដែលជួយឱ្យគ្រូបង្រៀនតាមដានភស្តុតាងជាឯកសារអំពីការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។ |

| | |
|---|---|
| | ទាំងនេះគឺជាផែនការដែលនឹងត្រូវបង្កើតឡើងដោយបុគ្គលិកនៅកម្រិតសាលារៀន ដែលរៀបរាប់ អំពីរាល់សកម្មភាព CPD ទាំងអស់ដែលបានធ្វើផែនការ និងបានបញ្ចប់សព្វគ្រប់នៅក្នុងឆ្នាំសិក្សាណាមួយ។ ផែនការទាំងនេះនឹងក្លាយទៅជាផ្នែកនៃកម្រងស្នាដៃវិជ្ជាជីវៈមួយដែលអាចត្រូវបានដាក់បញ្ចូលទៅក្នុងប្រវត្តិរូបគ្រូបង្រៀន ហើយនឹងត្រូវប្រើសម្រាប់ការអភិវឌ្ឍអាជីពផ្អែកលើភ័ស្តុតាង និង ជាការផ្តល់រង្វាន់។ |

## ឯកសារ ១៤គ៖ វាក្យសព្ទ & និយមន័យអំពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (ចម្លើយ)

សូមពិនិត្យមើលវាក្យសព្ទ និងនិយមន័យខាងក្រោមដើម្បីដឹងថាតើអ្នកបានផ្គូផ្គងវាក្យសព្ទបានត្រឹមត្រូវជាមួយនឹងនិយមន័យសមស្របដែលបានមកពីលំហាត់ខាងលើនេះដែរឬទេ។ ប្រសិនបើអ្នកកត់សម្គាល់ឃើញកំហុសណាមួយ សូមពិភាក្សាជាមួយសហការីអំពីអ្វីដែលធ្វើឱ្យអ្នកមានការភ័ន្តច្រឡំដែលធ្វើឱ្យការផ្គូផ្គងណាមួយខុស។

### និយមន័យនៃវាក្យសព្ទ CPD [6]

| វាក្យសព្ទ | និយមន័យ |
|---|---|
| **បញ្ញត្តិ** | |
| • ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ការបណ្តុះបណ្តាលឯកទេសយ៉ាងទូលំទូលាយ ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ដើម្បីជួយដល់គ្រូបង្រៀន និងនាយកសាលារៀនក្នុងការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង បំណិន សមត្ថភាព និងប្រសិទ្ធភាពវិជ្ជាជីវៈរបស់ខ្លួន។ គោលដៅចុងក្រោយនៃការបណ្តុះបណ្តាលនេះគឺដើម្បីកែលម្អការសិក្សារបស់សិស្សានុសិស្ស។ |
| **រចនាសម្ព័ន្ធរៀបចំ ឬស្ថាប័នដែលគាំទ្រ CPD** | |
| • ប្រព័ន្ធគាំទ្រប្រឹក្សាគរុកោសល្យតាមសាលារៀន | នេះសំដៅដល់ការដាក់បុគ្គលដែលទទួលបានការបណ្តុះបណ្តាលល្អមួយរូបនៅក្នុងសាលារៀនជាអចិន្ត្រៃយ៍ ហៅថាគ្រូប្រឹក្សាគរុកោសល្យ ដែលមានតួនាទីចម្បងក្នុងការគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនដទៃទៀត។ តួនាទីរបស់គ្រូប្រឹក្សាគរុកោសល្យនៅក្នុងប្រព័ន្ធនេះខុសប្លែកពីតួនាទីរបស់មន្ត្រីនៃប្រព័ន្ធអប់រំផ្សេងទៀត (ឧ. អធិការអប់រំ ឬនាយកសាលារៀន) ពីព្រោះពួកគេមិនត្រឹមតែផ្តល់ប្រឹក្សាគរុកោសល្យជាផ្លូវការដល់គ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរក្សាការសម្ងាត់នូវរាល់ការសន្ទនាទាំងអស់ ដែលជាផ្នែកមួយនៃ "មិត្តភាពបច្ចេកទេស" ផងដែរ។ |
| • ក្រុមបច្ចេកទេសគ្រូបង្រៀន | ក្រុមទាំងនេះជាផ្នែកនៃរចនាសម្ព័ន្ធក្រសួងអប់រំផ្លូវការ ដែលគ្រូបង្រៀនជាន់ខ្ពស់មួយរូបទទួលបាននូវតួនាទីដឹកនាំបច្ចេកទេសក្នុងចំណោមគ្រូបង្រៀនដទៃទៀតនៅក្នុងកម្រិតថ្នាក់របស់ខ្លួន (នៅកម្រិតបឋមសិក្សា) ឬមុខវិជ្ជា (នៅកម្រិតមធ្យមសិក្សា)។ តួនាទីរបស់ពួកគេគឺរៀបចំការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ ថ្នាក់និទ្ទស្សន៍ និង សកម្មភាព CPD ផ្សេងៗ។ |
| • សហគមន៍សិក្សាវិជ្ជាជីវៈ | នេះគឺជាក្រុមអ្នកអប់រំដែលជួបគ្នាជាប្រចាំ ចែករំលែកជំនាញឯកទេស និងធ្វើការតាមបែបសហការគ្នាដើម្បីកែលម្អបំណិនក្នុងការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្ស។ |
| • គណៈកម្មការសិក្សាវិជ្ជាជីវៈជាប្រចាំតាមសាលារៀន | នេះសំដៅទៅលើគណៈកម្មការនៅកម្រិតសាលារៀន ដែលរួមមានជាអាទិ៍ដូចជា អ្នកគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមួយចំនួនដែលនឹងត្រូវទទួលខុសត្រូវក្នុងការវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈ រៀបចំសកម្មភាព CPD តាមសាលារៀន ចូលរួម |

[6] ដកស្រង់ចេញពី៖ ក្រសួងអប់រំ (២០១៩) *ក្របខណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា*, ភ្នំពេញ៖ អ្នកនិពន្ធ។

| | |
|---|---|
| | នៅក្នុងវគ្គសិក្ខាសាលាវិក្រឹតការ (INSET) និងបង្កើតភាពជាដៃគូរជាមួយវិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន។ |
| • វិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន | បណ្ដាវិទ្យាស្ថាននៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលទទួលខុសត្រូវក្នុងការបណ្ដុះបណ្ដាលគ្រូកម្រិតបឋម និងកម្រិតមធ្យមសិក្សាតាមរយៈការបណ្ដុះបណ្ដាលដំបូង (PRESET) ក៏ដូចជាការគាំទ្រសកម្មភាព CPD តាមរយៈសកម្មភាពវិក្រឹតការ (INSET) ផងដែរ។ |
| **ដំណើរការទាំងឡាយដែលលើកកម្ពស់ CPD** | |
| • ស្វ័យវាយតម្លៃគ្រូបង្រៀន | នេះគឺជាដំណើរការបង្កើតការវិនិច្ឆ័យផ្សេងៗអំពីភាពសមរម្យ ឬប្រសិទ្ធភាពនៃចំណេះដឹង ការបំពេញការងារ ជំនឿ ផលិតផល ឬលទ្ធផលផ្ទាល់ខ្លួនរបស់នរណាម្នាក់ ដើម្បីអាចកែលម្អវា ឬធ្វើឱ្យវាប្រសើរឡើងបាន។ |
| • គន្លងអាជីពគ្រូបង្រៀន | នេះសំដៅទៅលើគន្លងអាជីពផ្សេងៗ ដែលគ្រូបង្រៀនមួយរូបអាចនឹងជ្រើសរើស ខណៈពេលដែលពួកគេអភិវឌ្ឍខ្លួនចេញពីមុខតំណែងជាគ្រូបង្រៀនធម្មតាមួយរូបទៅជាឋានៈមួយខ្ពស់ជាងនេះ។ មានគន្លងបីដែលត្រូវដើរតាម៖ ១) គន្លងការបង្រៀន; ២) គន្លងភាពជាអ្នកដឹកនាំ; និង ៣) គន្លងអ្នកឯកទេសអប់រំ។ |
| • សកម្មភាពវិក្រឹតការគ្រូបង្រៀន (INSET) | នេះមានន័យថាជាធានាលើសកម្មភាព និងការប្រតិបត្តិទាំងឡាយ ដែលគ្រូបង្រៀនចូលរួមដើម្បីបង្កើនគុណភាពចំណេះដឹងពួកគេ កែលម្អបំណិនក្នុងការបង្រៀនរបស់ពួកគេ និងបង្កលក្ខណៈឱ្យពួកគេមានប្រសិទ្ធភាពលើការងារកាន់តែច្រើនថែមទៀត។ ការធ្វើវិក្រឹតការ (INSET) តែងមានរូបភាពជាសិក្ខាសាលារៀន ប៉ុន្តែក៏មានជារូបភាពផ្សេងៗផងដែរ។ |
| • ការទទួលស្គាល់កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ | នេះគឺជាដំណើរការមួយ ដែលគ្រូបង្រៀនអាចទទួលបានក្រេឌីតផ្លូវការសម្រាប់ការចូលរួមវគ្គសិក្ខាសាលារៀនបណ្ដុះបណ្ដាល នៅពេលដែលអ្នកផ្ដល់វគ្គបណ្ដុះបណ្ដាលគឺជា CPD ដែលទទួលស្គាល់ដោយការិយាល័យគ្រប់គ្រង CPD (CPDMO) នៅរាជធានីភ្នំពេញ។ ក្រេឌីតទាំងនេះ អាចប្រើប្រាស់ដើម្បីវិវឌ្ឍខ្លួនទៅតាមរចនាសម្ព័ន្ធគន្លងអាជីពគ្រូបង្រៀនដែលអនុម័តដោយក្រសួងអប់រំ។ |
| • កម្រងស្នាដៃវិជ្ជាជីវៈ | នេះគឺជាប្រវត្តិរូបគ្រូបង្រៀនមួយរូប ដែលមានសំណុំឯកសារទាំងឡាយដែលបានចងក្រងដោយគ្រូបង្រៀន ដែលរួមមានដូចជា ប្រវត្តិរូបសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព សញ្ញាបត្រ និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាដែលមានគុណវុឌ្ឍ និទ្ទេសពិសេស ឬរង្វាន់ទាំងឡាយ ដែលគ្រូបង្រៀនទទួលបាន រង្វាយតម្លៃ ផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ និងឯកសារផ្សេងៗទៀតដែលជួយឱ្យគ្រូបង្រៀនតាមដានភ័ស្តុតាងជាឯកសារអំពីការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។ |
| • ផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ | ទាំងនេះគឺជាផែនការដែលនឹងត្រូវបង្កើតឡើងដោយបុគ្គលិកនៅកម្រិតសាលារៀន ដែលរៀបរាប់ អំពីរាល់សកម្មភាព CPD ទាំងអស់ដែលបានធ្វើផែនការ និងបានបញ្ចប់សព្វគ្រប់នៅក្នុងឆ្នាំសិក្សាណាមួយ។ ផែនការទាំងនេះនឹងក្លាយទៅជាផ្នែកនៃកម្រងស្នាដៃវិជ្ជាជីវៈមួយ ដែលអាចត្រូវបានដាក់បញ្ចូលទៅក្នុងប្រវត្តិរូបគ្រូបង្រៀន ហើយនឹងត្រូវប្រើសម្រាប់ការអភិវឌ្ឍអាជីពផ្អែកលើភ័ស្តុតាង និងជាការផ្ដល់រង្វាន់។ |

## ឯកសារទី១៥ក៖ ការផ្សារភ្ជាប់បញ្ញត្តិ រចនាសម្ព័ន្ធ & ដំណើរការ CPD ជាមួយគ្នាដើម្បីបង្កើតនូវក្របខ័ណ្ឌតក្កភាពមួយ

**សេចក្ដីណែនាំ៖** ផ្អែកលើការពិភាក្សាពីខាងដើមអំពីវាក្យសព្ទ និងនិយមន័យ ចូរបំពេញដ្យាក្រាមខាងក្រោមដែលរៀបរាប់អំពីការយល់ឃើញរបស់អ្នក ថាតើប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន នឹងមានរូបរាងដូចម្ដេចនៅពេលអនុវត្តគោលការណ៍នៃការគ្រប់គ្រងតាមសាលារៀន។ សូមប្រើវាក្យសព្ទទាំងឡាយដែលមានផ្ដល់ជូនក្នុងតារាងនៅផ្នែកខាងក្រោមនៃទំព័រនេះ ដើម្បីបំពេញដ្យាក្រាមរបស់អ្នក។ នៅពេលអ្នកធ្វើរួចរាល់ហើយ ចូរប្រៀបធៀបដ្យាក្រាមដែលបានបំពេញរួចរបស់អ្នកជាមួយនឹងក្រុមផ្សេងៗទៀត ដើម្បីឱ្យដឹងថាតើការយល់ឃើញរបស់អ្នកដូចគ្នា ឬខុសគ្នា។




| | |
|---|---|
| • ក្រុមបច្ចេកទេសគ្រូបង្រៀន<br>• សហគមន៍សិក្សាវិជ្ជាជីវៈ<br>• វិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូ<br>• កម្រងស្នាដៃវិជ្ជាជីវៈ<br>• ផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ<br>• គោលដៅចុងក្រោយ៖ ការសិក្សារបស់សិស្សរីកចម្រើន<br>• ដំណើរការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទូទៅ | • ស្វ័យវាយតម្លៃគ្រូ<br>• គណៈកម្មការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន<br>• ការធ្វើផែនការគន្លងអាជីពគ្រូបង្រៀន<br>• សកម្មភាពរិក្រិតការគ្រូ<br>• ការទទួលស្គាល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>• ប្រព័ន្ធផ្ដល់ប្រឹក្សាគរុកោសល្យតាមសាលារៀន |

## ឯកសារទី ១៥ខ៖ ក្របខ័ណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំនៅក្នុងបរិយាកាសនៃការគ្រប់គ្រងតាមសាលារៀន

ចូរប្រៀបធៀបតារាងលំហូរព័ត៌មានខាងក្រោមនេះ ជាមួយនឹងតារាងដែលអ្នកបានធ្វើក្នុងឯកសារទី ១៥ក។ តើការវិភាគរបស់អ្នកទៅលើវាក្យសព្ទទាំងនេះ និងរបៀបដែលមានទំនាក់ទំនងគ្នាដូចនឹងការវិភាគដែលផ្តល់ជូនក្នុងតារាងខាងក្រោមនេះដែរឬទេ? តើមានអ្វីដែលខុសគ្នា? ចូរពិភាក្សាជាមួយសហការីរបស់អ្នកអំពីសុខដុមនីយកម្មតារាងរបស់អ្នក ជាមួយនឹងតារាងដែលផ្តល់ជូនខាងក្រោមនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងរបស់អ្នកអំពីរបៀបដែលកត្តា CPD ទាំងនេះពាក់ព័ន្ធគ្នាទៅវិញទៅមក។



## **ឯកសារទី១៥គ៖ សកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដែលត្រូវពិចារណាសម្រាប់សាលារៀនរបស់អ្នក**[7]

ឯកសារនេះផ្តល់ជូននូវបញ្ជីសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំចំនួន ១៥ ដែលអ្នកអាចធ្វើទៅបាននៅសាលារៀនរៀនរបស់អ្នក។ ចូរពិនិត្យមើលបញ្ជីនេះជាមួយអ្នកសម្របសម្រួលរបស់អ្នក ដើម្បីស្វែងយល់ឱ្យបានកាន់តែប្រសើរនូវអ្វីដែលសកម្មភាពនីមួយៗតម្រូវ។ បញ្ជីសកម្មភាព CPD ដែលមានលក្ខណៈទូលំទូលាយជាងនេះមាននៅក្នុង *ក្របខ័ណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និង នាយកសាលារៀន* នៅក្នុងឧបសម្ព័ន្ធ "ជ" របស់ក្រសួងអប់រំ។

**លំហាត់ជាក្រុម៖** ក្រោយពីបានពិនិត្យមើលសកម្មភាពនីមួយៗរួចហើយ ចូរបំពេញតារាងខាងក្រោមជាមួយនឹងសញ្ញាធីក (✓) នៅក្នុងក្រុមរបស់អ្នក នៅលើសន្លឹកក្រដាសផ្ទាំងធំ ហើយត្រៀមខ្លួនចែករំលែកការពិចារណារបស់អ្នកជាមួយក្រុមធំ។

| **គំរូសកម្មភាពសម្រាប់លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** | តើសាលារៀនអ្នកធ្លាប់អនុវត្តសកម្មភាពនេះទេ? | | តើវាអាចធ្វើបាននៅសាលារៀនអ្នកឬទេ? | | តើអ្នកត្រូវការថវិកាដើម្បីអនុវត្តឬទេ? | | ចូរជ្រើសរើសសកម្មភាព ៥ ដែលសាលារៀនអ្នកអាចនឹងធ្វើបាន (✓) |
|---|---|---|---|---|---|---|---|
| | បាទ/ចាស់ | ទេ | បាទ/ចាស់ | ទេ | បាទ/ចាស់ | ទេ | |
| 1. ការស្រាវជ្រាវប្រតិបត្តិ | | | | | | | |
| 2. ការសិក្សាសៀវភៅ | | | | | | | |
| 3. ទស្សនកិច្ចសិក្សា | | | | | | | |
| 4. ការបង្វឹក | | | | | | | |
| 5. ធ្វើការជាមួយអង្គការសហគមន៍ | | | | | | | |
| 6. ការធ្វើផែនទីកម្មវិធីសិក្សា | | | | | | | |
| 7. វិភាគទិន្នន័យសិស្ស | | | | | | | |
| 8. ការទទួលគរុសិស្សធ្វើកម្មសិក្សា | | | | | | | |
| 9. ការធ្វើផែនការកម្មវិធីសិក្សាបែបបញ្ចូលគ្នា | | | | | | | |
| 10. ការសរសេរទិនានុប្បវត្តិ | | | | | | | |
| 11. បណ្តាញផ្សព្វផ្សាយសង្គម | | | | | | | |
| 12. ការបង្កើតកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំតាមអនឡាញ | | | | | | | |
| 13. ការចូលរួមជាមួយអង្គការវិជ្ជាជីវៈ | | | | | | | |
| 14. ការសិក្សាពេលវិស្សមកាល | | | | | | | |
| 15. ការបង្កើតគម្រោងរបស់ប្រធានក្រុមបច្ចេកទេស | | | | | | | |

ចូរត្រៀមខ្លួនពន្យល់អំពីមូលហេតុដែលអ្នកជ្រើសរើសសកម្មភាពជាសក្តានុពលទាំង ៥ ដែលអ្នកបានធ្វើ។ តើមានអ្វីដែលទាក់ទាញឱ្យអ្នកជ្រើសយកជម្រើសទាំងនេះ? តើអ្នកមានធនធានបច្ចេកទេសធ្វើវាដែរឬទេ? តើអ្នកមានធនធានធ្វើវាទេ?

---

[7] Ibid.

## សកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំទូទៅសម្រាប់កម្រិតសាលារៀន

| សកម្មភាព CPD | ការបរិយាយ |
|---|---|
| 1. ការស្រាវជ្រាវប្រតិបត្តិ | គ្រូអាចប្រើប្រាស់ថ្នាក់រៀនរបស់ខ្លួនជាទីតាំងស្រាវជ្រាវ។ |
| 2. ការសិក្សាសៀវភៅ | គ្រូជ្រើសរើសសៀវភៅមួយក្បាលស្ដីពីបញ្ហានៃភាពទាក់ទងអប់រំដែលសំខាន់ រួចហើយអានរួមគ្នា ពិភាក្សាអំពីគំនិតទាំងឡាយនៅក្នុងការប្រជុំដែលបានគ្រោងទុក។ |
| 3. ទស្សនកិច្ចសិក្សា | គ្រូចុះទស្សនកិច្ចតាមថ្នាក់រៀនរបស់សហការី ឬសាលារៀនផ្សេងទៀត ដើម្បីពិនិត្យ និងពង្រីកគរុកោសល្យផ្ទាល់ខ្លួនរបស់ពួកគេ។ ការចុះទស្សនកិច្ចគួរមានរចនាសម្ព័ន្ធនិងលទ្ធផលច្បាស់លាស់។ |
| 4. ការបង្វឹក | គ្រូស្នើសុំ និងទទួលព័ត៌មានត្រឡប់អំពីការអនុវត្តរបស់ខ្លួនបន្ទាប់ពីបានសង្កេតដោយគ្រូបង្វឹកមួយរូប (ឧ. សហការី ឬអ្នកសង្កេតដទៃទៀត (TTI, ។ល។)។ |
| 5. ការធ្វើការជាមួយអង្គការសហគមន៍ | គ្រូទទួលឱកាសក្នុងការធ្វើការជាមួយអង្គការសហគមន៍ ដើម្បីអភិវឌ្ឍបំណិនដឹកនាំរបស់ខ្លួន និងស្វែងយល់អំពីសហគមន៍មូលដ្ឋានបានកាន់តែប្រសើរថែមទៀត។ |
| 6. ការធ្វើផែនទីកម្មវិធីសិក្សា | ផែនទីកម្មវិធីសិក្សា គឺជាឧបករណ៍រៀបចំការបង្រៀន។ តាមរយៈការធ្វើផែនទីអ្វីដែលបានបង្រៀនជាក់ស្ដែង និងពេលវេលា គ្រូអាចកែសម្រួលការបង្រៀនរបស់ខ្លួនបាន។ |
| 7. ការវិភាគទិន្នន័យសិស្ស | គ្រូប្រើទិន្នន័យដើម្បីសម្រេចចិត្តបានកាន់តែប្រសើរអំពីអ្វីដែលត្រូវបង្រៀន របៀបកំណត់ថាតើសិស្សយល់នូវអ្វីដែលបានបង្រៀនដែរឬទេ ។ល។ គ្រូអាចប្រើតេស្ត កម្រងស្នាដៃសិស្ស ឬការសង្កេតសម្រាប់គោលបំណងនេះ។ |
| 8. ការទទួលគរុសិស្សធ្វើកម្មសិក្សា | ការទទួលគរុសិស្ស ដាក់គ្រូបង្រៀននៅក្នុងតួនាទីប្រឹក្សាគរុកោសល្យមួយ។ គ្រូប្រឹក្សាគរុកោសល្យរៀនសូត្របានកាន់តែច្រើនអំពីការប្រតិបត្តិផ្ទាល់ខ្លួនខណៈពេលពួកគេកំពុងធ្វើផង និងជួយដល់គ្រូបង្រៀនថ្មីផងក្នុងការអភិវឌ្ឍការអនុវត្តរបស់ខ្លួនផ្ទាល់។ |
| 9. ការធ្វើផែនការកម្មវិធីសិក្សាបែបបញ្ចូលគ្នា | គ្រូរៀបចំកម្មវិធីសិក្សាដើម្បីឱ្យវាជាប់ពាក់ព័ន្ធនឹងមុខវិជ្ជាផ្សេងទៀត ដោយនាំយកប្រធានបទនានាបញ្ចូលគ្នាប្រកបដោយអត្ថន័យ និងដើម្បីអនុញ្ញាតឱ្យសិស្សផ្ដោតលើជំនាញសិក្សាទូលំទូលាយ។ |
| 10. ការសរសេរទិនានុប្បវត្តិ | សៀវភៅកំណត់ត្រាគរុកោសល្យគឺជាបច្ចេកទេសមួយសម្រាប់កត់ត្រាការសង្កេត និងការឆ្លុះបញ្ចាំងទៅលើការបង្រៀនរបស់គ្រូណាម្នាក់។ វារួមចំណែកដល់ការបង្រៀនបែបឆ្លុះបញ្ចាំង។ |
| 11. បណ្ដាញផ្សព្វផ្សាយសង្គម | បណ្ដាញបច្ចេកវិទ្យាដែលជួយគ្រូបង្រៀនប្រាស្រ័យទាក់ទងជាមួយក្រុមអ្នកអប់រំកាន់តែទូលំទូលាយ និងចម្រុះ ដែលលើសពីសាលារៀនរបស់ខ្លួន ដើម្បីចែករំលែកគំនិត និងការអនុវត្តថ្មីៗ។ |
| 12. ការបង្កើតកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំតាម អនឡាញ | គ្រូអាចទទួលបានក្រេឌីតពីអង្គការនានាដែលផ្ដល់កម្មវិធីបណ្ដុះបណ្ដាលអនឡាញ ដែលរៀនតាមវីដេអូណែនាំ & កម្មវិធីរៀនដោយខ្លួនឯង។ |
| 13. ការចូលរួមជាមួយអង្គការវិជ្ជាជីវៈ | សមាគមសម្រាប់គ្រូមុខវិជ្ជា (ឧ. សមាគមគណិតវិទ្យា) ផ្ដល់នូវឱកាសដ៏ល្អមួយសម្រាប់កែលម្អចំណេះដឹងវិជ្ជាជីវៈរបស់គ្រូបង្រៀន។ |
| 14. ការសិក្សាពេលវិស្សមកាល | គ្រូក៏អាចចូលរួមវគ្គសិក្សាពិសេសៗ ដែលមានការគាំទ្រអាហារូបករណ៍ពីសាលារៀន នៅវិទ្យាស្ថាន ឬសាកលវិទ្យាល័យនានាក្នុងស្រុកផងដែរ។ |
| 15. ការបង្កើតគម្រោងរបស់ប្រធានក្រុមបច្ចេកទេស | តួនាទីមួយរបស់ប្រធានក្រុមបច្ចេកទេសគឺ ជួយក្រុមគ្រូបង្រៀនកំណត់រកគម្រោងមួយដែលមានន័យចំពោះពួកគេ បន្ទាប់មកធ្វើការជាដំណាក់កាលៗដែលត្រូវការអនុវត្តវា។ |

# ឯកសារទី ១៦កៈ ការបង្កើតប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដ៏ជោគជ័យមួយ

## ការដាក់ផែនការរួមគ្នាមួយដើម្បីដាក់ប្រព័ន្ធ CPD មួយតាមសាលារៀន

គោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់ៗនៃម៉ូឌុលនេះគឺ ដើម្បីជួយឱ្យអ្នកគ្រប់គ្រងសាលារៀនបានដឹងនូវអ្វីដែលពួកគេគួរតែធ្វើនៅពេលពួកគេត្រឡប់ទៅកាន់សាលារៀនរបស់ពួកគេវិញ ដើម្បីរៀបចំប្រព័ន្ធ CPD មួយតាមសាលារៀន។ ខាងក្រោមនេះគឺជាយោបល់មួយចំនួនៈ

យោបល់ទី ១ៈ **ប្រមូលឯកសារមានប្រយោជន៍មួយចំនួន** ដើម្បីឱ្យអ្នកបានយល់ដឹងកាន់តែប្រសើរអំពីក្របខ័ណ្ឌគោលនយោបាយរបស់ក្រសួងអប់រំ ពីព្រោះវាពាក់ព័ន្ធនឹងប្រព័ន្ធ CPD ។ ឯកសារសំខាន់ៗមួយចំនួនដែលត្រូវអានរួមមានជាអាទិ៍ដូចជាៈ

- *ក្របខ័ណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន ២០១៩-២៣*
- *សៀវភៅណែនាំការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ*
- *សៀវភៅណែនាំសហគមន៍សិក្សាវិជ្ជាជីវៈ*

ឯកសារទាំងនេះអាចរកបាននៅលើវិបសាយរបស់ក្រសួងអប់រំ ( https://www.moeys.gov.kh/index.php/kh/

យោបល់ទី ២ៈ **ជួបជាមួយបុគ្គលិកបង្រៀនសំខាន់ៗនៅក្នុងសាលារៀនរបស់អ្នក (ឧ. នាយករង ប្រធានក្រុមបច្ចេកទេស ។ល។) និងបង្កើនការយល់ដឹងរបស់ពួកគេអំពីបញ្ហា CPD ។** អ្នកអាចពិចារណាចម្លងតាមម៉ូឌុលនេះដោយប្រើឯកសារទាំងឡាយដែលបានផ្តល់ជូនអ្នក។

យោបល់ទី ៣ៈ **រៀបចំគណៈកម្មការ CPD តាមសាលារៀននៅក្នុងសាលារៀនរបស់អ្នក** តាមគោលការណ៍ណែនាំនៅក្នុងឯកសារក្របខ័ណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំ ដែលដាក់បញ្ចូលនូវអ្នកដឹកនាំសំខាន់ៗនៅក្នុងចំណោមគ្រូបង្រៀនរបស់អ្នក។ ព្យាយាមធានាឱ្យបានថា អ្នកដឹកនាំដែលមានភាពសកម្មបំផុតក្នុងសាលារៀន ដែលមានចំណេះដឹងល្អផ្នែកគរុកោសល្យ ស្ថិតនៅក្នុងតួនាទីជាថ្នាក់ដឹកនាំនៅក្នុងគណៈកម្មការនេះ។

យោបល់ទី ៤ៈ **ធ្វើការវាយតម្លៃតម្រូវការដើម្បីកំណត់នូវតម្រូវការសមត្ថភាពសំខាន់ៗបំផុតនៅសាលារៀនរបស់អ្នក តាមរយៈការស្ទង់មតិ សម្ភាសន៍ និងមធ្យោបាយផ្សេងៗ។**

យោបល់ទី ៥ៈ **លើកទឹកចិត្តឱ្យគ្រូបង្រៀនឈានទៅរកការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈមួយ។** នេះពុំមែនជាកិច្ចការងាយស្រួលធ្វើរហូតទេ ពីព្រោះសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) ពុំមែនជាគណៈកម្មការ ឬរចនាសម្ព័ន្ធផ្លូវការមួយឡើយ ប៉ុន្តែជាបណ្តាញគ្រូបង្រៀនក្រៅផ្លូវការមួយ ដែលជួយគ្នាទៅវិញទៅមក និងចែករំលែកអ្វីៗជាមួយគ្នា។ ប៉ុន្តែយ៉ាងហោចណាស់សាលារៀនអាចចាប់ផ្តើមដំណើរការដោយភ្ជាប់ទំនាក់ទំនងគ្រូបង្រៀនជាមួយគ្នានៅក្នុងក្រុមបណ្តាញសង្គម ដែលគោលបំណងរបស់ពួកគេគឺចែករំលែក និងបង្កើនការប្រាស្រ័យទាក់ទងក្នុងចំណោមគ្រូបង្រៀន។ ក្រុមរងផ្សេងៗទៀតអាចបង្កើតឡើងនៅពេលក្រោយ។ សូមអានសៀវភៅណែនាំសហគមន៍សិក្សាវិជ្ជាជីវៈរបស់ក្រសួងអប់រំ ដើម្បីទទួលបានការណែនាំបន្ថែមអំពីការបង្កើតសហគមន៍នេះនៅសាលារៀនរបស់អ្នក។

**យោបល់ទី ៦៖ កំណត់អត្តសញ្ញាណអ្នកផ្តល់សេវា CPD មួយចំនួននៅក្នុងតំបន់របស់អ្នក ដែលអាចផ្តល់នូវការគាំទ្រសកម្មភាពរៀបចំការ INSET ឬវគ្គសិក្សាអនឡាញ (ឧ. LNGOS, TTIs ។ល។)។**

**យោបល់ទី ៧៖ ធានាថា អ្នកបានដាក់បញ្ចូលថវិកាសម្រាប់សកម្មភាពគាំទ្រ CPD ទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក។**

## តើការស្រាវជ្រាវសកលនិយាយដូចម្តេចអំពីការអនុវត្តប្រព័ន្ធ CPD នៅកម្រិតសាលារៀន?

ប្រទេសផ្សេងៗជាច្រើនក្រៅពីកម្ពុជា កំពុងស្វែងរកការប្រើប្រាស់គោលការណ៍គ្រប់គ្រងតាមសាលារៀនដើម្បីកែលម្អការរៀបចំសាលារៀន ជាមធ្យោបាយក្នុងការរៀបចំប្រព័ន្ធ CPD នៅកម្រិតសាលារៀន។ ការស្រាវជ្រាវសកលបញ្ជាក់ថា ប្រទេសជាច្រើនកំពុងតែបរាជ័យនៅក្នុងកិច្ចប្រឹងប្រែងទាំងនេះ។[8] ទាំងនេះគឺជាហេតុផលមួយចំនួន ដែលអ្នកស្រាវជ្រាវរាយការណ៍អំពីមូលហេតុដែលប្រព័ន្ធ CPD នៅកម្រិតសាលារៀនតែងតែបរាជ័យ៖

1. **អាទិភាពទាប៖** គ្រូបង្រៀនផ្តោតតែទៅលើការបង្រៀនឯកជនរបស់ពួកគេ និងកិច្ចការផ្សេងៗតាមទម្លាប់ ហើយផ្តល់អាទិភាពទាបទៅលើការអភិវឌ្ឍន៍វិជ្ជាជីវៈ។
2. **ខ្វះភាពជាអ្នកដឹកនាំ៖** ពុំមាននរណាម្នាក់នៅសាលារៀន ដែលមានជំនាញឯកទេសខ្ពស់ផ្នែក CPD ដើម្បីសម្របសម្រួលសកម្មភាព CPD ប្រកបដោយប្រសិទ្ធភាព ដូច្នេះមានស្ថានភាពមួយហៅថា "អ្នកខ្វាក់ដឹកនាំអ្នកខ្វាក់"។
3. **ការជំរុញទឹកចិត្តទាប៖** គ្រូបង្រៀនបំពេញតែភារកិច្ច CPD តាមរបៀបជាយន្តការមួយដោយពុំអស់ពីបេះដូងទៅលើកិច្ចការនោះឡើយ។ ដូច្នេះ មានផលជះតិចតួចទៅលើការប្រតិបត្តិជាក់ស្តែងនៅក្នុងថ្នាក់រៀន។
4. **លទ្ធភាពប្រើប្រាស់ពេលវេលានៅមានកម្រិត៖** ពេលវេលាដែលបានចាត់ចែងសម្រាប់សកម្មភាព CPD (ឧ. ២ ម៉ោងក្នុងមួយសប្តាហ៍) ហាក់ដូចជាតិចតួចពេកសម្រាប់ធ្វើឱ្យមានផលជះពិតប្រាកដទៅលើចំណេះដឹង និងបំណិនរបស់គ្រូបង្រៀន។
5. **ភាពទាក់ទងមានកម្រិតទាប៖** គ្រូបង្រៀនពុំបានមើលឃើញជាក់ស្តែងថា សកម្មភាព CPD ពាក់ព័ន្ធនឹងការអភិវឌ្ឍខ្លួន ឬបញ្ហាជាក់ស្តែងនៅសាលារៀនឡើយ។ វាគ្រាន់តែជាបន្ទុកការិយាធិបតេយ្យបន្ថែមដែលពួកគេត្រូវតែធ្វើដោយពុំបានដឹងពីមូលហេតុប៉ុណ្ណោះ។
6. **ខ្វះធនធាន៖** ទោះពេលដែលសាលារៀនព្យាយាមបង្កើតនូវកិច្ចប្រឹងប្រែងមួយដើម្បីអនុវត្តគោលការណ៍ CPD ក៏ដោយ ក៏ពុំមានធនធានសម្រាប់វគ្គសិក្សាសាលារៀន ទស្សនកិច្ច ការស្រាវជ្រាវប្រតិបត្តិឡើយ។ល។
7. **ពិបាកក្នុងការប្រែក្លាយលទ្ធផលជាក់ស្តែងទៅជាសកម្មភាព៖** បន្ទាប់ពីសាលារៀនបានធ្វើការវាយតម្លៃទៅលើស្ថានភាពនៅក្នុងសាលារៀនរបស់ពួកគេរួចហើយ មានអសមត្ថភាពមួយក្នុងការផ្គូរផ្គងលទ្ធផលជាមួយនឹងដំណោះស្រាយជាដុំកំភួន ដែលអាចមានផលជះ។
8. **ខ្វះសម្ភារជាឯកសារ៖** សាលារៀនទទួលបានតិចតួចនូវឯកសារជាភាសាជាតិ ដើម្បីជួយឱ្យពួកគេយល់បានកាន់តែប្រសើរថែមទៀតអំពីដំណើរការ CPD ។ ឯកសារដែលមានទាំងនោះសុទ្ធតែក្រាស់ និងពិបាកអាន។

---

[8] ឧទា. Craft, A. (2000). *Continuing professional development: A practical guide for teachers and schools.* (2nd ed). London: Routledge Falmer.

**ពិភាក្សាក្រុម៖** ចូរពិនិត្យមើលសំណួរទាំងឡាយខាងក្រោមតាមក្រុមតូចៗរបស់អ្នក ហើយបង្កើតចម្លើយដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក និងបទពិសោធន៍របស់អ្នកដទៃ។ ត្រូវត្រៀមខ្លួនពិភាក្សាចម្លើយរបស់អ្នកជាមួយក្រុមធំទាំងមូល។

**សំណួរពិភាក្សា៖**

1. តើអ្នកគិតថា បញ្ហាដកស្រង់ខាងលើ មានប៉ុន្មានដែលពាក់ព័ន្ធនឹងស្ថានភាពក្នុងប្រទេសកម្ពុជា (ឧ. ទាំងអស់? ភាគច្រើន? ឬមួយចំនួន?)
2. ចំពោះការដកស្រង់បញ្ហាខាងលើ បញ្ហា**២ ឬ៣** ណាមួយ ដែលអ្នកគិតថាសំខាន់បំផុតនៅក្នុងបរិបទប្រទេសកម្ពុជា ហើយពិបាកដោះស្រាយបំផុត?
3. សម្រាប់បញ្ហា២ឬ៣ ដែលអ្នកបានដកស្រង់ជាអាទិភាពខ្ពស់ជាងគេ តើអ្នកព្យាយាមដោះស្រាយបញ្ហាទាំងនោះដោយរបៀបណានៅតាមមូលដ្ឋានសាលារៀន ឬតាមខេត្តរបស់អ្នក? ចូរព្យាយាមផ្តល់ព័ត៌មានជាក់លាក់នៅពេលពិពណ៌នាដំណោះស្រាយ។

## ចម្លើយ

## ឯកសារទី១៦២៖ តើយើងគួរប្រើប្រាស់តេស្តដើម្បីវិនិច្ឆ័យប្រសិទ្ធភាពនៃប្រព័ន្ធ CPD នៅកម្រិតសាលារៀនដែរឬទេ ?

### ហេតុអ្វីប្រើប្រាស់តេស្តដើម្បីវាយតម្លៃប្រសិទ្ធភាព CPD ?

សម្រាប់អ្នកអប់រំជាច្រើន មូលដ្ឋានសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំមានប្រសិទ្ធភាពឬយ៉ាងណានោះ គួរតែជាសិស្ស ដែលបង្ហាញឱ្យឃើញនូវការសិក្សាប្រសើរឡើង។ ប្រសិនបើការសិក្សារបស់សិស្សប្រសើរជាងមុននោះ នោះមានន័យថាមានភាពវិជ្ជមានលើការប្រែប្រួលដែលបានកើតឡើងនៅក្នុងវិជ្ជាជីវៈ សមត្ថភាព និងការប្រតិបត្តិក្នុងថ្នាក់រៀនជាទូទៅរបស់គ្រូបង្រៀន។



សម្រាប់អ្នកអប់រំជាច្រើន វិធីងាយស្រួលបំផុតក្នុងការរកឱ្យឃើញថាតើសិស្សរៀនបានប្រសើរជាងមុនដែរឬយ៉ាងណានោះ គឺមើលទៅលើពិន្ទុតេស្ត។ គោលបំណងនៃតេស្តគឺ ដើម្បីវាយតម្លៃការយល់ដឹងរបស់សិស្សអំពីមាតិកានៃកម្មវិធីសិក្សា។ ដូច្នេះហើយ តេស្តទាំងនេះហាក់ដូចជាឧបករណ៍ដ៏ល្អបំផុតក្នុងការវាយតម្លៃទៅលើលទ្ធផលសិក្សារបស់សិស្ស ហើយបន្តមកទៀតគឺវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំរបស់សាលារៀន។ ប៉ុន្តែ សាលារៀនមួយចំនួន ពុំទុកចិត្តទៅលើតេស្តរបស់គ្រូបង្រៀនឡើយ ពីព្រោះពួកគេអាចនឹងចង់បង្ហាញលទ្ធផលល្អ ដើម្បីចៀសវាងការស្តីបន្ទោស។ ការណ៍នេះ ជំរុញទឹកចិត្តឱ្យគ្រូបង្រៀនបង្កើតនូវតេស្តបែបងាយៗ។ ដូច្នេះ ពេលខ្លះប្រព័ន្ធអប់រំដាក់តេស្តស្តង់ដាឱ្យសាលារៀនប្រើប្រាស់ដើម្បីវាយតម្លៃការសិក្សារបស់សិស្សឱ្យបានជឿជាក់ជាងមុន។

### តើអ្នករាល់គ្នាយល់ព្រមទេថា យើងគួរតែប្រើប្រាស់តេស្តដើម្បីវាយតម្លៃប្រសិទ្ធភាព CPD?

ចម្លើយនៃសំណួរនេះគឺ "ទេ" ! គ្មាននរណាម្នាក់យល់ព្រមជាមួយនឹងទស្សនៈដែលបានលើកឡើងខាងលើទេ។ ហេតុផលចំពោះការមិនពេញចិត្តរបស់អ្នកអប់រំមួយចំនួនក្នុងការវាយតម្លៃប្រព័ន្ធ CPD ដោយប្រើប្រាស់ឬសគល់តេស្តដែលបានមកពីការអនុវត្តមួយហៅថា "ការបង្រៀនតម្រូវតាមតេស្ត"។ ការណ៍នេះមានន័យថា គ្រូមានបំណងចង់ចៀសវាងការស្តីបន្ទោសពីថ្នាក់លើចំពោះលទ្ធផលសិក្សាខ្សោយរបស់សិស្ស។ ដោយសារគ្រូបង្រៀនទាញហេតុផលថា ពួកគេនឹងទទួលខុសត្រូវចំពោះលទ្ធផលនៃតេស្តដែលបានផ្តល់ទៅឱ្យសិស្សរបស់ខ្លួននោះ ពួកគេធ្វើអ្វីៗគ្រប់យ៉ាងតាមដែលអាចធ្វើបាន ដើម្បីធ្វើឱ្យប្រាកដថាសិស្សប្រឡងជាប់។ នេះមានន័យថា រាល់ការបង្រៀនរបស់ពួកគេ ក្តោបជុំវិញការជួយឱ្យសិស្សទទួលបានជោគជ័យនៅក្នុងការធ្វើតេស្ត។

បញ្ហាជាមួយនឹង "ការបង្រៀនតម្រូវតាមតេស្ត" គឺថា តេស្តប្រើក្រដាស និងខ្មៅដៃតែងតែផ្តោតលើបំណិនគិតកម្រិតទាបដូចជា ការចងចាំ និងការយល់។ បំណិនដូចជា ការអនុវត្ត ការវិភាគ និងការវាយតម្លៃតែងតែមើលរំលង។ លើសពីនេះ ការផ្តោតតែម្យ៉ាងទៅលើ "ការធ្វើតេស្ត" ជាទូទៅមានន័យថា គ្រូបង្រៀនមិនចាប់អារម្មណ៍លើវិធីបង្រៀនថ្មីៗ ការប្រើប្រាស់បន្ទប់ពិសោធន៍ ឬការប្រើប្រាស់ ICT នៅក្នុងការបង្រៀនឡើយ ពីព្រោះអ្វីៗទាំងនេះធ្វើបានតិចតួចក្នុងការជួយឱ្យសិស្សធ្វើតេស្តជាប់។ ដូច្នេះហើយ ការប្រតិបត្តិ "ការបង្រៀនតម្រូវតាមតេស្ត" ពិតជាធ្វើឱ្យចុះខ្សោយនូវកិច្ចប្រឹងប្រែងក្នុងការជំរុញទឹកចិត្តគ្រូបង្រៀនឱ្យប្រើប្រាស់ការអនុវត្តក្នុងការបង្រៀនថ្មីៗ។

## វិធីសាស្ត្រផ្សេងៗក្នុងការវាយតម្លៃប្រព័ន្ធ CPD

អ្នកប្រឆាំងការប្រើប្រាស់តេស្តជាមធ្យោបាយចម្បងក្នុងការវាយតម្លៃប្រសិទ្ធភាព CPD បង្ហាញហេតុផលថា គ្រូបង្រៀនគួរទទួលបានការវិនិច្ឆ័យលើសពីលទ្ធផលតេស្តតែម្យ៉ាងគត់។ សាលារៀនអាចក្រឡេកមើលទៅលើលទ្ធផលតេស្តនូវកម្រិតមួយចំនួន ប៉ុន្តែកម្រិតទាំងនេះគួរតែជាការវាស់ស្ទង់ "**មួយ**" ក្នុងចំណោមការវាស់ស្ទង់ជាច្រើនអំពីរបៀបដែលគ្រូបង្រៀនត្រូវបានវិនិច្ឆ័យ។ ការវាស់ស្ទង់ដ៏មានប្រយោជន៍ចុងក្រោយបង្អស់ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធ CPD អាចនឹងរួមមានជាអាទិ៍ដូចជា៖

1. អត្រានៃការឆ្លងភូមិសិក្សាទៅកាន់សាកលវិទ្យាល័យ ឬសាលារៀនវិជ្ជាជីវៈ
2. ចំនួនគម្រោងដែលសិស្សបានបញ្ចប់ក្នុងមួយឆ្នាំ
3. ចំនួនរង្វាន់ និងមេដាយដែលសាលារៀនទទួលបាន
4. តម្រូវការរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅសាលារៀន

អាចមានការវាស់ស្ទង់ចុងក្រោយផ្សេងៗជាច្រើនទៀតអំពីប្រសិទ្ធភាពនៃ CPD ដែលអាចប្រើប្រាស់ផងដែរនៅក្នុងន័យនេះ។ ទោះជាយ៉ាងណា ការប្រើប្រាស់តេស្តតែម្យ៉ាង អាចធ្វើឱ្យចុះខ្សោយដល់ប្រសិទ្ធភាពរបស់ប្រព័ន្ធ CPD ។

### សំណួរពិភាក្សា

1. តើទស្សនៈខាងលើណាមួយដែលអ្នកយល់ស្រប? តើទស្សនៈគាំទ្រ ឬប្រឆាំងនឹងការធ្វើតេស្ត? ចូរពន្យល់ហេតុផល ហេតុអ្វីបានជាអ្នកយល់ស្របទៅនឹងទស្សនៈជាក់លាក់មួយនេះ ដោយរៀបហេតុផលរបស់អ្នក។
2. តើអ្នកដែលជួបស្ថានភាពមួយដែលថា សាលារៀនរបស់អ្នកធ្វើការល្អហើយ តែលទ្ធផលវាយតម្លៃក្នុងតេស្តបែរជាផ្ទុយទៅវិញ? ប្រសិនបើដូច្នេះមែន តើអ្នកប្រានលទ្ធផលរិះគន់ត្រឡប់ទៅវិញដូចម្តេច? តើអ្នកធ្វើអ្វីចំពោះស្ថានភាពនេះ? តើមានប្រសិទ្ធភាពទេ?
3. តើអ្នកគិតថា អ្នកអាចតាមដានជម្រើសវិធានការមួយចំនួនលើការវាយតម្លៃសមត្ថភាពគ្រូដែលបានលើកឡើងក្នុងកថាខ័ណ្ឌខាងលើ (ឧ.ការឆ្លងភូមិសិក្សាទៅកម្រិតសកលវិទ្យាល័យ)? ចូរជ្រើសរើសវិធានការវាយតម្លៃ១ឬ២ ដើម្បីពិនិត្យតាមដានប្រសិទ្ធភាពការងាររបស់គ្រូ និងពិពណ៌នាពីអ្វីដែលអ្នកត្រូវធ្វើដើម្បីទទួលបានព័ត៌មាននេះ។

## ចម្លើយ

## ឯកសារទី ១៧៖ ការកំណត់និយមន័យវាក្យសព្ទផែនការទូទៅ

**ការណែនាំ៖** ចូរអានវាក្យសព្ទទូទៅដែលប្រើប្រាស់នៅក្នុងការធ្វើផែនការនៅខាងក្រោមនេះ និងព្យាយាមចាត់ថ្នាក់វា ថាតើមួយណាខ្លះមានអត្ថន័យស្រដៀងគ្នា។ រាយបញ្ជីវាក្យសព្ទដែលមានអត្ថន័យស្រដៀងគ្នានៅក្នុងតារាងដែលមានផ្តល់ជូន។ មានឧទាហរណ៍មួយសម្រាប់អ្នករួចហើយ។ និយមន័យមួយចំនួនអាចត្រូវបានអនុវត្តលើសពីមួយពាក្យ អាស្រ័យទៅលើគោលវិធីធ្វើផែនការដែលសិក្ខាកាមបានប្រើប្រាស់ពីមុនមក។ មុនពេលធ្វើចម្លើយរបស់អ្នក ចូរពិភាក្សាដោយប្រុងប្រយ័ត្នជាមួយសមាជិកក្នុងក្រុមរបស់អ្នកដោយយោងទៅតាមបទពិសោធន៍ធ្វើផែនការពីមុនមក។ នៅក្នុងលំហាត់ ត្រង់ចំណុចនេះ ពុំមានចម្លើយត្រឹមត្រូវតែមួយទេ ដូច្នេះក្រុមនីមួយៗអាចនឹងមានរបៀបខុសគ្នាក្នុងការចាត់ថ្នាក់វាក្យសព្ទ។ ដូច្នេះពេលធ្វើការជាក្រុមធំ សិក្ខាកាមគួរព្យាយាមផ្ទៀងផ្ទាត់វាក្យសព្ទជាមួយនឹងនិយមន័យដែលផ្តល់ជូននៅក្នុងតារាងទីពីរ ដើម្បីធ្វើឱ្យមានស្តង់ដាអត្ថន័យនៃវាក្យសព្ទដែលត្រូវប្រើប្រាស់នៅក្នុងលំហាត់នេះ។

| | | | |
|---|---|---|---|
| ក. គោលដៅ | ង. សូចនាករ* | ឈ. តម្រូវការ | ឌ. វត្ថុបំណង |
| ខ. សកម្មភាព | ច. ដំណោះស្រាយ | ញ. សូចនាករ* | ឍ. ធនធាន |
| គ. ធាតុចូល | ឆ. ធាតុចេញ | ដ. គោលបំណង | ណ. កត្តាខាងក្រៅ |
| ឃ. ការសន្មត់ | ជ. បញ្ហា | ឋ. លទ្ធផល | ត. សូចនាករ* |

*ពាក្យ *សូចនាករ* មានរាយបញ្ជី ៣ ដង ពីព្រោះភាសាខ្មែរមានវាក្យសព្ទខុសគ្នាចំនួន ៣ ដែលអាចមានន័យជាសូចនាករ។

| រាយបញ្ជីវាក្យសព្ទសមមូលគ្នានៅក្នុងជួរនីមួយៗដែលផ្តល់ជូនខាងក្រោមនេះ។ មានឧទាហរណ៍មួយសម្រាប់អ្នកហើយ។ | | | |
|---|---|---|---|
| 1. គោលដៅ | វត្ថុបំណង | លទ្ធផល | គោលបំណង |
| 2. | | | |
| 3. | | | |
| 4. | | | |
| 5. | | | |
| 6. | | | |
| 7. | | | |

| និយមន័យ | វាក្យសព្ទ |
|---|---|
| 1. អ្វីមួយដែលយើងមិនពេញចិត្តជាមួយ ឬជាឧបសគ្គចំពោះគោលដៅរបស់យើង។ | |
| 2. លទ្ធផលវិជ្ជមានរួមដែលយើងចង់មើលឃើញនៅក្នុងផែនការរបស់យើង។ | |
| 3. លទ្ធផលវិជ្ជមានជាក់លាក់ ឬលក្ខខណ្ឌក្នុងផែនការដែលនាំទៅរកគោលដៅកម្រិតខ្ពស់។ | |
| 4. សម្ភារ ឬអ្វីៗដែលយើងត្រូវការដើម្បីអនុវត្តផែនការ។ | |
| 5. លក្ខខណ្ឌទាំងឡាយដែលយើងពុំអាចគ្រប់គ្រងលើវាបាន ដែលអាចប៉ះពាល់ដល់ការអនុវត្តផែនការ។ | |
| 6. អ្វីៗដែលមនុស្សម្នាក់ៗធ្វើ ដើម្បីអនុវត្តផែនការ ហើយទាមទារឱ្យមានធនធានក្នុងការធ្វើវា | |
| 7. អ្វីៗដែលយើងប្រើប្រាស់ដើម្បីវាស់ស្ទង់វឌ្ឍនភាពឆ្ពោះទៅរកគោលដៅរបស់យើង។ | |

## ឯកសារទី ១៨៖ ការសង្កេតជាមូលដ្ឋានមួយចំនួនអំពីដំណើរការធ្វើផែនការ

**ហេតុអ្វីបានជាយើងគួរតែធ្វើផែនការ?** មហិច្ឆតាថ្នាក់ជាតិចំពោះគុណភាពអប់រំ និងការសិក្សារបស់សិស្សមានកម្រិតខ្ពស់បំផុត។ ដើម្បីសម្រេចមហិច្ឆតានោះបាន សាលារៀននៅកម្ពុជាគួរបង្កើតផែនការមួយដែលព្យាយាមដោះស្រាយរាល់បញ្ហាដែលបានរកឃើញ ដែលរាំងស្ទះដល់គុណភាពអប់រំ និងការសិក្សារបស់សិស្ស។ ការធ្វើផែនការនៅក្នុងបរិបទការគ្រប់គ្រងតាមសាលារៀន (SBM) ដែលសាលារៀនមានស្វ័យភាពខ្ពស់ក្នុងការសម្រេចចិត្តទាក់ទងនឹងការចាត់ចែងធនធាន និងការផ្លាស់ប្តូរការរៀបចំសាលារៀនទំនងជាផ្តល់លទ្ធផលល្អបំផុត។

**ការធ្វើផែនការ និង ការអនុវត្ត៖** ការធ្វើផែនការអភិវឌ្ឍន៍សាលារៀនពុំមែនជាអ្វីមួយដែលយើងធ្វើនៅពេលចាប់ផ្តើមឆ្នាំសិក្សា ហើយក្រោយមកទៀតបំភ្លេចវាចោលនៅពេលផុតមួយឆ្នាំសិក្សានោះឡើយ។ ជារឿយៗនាយកសាលារៀនតែងតែទុកផែនការនៅក្នុងថតតុរបស់ខ្លួនរួចហើយបំភ្លេចវាចោល។ ផ្ទុយមកវិញការធ្វើផែនការសំដៅទៅលើការអនុវត្តឱ្យបានច្រើន ជាជាងការធ្វើផែនការរួចទុកវាចោល។ ឧទាហរណ៍អំពីសមាសភាពខុសៗគ្នានៅក្នុងដំណើរការធ្វើផែនការមានបង្ហាញជូននៅក្នុងដ្យាក្រាមខាងក្រោមនេះ។




**សូមកត់ចំណាំថា ការធ្វើផែនការតែងតែចាប់ផ្តើម និងបញ្ចប់ជាមួយនឹងការវិភាគបញ្ហា។**

**សិក្ខាសាលារៀនធ្វើផែនការ គួរមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។** អ្នកពាក់ព័ន្ធគួររួមបញ្ចូលនូវក្រុមទាំងឡាយដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។ ជាការចាំបាច់ណាស់ដែលត្រូវអញ្ជើញអ្នកពាក់ព័ន្ធឱ្យបានច្រើនគ្រប់គ្រាន់មកចូលរួមកិច្ចប្រជុំ "ចាប់ផ្តើមដំបូង" ដើម្បីពន្យល់ពីគោលបំណង និងដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍សាលារៀន ដូច្នោះសិក្ខាកាមទាំងអស់មានការយល់ដឹងជារួមមួយ និងដឹងអំពីអ្វីដែលពួកគេរំពឹងទុក។ ក្រោយមក អាចរៀបចំការប្រជុំជាបន្តបន្ទាប់ ដែលអាចធ្វើឡើងនៅថ្ងៃផ្សេងគ្នាបាន អាស្រ័យទៅលើភាពទំនេររបស់ក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នា។

**បញ្ជីរាយនាមអ្នកពាក់ព័ន្ធដែលអាចចូលរួមនៅក្នុងកិច្ចប្រជុំធ្វើផែនការអភិវឌ្ឍន៍សាលារៀន៖**

- នាយកសាលារៀន នាយករង
- គ្រូបង្រៀន
- SMC (គណៈកម្មការគ្រប់គ្រងសាលារៀន)
- សមាជិកសហគមន៍
- ឪពុកម្តាយសិស្សនៅក្នុងសាលារៀន
- បុគ្គលិកមណ្ឌលសុខភាព
- នគរបាល
- សិស្ស/កុមារមកពីក្នុងសហគមន៍
- អាជ្ញាធរមូលដ្ឋាន (មេភូមិ មេឃុំ តំណាងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារថ្នាក់ឃុំ (CCWC)។ល។)
- អ្នកដឹកនាំក្រុមសាសនា (ពុទ្ធសាសនិក មូស្លីម គ្រិស្តសាសនិក ។ល។)

**ពេលវេលាដែលត្រូវការសម្រាប់សិក្ខាសាលារៀនធ្វើផែនការ៖** ផែនការសាលារៀនជាក់ស្តែងមួយអាចចំណាយពេលជាច្រើនថ្ងៃដើម្បីបញ្ចប់វាបាន ហើយវានឹងទាមទារឱ្យមានអនុគណៈកម្មការនៃអ្នកពាក់ព័ន្ធទាំងឡាយដែលធ្វើការបន្តមកទៀត ដើម្បីបញ្ចប់គម្រោងពេលវេលា និងថវិកាលម្អិត។

**តម្រូវការពិនិត្យ និង អនុម័ត៖** ពេលផែនការបានបញ្ចប់ជាស្ថាពរ គួរបញ្ជូនទៅកាន់ការិយាល័យអប់រំស្រុកដើម្បីពិនិត្យ និងអនុម័ត។ ជានិច្ចកាលវាជាការសំខាន់ណាស់ដែលត្រូវជូនដំណឹងដល់ស្រុកអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងសាលារៀន។ ប្រសិនបើសាលារៀនរបស់អ្នកស្ថិតក្នុងគម្រោងប្រហែលជាត្រូវមានបុគ្គលម្នាក់មកពីគម្រោងចុះហត្ថលេខាផងដែរ។

**ការកំណត់ធនធានដែលត្រូវការក្នុងការអនុវត្តផែនការ៖** នៅពេលផែនការទទួលបានការអនុម័តរួច សាលារៀនអាចចាប់ផ្តើមកំណត់ពីតម្រូវការធនធានសម្រាប់ផែនការនោះ។ ធនធានទាំងនេះអាចបានមកពីគម្រោងថវិកាដំណើរការសាលារៀន ការចូលរួមវិភាគទានរបស់សហគមន៍ ឬផ្សំគ្នាទាំងពីរប្រភពនេះ។ ទោះបីថវិកាមានប្រភពមកពីធនធានណាមួយក៏ដោយ ត្រូវប្រើប្រាស់វាប្រកបដោយតម្លាភាពជានិច្ច។

**ការវាយតម្លៃផលជះនៃផែនការ៖** នៅចុងឆ្នាំសិក្សា សាលារៀនគួរវាយតម្លៃទៅលើផលជះនៃអន្តរាគមន៍ទាំងឡាយដែលបានអនុវត្តរួចមក។ ការវាយតម្លៃនេះ នឹងផ្តល់នូវចំណុចចាប់ផ្តើមសម្រាប់ការបង្កើតផែនការអភិវឌ្ឍន៍សាលារៀនថ្មីមួយសម្រាប់ឆ្នាំសិក្សាថ្មីខាងមុខទៀត។

## ឯកសារទី១៩៖ គោលការណ៍ទូទៅដើម្បីជួយរៀបចំដំណើរការធ្វើផែនការ៖[9]

1. **គុណភាពក្នុងចំណោមសមាសភាគខុសៗគ្នា៖** គោលនយោបាយសាលារៀនកុមារមេត្រីរបស់ក្រសួងអប់រំ អំពាវនាវសុំឱ្យមានការអនុវត្តសកម្មភាពលើសមាសភាគជាច្រើន។ ដូច្នេះជាការសំខាន់ណាស់ដែលឯកសារធ្វើផែនការត្រូវដាក់បញ្ចូលនូវសកម្មភាពឱ្យបានច្រើនមកពីគ្រប់សមាសភាគទាំងអស់មិនមែនមួយឬពីរទេ។
2. **រៀបចំអ្នកពាក់ព័ន្ធឱ្យទៅជាក្រុមដែលមានសមាសភាពដូចគ្នា៖** នៅក្នុងករណីជាច្រើន អ្នកពាក់ព័ន្ធមួយចំនួនមានទំនោរគ្របសង្កត់ទៅលើអ្នកពាក់ព័ន្ធដទៃទៀត។ ឧទាហរណ៍៖ គ្រូបង្រៀន និងសមាជិកសហគមន៍អាចនឹងមិនហ៊ានប្រឆាំងនឹងគំនិតយោបល់របស់នាយកសាលារៀនទេ ពីព្រោះនាយកសាលារៀនមានឋានៈសង្គមខ្ពស់ជាង។ នៅពេលអ្នកពាក់ព័ន្ធមិនបញ្ចេញយោបល់នៅក្នុងដំណើរការធ្វើផែនការ ពួកគេនឹងមានកម្មសិទ្ធិតិចតួចទៅលើផែនការសម្រេចចុងក្រោយ។ ដូច្នេះហើយមានការស្នើជាយោបល់ថា ពេលដែលត្រូវកំណត់រកបញ្ហា និងសកម្មភាពជាក្រុមតូចៗ អ្នកពាក់ព័ន្ធគួរអង្គុយជាក្រុមដែលមានសមាសភាពដូចគ្នា ពោលគឺអ្នកគ្រប់គ្រងសាលារៀនទាំងអស់ត្រូវអង្គុយជាមួយគ្នាមួយក្រុម សមាជិកសហគមន៍អង្គុយមួយក្រុមផ្សេង សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន (SMC) អង្គុយមួយក្រុមផ្សេងទៀត បុគ្គលិកមណ្ឌលសុខភាព និងនគរបាលអង្គុយមួយក្រុម។ល។ ការធ្វើបែបនេះនឹងជួយធានាបានថា អ្នកទាំងអស់គ្នាសម្តែងការយល់ឃើញរបស់ខ្លួនដោយសេរី។
3. **ការទាញកុមារ/សិស្សឱ្យចូលរួមនៅក្នុងដំណើរការធ្វើផែនការ៖** ជាការសំខាន់ និងចាំបាច់ណាស់ដែលត្រូវមានកុមារចូលរួមនៅក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍សាលារៀន (SIP)។ ទោះជាយ៉ាងណា ប្រសិនបើយើងគ្រាន់តែដាក់បញ្ចូលកុមារទៅក្នុងសិក្ខាសាលារៀនជាប្រចាំរបស់យើង ដែលមានមនុស្សពេញវ័យជាច្រើនអង្គុយជុំវិញតុនោះ វាអាចពុំមែនជាវិធីមួយដែលមានប្រសិទ្ធភាពក្នុងការទាញកុមារឱ្យចូលរួមឡើយ ពីព្រោះពួកគេអាចនឹងមានការភ័យខ្លាចក្នុងការប្រឆាំង ឬធ្វើឱ្យមនុស្សចាស់ជាងខ្លួនអាម៉ាស់មុខ។ ការធ្វើបែបនេះនឹងរារាំងពួកគេពីការបង្ហាញនូវការចូលរួមពិតប្រាកដ ដោយសារតែទំនៀមទម្លាប់មួយហៅថា "ក្រែងចិត្ត"។ វិធីល្អបំផុតក្នុងការទាញកុមារឱ្យចូលរួមនៅក្នុងដំណើរការធ្វើផែនការគឺ បើកសិក្ខាសាលារៀនកន្លះថ្ងៃដាច់ដោយឡែកមួយដែលមានតែកុមារប្រហែល ១៥ ទៅ ២០នាក់ចូលរួមប៉ុណ្ណោះ។ ជាការសំខាន់ណាស់ដែលថា អាជ្ញាធរសាលារៀន និងអាជ្ញាធរអប់រំមិនត្រូវចូលរួម ឬសម្របសម្រួលសិក្ខាសាលារៀនសម្រាប់កុមារឡើយ ដើម្បីឱ្យពួកគេអាចសម្តែងមតិយោបល់ផ្ទាល់ខ្លួនដោយពុំមានការភ័យខ្លាចចំពោះការផ្ចាញ់តបវិញ។ សាលារៀនគួរតែជ្រើសរើសគ្រូម្នាក់ ដែលគ្រាន់តែផ្តល់ការណែនាំជាទូទៅខ្លះៗដល់សិស្សអំពីការកំណត់រកបញ្ហា។ល។ នៅក្នុងសាលារៀនប៉ុន្តែបន្ទាប់មកទៀតទុកឱ្យពួកគេធ្វើការបែបម្ចាស់ការដោយគ្មានការត្រួតពិនិត្យពីគ្រូ។ សិក្ខាសាលារៀនសម្រាប់កុមារ គួរដាក់បញ្ចូលនូវការស្នើឱ្យពួកគេកំណត់ និងបញ្ចេញគំនិតយោបល់របស់ពួកគេអំពីលក្ខណៈរបស់ "សាលារៀនល្អ" ឬ "ការសិក្សាប្រកបដោយប្រសិទ្ធភាព" ឬ "ការឈានដល់សក្តានុពលរបស់ខ្ញុំ"។ សកម្មភាពអាចរួមមានដូចជា ការស្នើឱ្យសិក្ខាកាមជាកុមារគូររូបភាពមួយអំពីសាលារៀនល្អបំផុតរបស់ពួកគេ ការទាញឱ្យកុមារចូលរួមនៅក្នុងដំណើរការដូចគ្នានឹងដំណើរការ SIP ដែលមនុស្សពេញវ័យអនុវត្តដែរ ការបង្កលក្ខណៈឱ្យកុមារបង្កើតសាច់រឿងខ្លីមួយអំពីឧបសគ្គក្នុងការសិក្សានៅសាលារៀនពួកគេ។ល។

---

[9] ដកស្រង់ពី IBEC 2011, *Secondary School Planning Activity Menu: A Guide to promote stakeholder-driven development.* KAPE: Kampong Cham, Cambodia.

4. **កំណត់ចំនួនធនធានដែលមានសម្រាប់អនុវត្តផែនការរបស់អ្នក៖** ពិនិត្យឡើងវិញជាមួយនាយកសាលារៀនអំពីចំនួនថវិកាដែលពួកគេយល់ថាពួកគេមានសម្រាប់ផែនការរបស់ខ្លួន។ សាលារៀនមានធនធានមកពីប្រភពជាច្រើន (ឧ. រដ្ឋាភិបាល គម្រោង សហគមន៍។ល។) នោះផែនការអាចមានមហិច្ឆតាច្រើន។ ធនធានតិច (ឧ. ធនធានរដ្ឋាភិបាលតែមួយមុខ) អាចមានន័យថាផែនការមិនសូវមានមហិច្ឆតា។ ប្រសិនបើសាលារៀនកំណត់បន្ថែមទៀតថា ខ្លួនមានស្វ័យភាពច្រើនក្នុងការផ្លាស់ប្តូរទៅតាមគោលវិធីនៃការគ្រប់គ្រងតាមសាលារៀននោះសាលារៀននោះអាចនឹងមានមហិច្ឆតាកាន់តែច្រើន។ ចាប់ផ្តើមដំណើរការកំណត់ការរំពឹងទុក និងមហិច្ឆតានៃផែនការរបស់នរណាម្នាក់ដោយកំណត់លទ្ធភាពទទួលបានធនធានថវិការបស់អ្នក។
5. **កំណត់អាទិភាព៖** ជំហានវិភាគតម្រូវការ អាចនឹងលាតត្រដាងនូវចំណុចខ្វះខាតជាច្រើននៅក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពរបស់សាលារៀន។ ទោះជាយ៉ាងណា ដោយសារតែគ្មានចំនួនទឹកប្រាក់ ឬធនធានបច្ចេកទេសច្បាស់លាស់ដើម្បីជួយបំពេញចំណុចខ្វះខាតទាំងនោះគណៈគ្រប់គ្រងទ្រទ្រង់សាលារៀន និងអ្នកដទៃទៀតដែលចូលរួមក្នុងការបង្កើតផែនការអភិវឌ្ឍន៍សាលារៀន (SIP) នឹងត្រូវកំណត់អាទិភាព។ ដើម្បីជួយកំណត់អាទិភាពយកល្អគួរមាន "ទស្សនៈវែងឆ្ងាយ" (គិតរយៈពេល ៣ ទៅ ៥ ឆ្នាំ) ជាជាងការគិតតែអំពីឆ្នាំបច្ចុប្បន្ន។ ការកែលម្អជាច្រើននឹងកើតឡើងបន្តិចម្តងៗជាជំហានៗ។ ដូច្នេះអ្នកធ្វើផែនការត្រូវតែចងចាំទុកចំណុចនេះក្នុងចិត្តផងដែរ។
6. **ធានាថាគ្មានការត្រួតគ្នារវាងថវិកា៖** សាលារៀនអាចមានប្រភពថវិកាផ្សេងៗគ្នា។ សាលារៀនដែលទទួលថវិកាពីគម្រោង ឬម្ចាស់ជំនួយអភិវឌ្ឍន៍ពិសេស គួរប្រើធនធានហិរញ្ញវត្ថុទាំងនោះសម្រាប់ធ្វើសកម្មភាពដែលពុំអាចធ្វើទៅបានក្រោមគោលការណ៍ណែនាំពីក្រសួងអប់រំស្តីពីថវិកាដំណើរការសាលារៀន។ ដូច្នេះផែនការអភិវឌ្ឍន៍សាលារៀន (SIP) មិនគួរដាក់បញ្ចូលថវិកាទាំងឡាយណាដែលបានរ៉ាប់រងដោយថវិកាដំណើរការសាលារៀន (ឬគម្រោងពាក់ព័ន្ធផ្សេងៗរបស់រដ្ឋាភិបាល) រួចនោះទេ។ របស់ទាំងឡាយខាងក្រោមនេះ គឺជាឧទាហរណ៍អំពីការចំណាយផ្សេងៗដែលសាលារៀនទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ថវិកាដំណើរការសាលារៀនរបស់ខ្លួនដើម្បីរ៉ាប់រង៖ សួនផ្កា សម្ភារកីឡា សម្ភារៈសិល្បៈ ដងទង់ជាតិ ក្លោងទ្វារសាលារៀន និងសម្ភារការិយាល័យសាលារៀន។ ដូច្នេះ គ្មានរបស់ណាមួយក្នុងចំណោមរបស់ទាំងនេះគួរត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីថវិកា ឬសកម្មភាព SIP ឡើយ។
7. **ការចុះហត្ថលេខាដែលចាំបាច់៖** ផែនការអភិវឌ្ឍន៍សាលារៀនដែលបានបង្កើតក្នុងមូលដ្ឋាន គួរតែមានការចុះហត្ថលេខាពីការិយាល័យអប់រំស្រុក (DoE) ដើម្បីធានាថា អាជ្ញាធរថ្នាក់ស្រុកបានដឹងអំពីលក្ខណៈនៃការវិនិយោគទាំងឡាយដែលនឹងត្រូវធ្វើឡើងនៅក្នុងសាលារៀន ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។
8. **បិទផ្សាយផែនការជាសាធារណៈ៖** នៅពេលផែនការអភិវឌ្ឍន៍សាលារៀនបានបញ្ចប់សព្វគ្រប់ហើយ ជាការសំខាន់ណាស់ ដែលត្រូវឱ្យសាលារៀនតាំងបង្ហាញផែនការនៅលើក្រដាសផ្ទាំងធំមួយក្នុងទីចាត់ការ។ ការធ្វើបែបនេះ នឹងជួយធានាថាមានតម្លាភាពអំពីសកម្មភាពអ្វីខ្លះដែលនឹងត្រូវធ្វើ នរណាជាអ្នកទទួលបន្ទុករៀបចំវា និងចំនួនថវិកាដែលបានចាត់ចែងសម្រាប់ការអនុវត្តសកម្មភាពនីមួយៗ។ ជាការល្អផងដែរ ក្នុងការបិទផ្សាយផែនការអភិវឌ្ឍន៍សាលារៀននៅតាមទីសាធារណៈផ្សេងៗ ដើម្បីឱ្យសហគមន៍ទាំងមូលបានដឹងអំពីខ្លឹមសារ និងថវិកាសម្រាប់ការកែលម្អការអប់រំ និងធ្វើឱ្យការសិក្សាប្រសើរឡើងក្នុងសាលារៀនរៀនពួកគេ។

## ឯកសារទី២០៖ ការបង្ហាញពីរបៀបធ្វើផែនការតាមក្របខ័ណ្ឌតក្ក (វិធីសមហេតុផល)

### តើអ្នកបានដឹងច្រើនប៉ុនណាអំពីការធ្វើផែនការតាមក្របខ័ណ្ឌតក្ក?

**ចូរអានសំណួរខាងក្រោម និងបញ្ជាក់ពីចំណេះដឹង ឬយោបល់អ្នកជាមួយនឹងចម្លើយសមស្របមួយ។**

1. តើអ្នកធ្លាប់ឮអំពីក្របខ័ណ្ឌតក្កពីមុនមកដែរឬទេ?

   ☐ បាទ/ចាស៎ ☐ ទេ

2. តើអ្នកយល់ថា ក្របខ័ណ្ឌតក្កគឺជាគោលវិធីថ្មីមួយក្នុងការធ្វើផែនការដែរឬទេ?

   ☐ បាទ/ចាស៎ ☐ ទេ

3. តើសាលារៀនអ្នកប្រើប្រាស់ក្របខ័ណ្ឌតក្កនៅក្នុងការធ្វើផែនការរបស់ខ្លួនដែរឬទេ?

   ☐ បាទ/ចាស៎ ☐ ទេ

នៅក្នុងក្រុមអ្នក ចូររៀបជាតារាងនូវចម្លើយរបស់អ្នករាល់គ្នាឱ្យបានឆាប់រហ័សដោយបំពេញតារាងខាងក្រោម។ ចូរបញ្ជាក់នូវចំនួនមនុស្សក្នុងក្រុមអ្នក ដែលឆ្លើយថា "បាទ/ចាស៎" ឬ "ទេ" ចំពោះសំណួរនីមួយៗ។

| **លេខសំណួរ** | **បាទ/ចាស៎** | **ទេ** |
|---|---|---|
| សំណួរទី ១ | | |
| សំណួរទី ២ | | |
| សំណួរទី ៣ | | |

*ពិនិត្យមើលចម្លើយរបស់អ្នកនៅក្នុងក្រុមធំ។ រាយការណ៍ចម្លើយរបស់អ្នកទៅកាន់អ្នកសម្របសម្រួល។*

### តើវិធីធ្វើផែនការតាមក្របខ័ណ្ឌតក្កគឺជាអ្វី?

**ក្របខ័ណ្ឌតក្ក** គឺជាឧបករណ៍មួយសម្រាប់កែលម្អការធ្វើផែនការ ការអនុវត្ត ការគ្រប់គ្រង ការត្រួតពិនិត្យ និងការវាយតម្លៃគម្រោង។ **ក្របខ័ណ្ឌតក្ក** គឺជាមធ្យោបាយក្នុងការរៀបចំរចនាសម្ព័ន្ធសមាសភាព**សំខាន់ៗ**នៅក្នុងគម្រោង និងគូសបញ្ជាក់នូវ**ទំនាក់ទំនងតក្ក**រវាងពួកវា។

### ទិដ្ឋភាពសំខាន់ៗមួយចំនួននៃក្របខ័ណ្ឌតក្កដែលខុសប្លែកពីផែនការផ្សេងៗ

- ផែនការតាមក្របខ័ណ្ឌតក្ក ពុំមែនគ្រាន់តែជាបញ្ជីសកម្មភាពនៅក្នុងគម្រោងពេលវេលាមួយនោះឡើយ។ សកម្មភាពនីមួយៗត្រូវតែមានលក្ខណៈ "បែបតក្ក" ដោយមានទំនាក់ទំនងវាជាមួយនឹងវត្ថុបំណងមួយ។
- ផែនការតាមក្របខ័ណ្ឌតក្ក តែងតែចាប់ផ្ដើមជាមួយនឹងការវិភាគបញ្ហាមួយ។
- រាល់ផែនការតាមក្របខ័ណ្ឌតក្កមានបញ្ហារួមតែ**មួយ** និងមានវត្ថុបំណង ឬគោលដៅរួមតែ**មួយ**ប៉ុណ្ណោះ ។
- ធាតុនីមួយៗនៅក្នុងផែនការក្របខ័ណ្ឌតក្ក មានទំនាក់ទំនងបែបតក្កដូចតទៅ៖

| បញ្ហា ➔ | វត្ថុបំណង ➔ | សកម្មភាព ➔ | ធនធាន ➔ | សូចនាករ |
|---|---|---|---|---|
| ជួយកំណត់វត្ថុបំណងបែបតក្ក | ជួយកំណត់សកម្មភាពបែបតក្ក | ជួយគាំទ្រវត្ថុបំណងបែបតក្ក | គាំទ្រសកម្មភាពបែបតក្ក | ជួយវាយតម្លៃវត្ថុបំណងបែបតក្ក |

# ឯកសារទី២១៖ ការវិភាគបញ្ហា

## ១. ទំនាក់ទំនងរវាងបញ្ហា និងវត្ថុបំណង

- ចូរពិចារណាអំពីសំណួរសម្មតិកម្មខាងក្រោម៖ តើអាចមានវត្ថុបំណងនៅក្នុងសាលារៀនមួយដែរឬទេ ប្រសិនបើគ្មានបញ្ហាអ្វីមួយសោះ។ ប្រសិនបើមានសាលារៀនបែបនេះមែន វាអាចនឹងពិបាកក្នុងការបង្កើតវត្ថុបំណងពីព្រោះតាមធម្មតា វត្ថុបំណងតែងតែតម្រង់ទិសទៅរកការដោះស្រាយបញ្ហា។ តាមពិតវត្ថុបំណងមួយគឺជាពាក្យផ្ទុយនៃបញ្ហាមួយ – *វាគឺជាការបំប្លែងពីលក្ខខណ្ឌអវិជ្ជមានទៅជាវិជ្ជមាន។* សូមមើលឧទាហរណ៍ខាងក្រោមនេះ។

*ឧទាហរណ៍៖*

| <u>*បញ្ហា*</u> | | <u>*វត្ថុបំណង*</u> |
|---|---|---|
| **សិស្សពុំមានសៀវភៅសិក្សាគោល** | ⟶ | **សិស្សមានសៀវភៅសិក្សាគោល** |

- ផ្អែកលើបន្ទាត់ផ្តល់ហេតុផលនេះ យើងអាចសន្និដ្ឋានបានថាការសរសេរវត្ថុបំណងនៅក្នុងផែនការប្រចាំឆ្នាំជាដំបូងគួរតែផ្អែកលើការយល់ឱ្យបានច្បាស់លាស់ថាតើមានបញ្ហាអ្វីខ្លះ។

## ២. ការវិភាគបញ្ហា

ចូរពិចារណាអំពីសំណួរមួយទៀត៖ តើបញ្ហាទាំងអស់សុទ្ធតែដូចគ្នាដែរឬទេ? ផ្អែកលើបទពិសោធន៍ក្នុងជីវិតជាក់ស្តែងរបស់យើងបញ្ហាទាំងអស់ពិតជាមិនដូចគ្នាទេ។ បញ្ហាខ្លះអាចសំខាន់ជាងបញ្ហាផ្សេងទៀត បញ្ហាខ្លះអាចជាហេតុ ហើយបញ្ហាខ្លះទៀតអាចជាផល ហើយបញ្ហាមួយចំនួនទៀតអាចជាហេតុ និងផលក្នុងពេលតែមួយ។

ដើម្បីជួយដល់យើងក្នុងការញែកបញ្ហា ពេលខ្លះអ្នកធ្វើផែនការធ្វើអ្វីមួយដែលហៅថា **ការវិភាគបញ្ហា**។ ការវិភាគបែបនេះ គឺជាការព្យាយាមភ្ជាប់ទំនាក់ទំនងតាមរបៀបមួយដែលបង្ហាញឱ្យឃើញនូវហេតុ និងផលរបស់វា។ នៅក្នុងការវិភាគបែបនេះ យើងត្រូវតែចាប់ផ្តើមជាមួយនឹងអ្វីដែលយើងហៅថា**បញ្ហាស្នូល** ដែលជាធម្មតាមានតែ "មួយ" ប៉ុណ្ណោះនៅក្នុងផែនការមួយ។ តាមឈ្មោះរបស់វាស្រាប់បញ្ហាស្នូលគឺជាបញ្ហារួមបំផុតនៅក្នុងបរិបទណាមួយ។ វាគឺជាបញ្ហាទៅកាន់ចំណុចបញ្ហាជាហេតុ ហើយបានមកពីបញ្ហារយៈពេលវែងជាច្រើន។

**ជំហានទី ១** (ស្វែងរកបញ្ហាស្នូល)៖ ជំហានដំបូងក្នុងការវិភាគបញ្ហា តម្រូវឱ្យយើងស្វែងរកបញ្ហាស្នូលមួយ។ សិក្ខាកាមទាំងអស់នៅក្នុងអង្គប្រជុំ ត្រូវតែឯកភាពគ្នាទៅលើបញ្ហាស្នូល**មួយ។** ដំបូងអាចនឹងមានយោបល់ជាច្រើនអំពីអ្វីដែលជាបញ្ហាធំជាងគេ និងជាបញ្ហារួមជាងគេនៅក្នុងសហគមន៍។ ឧបមាថា មេឃុំមួយក្រុមកំពុងតែប្រជុំដើម្បីបង្កើតការវិភាគបញ្ហាមួយអំពីបញ្ហាសំខាន់ៗដែលកសិករប្រឈម ។ មេឃុំនៅក្នុងមជ្ឈដ្ឋានសម្មតិកម្មនេះ អាចលើកយកបញ្ហាធំៗពីរដូចតទៅ៖

- កសិករមានជីវភាពក្រីក្រ
- ការប្រមូលផលស្រូវបានតិចតួច

| |
|---|
| កសិករមានជីវភាពក្រីក្រ |
| ↑ |
| ការប្រមូលផលស្រូវបានតិចតួច |

នៅក្នុងការវិភាគទំនាក់ទំនងរវាងបញ្ហាទាំងពីរនេះ ដើម្បីស្វែងរកបញ្ហាស្នូលមួយបុគ្គលទាំងឡាយដែលបង្កើតផែនការនោះអាចសួរខ្លួនឯងនូវសំណួរដូចតទៅ "តើអ្វីដែលមកដល់មុន៖ តើការប្រមូលផលស្រូវបានតិចតួច ធ្វើឱ្យកសិករមានជីវភាពក្រីក្រ ឬការមានជីវភាពក្រីក្របណ្ដាលឱ្យការប្រមូលផលស្រូវបានតិចតួច?" វិធីដែលមានតក្កបំផុតក្នុងការរៀបចំបញ្ហាទាំងនេះ អាចជាការយកការប្រមូលផលស្រូវបានតិចតួចធ្វើជាបញ្ហាជាហេតុ ដែលនាំឱ្យមានផល ពីព្រោះប្រាក់ចំណូលរបស់កសិករពឹងផ្អែកទៅលើការបង្កបង្កើនផលស្រូវ។ ទោះជាយ៉ាងណាវាក៏សំខាន់ផងដែរដែលអ្នករាល់គ្នាត្រូវឯកភាពគ្នាថានេះគឺជាទំនាក់ទំនងគ្នារវាងបញ្ហា។ នេះមានន័យថា ការវិភាគបញ្ហានៅក្នុងក្រុមមួយត្រូវតែគ្រប់គ្រងដោយ**មតិរួម**មួយ មិនមែនដោយនរណាម្នាក់ដែលប្រាប់អ្នកដទៃទៀតនូវអ្វីដែលពួកគេគួរធ្វើ ឬគិតទេ។ ប៉ុន្តែការប្រើតក្កជាវិធីដ៏ល្អមួយក្នុងការកសាងមតិរួម។

**ជំហានទី ២ (ស្វែងរកបញ្ហាជាហេតុ)៖** នៅពេលក្រុមមួយបានឯកភាពគ្នាទៅលើបញ្ហាស្នូលរួចហើយ ជំហានបន្ទាប់នៅក្នុងការវិភាគបញ្ហាគឺ កំណត់បញ្ហាជាហេតុផ្សេងៗ ដែលនាំឱ្យមានបញ្ហាស្នូលនោះ។ សិក្ខាកាមនៅក្នុងកិច្ចប្រជុំធ្វើផែនការអាចនឹងរកឃើញបញ្ហាជាសម្មតិកម្មមួយចំនួនខាងក្រោម ជាផ្នែកនៃការវិភាគបញ្ហា (សូមមើលខាងក្រោម)។ អាចសរសេរបញ្ហាទាំងនេះលើប័ណ្ណ ដើម្បីឱ្យវាអាចងាយស្រួលក្នុងការសម្របសម្រួលការបង្កើតដ្យាក្រាមដូចមានបង្ហាញខាងក្រោមនេះ។

- ដីខ្សត់ជីវជាតិ
- ទឹកជំនន់
- ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់
- ជំងឺ និងសត្វល្អិតចង្រៃ
- កសិករខ្វះចំណេះដឹងអំពីការអនុវត្តកសិកម្មល្អៗ
- គ្មានប្រព័ន្ធស្រោចស្រព
- គ្មានទុនក្នុងការទិញជី និងថ្នាំសម្លាប់សត្វល្អិត

**ជំហានទី ៣ (រៀបចំបញ្ហាទាំងអស់ទៅជាដើមឈើបញ្ហាមួយ)៖** បន្ទាប់ពីបានបង្កើតបញ្ជីនេះរួចហើយ ជំហានបន្ទាប់ និងចុងក្រោយនៅក្នុងការវិភាគបញ្ហាគឺ ព្យាយាមរៀបចំបញ្ហាទាំងនេះទៅជាបំប្លែងដ្យាក្រាមមួយ ដែលហេតុស្ថិតនៅខាងក្រោម ចំណែកផលស្ថិតនៅខាងលើ។ សូមមើលឧទាហរណ៍ដែលផ្ដល់ជូនខាងក្រោមនេះ។

## ឧទាហរណ៍អំពីដើមឈើបញ្ហា




ដ្យាក្រាមបង្ហាញលទ្ធផលនេះហៅថា **ដើមឈើបញ្ហា** ។ នៅពេលអានដើមឈើបញ្ហាមួយ យើងតែងតែអានវាពីផ្នែកខាងក្រោម (ពោលគឺ ចាប់ពីហេតុ) ទៅផ្នែកខាងលើ (ពោលគឺ ផល)។ ចូរកត់ចំណាំថា អាស្រ័យលើទំនាក់ទំនងរបស់វាទៅវិញទៅមក បញ្ហាអាចជាហេតុ ឬអាចជាផល។ ឧទាហរណ៍ "ទឹកជំនន់" អាចជា **ផល** នៃ "ការពុំមានប្រព័ន្ធធារាសាស្ត្រ" ប៉ុន្តែទាក់ទងនឹង "ការប្រមូលផលស្រូវបានតិចតួច" ទឹកជំនន់អាចជា **ហេតុ** វិញ។

## ឯកសារទី ២២៖ ការវិភាគវត្ថុបំណង

### ១. និយមន័យនៃវត្ថុបំណង៖

នៅពេលអ្នកបានបញ្ចប់ការវិភាគបញ្ហាមួយរួចហើយ ការវិភាគវត្ថុបំណងមានភាពងាយស្រួល ពីព្រោះវត្ថុបំណងគ្រាន់តែជាលក្ខខណ្ឌផ្ទុយនៃបញ្ហាមួយប៉ុណ្ណោះ។ ដូច្នេះយើងកំណត់វត្ថុបំណងមួយជា**លក្ខខណ្ឌវិជ្ជមាន**ដែលចង់បានមួយដែលយើងចង់សម្រេចបាននៅក្នុងផែនការរបស់យើង។ ចូរកត់ចំណាំថា សម្រាប់គោលបំណងនៃការធ្វើផែនការផ្តែកលើតម្រូវការយើងបញ្ជាក់វត្ថុបំណងថាជាលក្ខខណ្ឌ និងពុំចាំបាច់ប្រើកិរិយាសព្ទទាំងឡាយដូចជា បង្កើន កែលម្អ ។ល។ ជាវាក្យសព្ទដំបូងឡើយ។

### ២. ការវិភាគវត្ថុបំណង៖

ការវិភាគវត្ថុបំណង ទាមទារឱ្យយើងផ្លាស់ប្តូរបញ្ហានីមួយៗនៅក្នុងដើមឈើបញ្ហាឱ្យទៅជាលក្ខខណ្ឌវិជ្ជមាន ឬជាលក្ខខណ្ឌផ្ទុយមួយ។ ឧទាហរណ៍ ក្រឡេកមើលបញ្ហាទាំងឡាយពីគំរូដើមឈើបញ្ហារបស់យើងនៅក្នុងមេរៀនពីមុន។ តើអ្នកនឹងផ្លាស់ប្តូរបញ្ហានីមួយៗទាំងនេះឱ្យទៅជាលក្ខខណ្ឌវិជ្ជមានដោយរបៀបណា? មានឧទាហរណ៍មួយចំនួនសម្រាប់អ្នករួចហើយ។ ចូរបំពេញអ្វីដែលនៅសេសសល់ក្នុងតារាងជាក្រុមធំ។

### ៣. លំហាត់ក្រុមធំ

**ការបំប្លែងបញ្ហាឱ្យទៅជាវត្ថុបំណង៖** ចូរបំពេញតារាងខាងក្រោមដោយផ្លាស់ប្តូរបញ្ហានីមួយៗឱ្យទៅជាលក្ខខណ្ឌវិជ្ជមានមួយ ដែលយើងហៅថាវត្ថុបំណង។

| **បញ្ហា** ➔ ➔ ➔ | **វត្ថុបំណង** |
|---|---|
| 1. កសិករមានជីវភាពក្រីក្រ | កសិករមានជីវភាពសម្បូរសប្បាយ |
| 2. ការប្រមូលផលស្រូវបានតិចតួច | ការប្រមូលផលស្រូវបានច្រើន |
| 3. ដីខ្សត់ជីវជាតិ | |
| 4. ទឹកជំនន់ | |
| 5. ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់ | |
| 6. ជំងឺ និងសត្វល្អិតចង្រៃ | |
| 7. កសិករខ្វះចំណេះដឹងអំពីការអនុវត្តកសិកម្មល្អៗ | |
| 8. គ្មានប្រព័ន្ធធារាសាស្ត្រ | |
| 9. គ្មានទុនទិញជី និងថ្នាំសម្លាប់សត្វល្អិត | |

### ៤. ការបំប្លែងដើមឈើបញ្ហាឱ្យទៅជាដើមឈើវត្ថុបំណងមួយ៖

នៅពេលអ្នកបានបំពេញតារាងខាងលើរួចហើយ ឥឡូវនេះអ្នកត្រូវត្រៀមខ្លួនក្នុងការផ្លាស់ប្តូរការវិភាគបញ្ហាដែលអ្នកបានធ្វើពីមុននេះឱ្យទៅជាការវិភាគវត្ថុបំណងមួយ។ ចូរបំប្លែងបញ្ហានីមួយៗនៅក្នុងដើមឈើបញ្ហាឱ្យទៅជាវត្ថុបំណងមួយដោយប្រើការបំប្លែងទាំងឡាយដែលអ្នកទើបតែបានបំពេញនៅក្នុងតារាងខាងលើ។

**ដើមឈើបញ្ហា ដែលបំពេញរួច នឹងមើលទៅឃើញមានរូបរាងដូចដ្យាក្រាមខាងក្រោមនេះ៖**




## ៥. ការអានដើមឈើវត្ថុបំណង៖

ដូចគ្នានឹងបញ្ហាដើមឈើដែរ យើងអានដើមឈើវត្ថុបំណងពីខាងក្រោមទៅលើ។ នេះមានន័យថា ការសម្រេចវត្ថុបំណងនៅផ្នែកខាងក្រោមនៃដើមឈើ នឹងបណ្តាលឱ្យ ឬបង្កលក្ខណៈឱ្យសម្រេចបាននូវវត្ថុបំណងនៅផ្នែកខាងលើ។ ការអានដើមឈើវត្ថុបំណងតាមវិធីនេះ ក៏ជាវិធីល្អមួយក្នុងការពិនិត្យមើលតក្កនៃដ្យាក្រាម និងធ្វើការផ្លាស់ប្តូរទៅតាមនោះផងដែរ។ ដូចគ្នានេះដែរ នៅពេលពិនិត្យមើលដើមឈើវត្ថុបំណងត្រូវប្រាកដថាបានពិនិត្យមើលថាតើវត្ថុបំណងមានឃ្លោងឃ្លាជាវាក្យសព្ទដែលអាចសម្រេចបានដែរឬទេ។ ឧទាហរណ៍ វត្ថុបំណងមួយដែលថ្លែងថា "ពុំមានការបោះបង់ការសិក្សា" ប្រាកដជាពុំអាចសម្រេចបានឡើយ។

## ៦. ប្រភេទនៃវត្ថុបំណង

ជាចុងក្រោយ យើងត្រូវកត់ចំណាំថា ដើមឈើវត្ថុបំណងតំណាងឱ្យឋានានុក្រមនៃវត្ថុបំណងទាំងឡាយដែលរួមមានជាអាទិ៍ដូចជា **វត្ថុបំណងរយៈពេលវែង វត្ថុបំណងរយៈពេលខ្លី** និង**ធាតុចេញ**។ ទោះបីជាយើងអាចហៅវាជាឈ្មោះខុសៗគ្នាក៏ដោយ ក៏វានៅតែជាវត្ថុបំណងដដែល។ ទោះបីជាយើងមិនដាក់បញ្ចូលវត្ថុបំណងខាងក្រោមធាតុចេញរបស់យើងនៅក្នុងផែនការជាក់ស្តែងក៏ដោយវានៅតែសំខាន់ពីព្រោះវាផ្តល់ជាយោបល់នូវយុទ្ធសាស្ត្រ និងសកម្មភាពល្អៗដើម្បីសម្រេចធាតុចេញបាន។ ចូរកត់ចំណាំថាជាធម្មតាយើងយកជួរទីមួយនៃវត្ថុបំណងនៅក្រោមវត្ថុបំណងរយៈពេលខ្លីជាធាតុចេញ ដោយសារហេតុផលពីរយ៉ាង។ ទីមួយវត្ថុបំណងទាំងអស់នៅក្រោមវា សុទ្ធតែបានបញ្ចូលនៅក្រោមធាតុចេញនីមួយៗរួច។ ទីពីរវាជួយកំណត់ចំនួនសូចនាករដែលយើងត្រូវតែសរសេរ ពីព្រោះចាំបាច់ត្រូវសរសេរសូចនាករនៅ និងលើសពីកម្រិតធាតុចេញ។

## ឯកសារទី២៣៖ គោលការណ៍ណែនាំសម្រាប់សរសេរសកម្មភាព

### ១. របៀបសរសេរសកម្មភាព

- សម្រាប់គោលបំណងនៃលំហាត់ធ្វើផែនការនេះ សកម្មភាពមានន័យថាជាអន្តរាគមន៍នានាដែលបង្កើតឡើងដើម្បីនាំមកនូវលក្ខខណ្ឌ ឬដំណោះស្រាយបញ្ហាដែលចង់បានមួយ។
- ផ្អែកតាមនិយមន័យនេះ សកម្មភាពគួរត្រូវបានចាប់ជាដៃគូជាមួយនឹងវត្ថុបំណង ឬលក្ខខណ្ឌដែលវាត្រូវបានអនុវត្តនៅក្នុងតារាងម៉ាទ្រិចផែនការ។ **ចូរចងចាំថា** យើងត្រូវធ្វើតែសកម្មភាពសម្រាប់សកម្មភាពទាំងឡាយណាដែលយើងហៅថា**ធាតុចេញ**ប៉ុណ្ណោះ។ ដូច្នេះយើងមិនត្រូវបង្កើតសកម្មភាពសម្រាប់វត្ថុបំណងរយៈពេលវែង ឬវត្ថុបំណងរយៈពេលខ្លីឡើយ។
- មុននឹងសរសេរសកម្មភាពជាក់ស្តែង អ្នកធ្វើផែនការគួរសង្កេតមើលគោលការណ៍ណែនាំទូទៅខ្លះៗសិន។
  1. **ទីមួយ** សកម្មភាពគួរចាប់ផ្តើមជាមួយនឹងកិរិយាសព្ទ។
  2. **ទីពីរ** នៅក្នុងការប្រើប្រាស់ពាក្យសកម្មភាព មានកិរិយាសព្ទមួយចំនួនដែលសិក្ខាកាមគួរតែចៀសវាង។ កិរិយាសព្ទទាំងនេះរួមមានដូចជា *ពង្រឹង កែលម្អ ផ្តល់ជំបូន្មាន លើកទឹកចិត្ត ស្នើជាយោបល់ ជួយ* និង *ផ្សព្វផ្សាយ* ជាដើម។ នៅពេលប្រើប្រាស់ពាក្យទាំងនេះ វាធ្វើឱ្យសកម្មភាពមានភាពស្រពិចស្រពិលពេក ហើយពុំជួយដល់អ្នកអនុវត្តបានដឹងច្បាស់អំពីអ្វីដែលពួកគេត្រូវធ្វើឡើយ។ ដូច្នេះគួរតែចៀសវាងការប្រើប្រាស់ពាក្យទាំងនេះទោះជាមានរឿងអ្វីកើតឡើងក៏ដោយ។
  3. ខាងក្រោមនេះ គឺជាបញ្ជីពាក្យសមស្របដែលប្រើប្រាស់នៅពេលសរសេរសកម្មភាព៖

| ពាក្យសកម្មភាពដែលមានប្រយោជន៍ | | | |
|---|---|---|---|
| បណ្តុះបណ្តាល | ធ្វើ | បង្កើត | ស្ទង់មតិ |
| ជួប | រាយបញ្ជី | រៀបចំ | ទិញ |
| ចែកចាយ | កសាង | សរសេរ | ផលិត |
| ផ្តល់ជូន | ជ្រើសរើស | អភិវឌ្ឍ | គ្រោងពេលវេលា |
| ត្រួតពិនិត្យ | កំណត់/កំណត់រក | ដំឡើង | ប្រមូលផ្តុំ |
| ធ្វើផែនការ | ស្វែងរក | ប្រព្រឹត្ត | កត់ត្រា |

### ២. ការសរសេរសកម្មភាពជាក់ស្តែង៖ លំហាត់

**ការណែនាំ៖** ចូរអានបញ្ជីធាតុចេញខាងក្រោម និងកំណត់រកសកម្មភាពសមស្របមួយ ឬច្រើនដើម្បីធ្វើឱ្យដំណោះស្រាយសម្រេចទៅបាន។

| ធាតុចេញ | សកម្មភាពសមស្រប |
|---|---|
| 1. ការសិក្សារបស់កុមារមានភាពប្រសើរឡើង។ | |
| | |
| 2. កុមារបោះបង់ការសិក្សាមានតិចជាងមុន។ | |
| | |

| ធាតុចេញ | សកម្មភាពសមស្រប |
|---|---|
| 3. សាលារៀនកាន់តែមានភាពទាក់ទងជាមួយនឹងតម្រូវការប្រចាំថ្ងៃរបស់កុមារ។ | |
| | |
| 4. មានកុមារកាន់តែច្រើនដែលមានលទ្ធភាពចូលរៀននៅសាលារៀនមធ្យមសិក្សា | |
| | |
| 5. ចំនួនសិស្សតាមថ្នាក់រៀនមិនសូវណែនណាន់តាន់តាប់ដូចកាលពីមុន | |
| | |
| 6. បន្ទប់វិទ្យាសាស្ត្រមានអត្រាប្រើប្រាស់ខ្ពស់។ | |
| | |
| 7. គ្រូមានឱកាសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | |
| | |
| 8. គ្រូប្រើប្រាស់ ICT សកម្មជាងមុនក្នុងការបង្ហាត់បង្រៀនរបស់ពួកគេ។ | |
| | |

## ឯកសារទី២៤៖ ការផ្តល់ប្រភពធនធានសម្រាប់ធ្វើផែនការ

### ១. ប្រភេទធនធាន

ធនធានដែលត្រូវការដើម្បីអនុវត្តផែនការ អាចបរិយាយតាមវិធីជាច្រើន។ ប្រភេទធនធានមានលក្ខណៈខុសគ្នា ហើយជួនកាលត្រួតគ្នា។ ធនធានមួយចំនួនមានរាយបញ្ជីខាងក្រោមនេះ។ ចូររកឧទាហរណ៍អំពីប្រភេទនៃធនធាននីមួយៗដែលបានដកស្រង់។

| ប្រភេទធនធាន | | ឧទាហរណ៍ |
|---|---|---|
| ឯកសារ | ❖ | ❖<br>❖ |
| បច្ចេកទេស | ❖ | ❖<br>❖ |
| មនុស្ស | ❖ | ❖<br>❖ |
| ពេលវេលា | ❖ | ❖<br>❖ |
| ហិរញ្ញវត្ថុ | ❖ | ❖<br>❖ |
| សម្ភារ | ❖ | ❖<br>❖ |

### ២. ទម្រង់ដែលត្រូវប្រើក្នុងការបង្ហាញអំពីធនធាននៅក្នុងផែនការ

សម្រាប់គោលបំណងនៃលំហាត់ធ្វើផែនការនេះ អ្នកធ្វើផែនការអាចនឹងបង្ហាញឱ្យឃើញធនធានតាមទម្រង់មួយក្នុងចំណោមទម្រង់ទាំងពីរ។ ទម្រង់ដ៏សាមញ្ញមួយដែលអាចប្រើក្នុងការបរិយាយអំពីធនធានដែលត្រូវការប្រើប្រាស់*ល្បះបរិយាយខ្លីមួយអំពីប្រភេទនៃធនធាន* ដូចជាល្បះដែលមានបង្ហាញនៅក្នុងបញ្ជីសកម្មភាពដែលមានពន្យល់មកពីខាងដើម។ នៅក្នុងទម្រង់នេះ យើងគិតអំពីធនធានក្នុងន័យប្រភេទទាំងឡាយដែលមានរៀបរាប់នៅក្នុងតារាងខាងលើ។

ទម្រង់មួយផ្សេងទៀត ដែលប្រើសម្រាប់បរិយាយអំពីធនធានដែលត្រូវការ មានលក្ខណៈលម្អិតជាងនេះ ហើយប្រើប្រាស់*រូបមន្តជាក់លាក់* ដែលបង្ហាញឱ្យឃើញនូវតម្រូវការធនធានជាវាក្យសព្ទរូបិយវត្ថុ។ មានឧទាហរណ៍មួយផ្តល់ជូននៅខាងក្រោម៖

| ធនធានដែលត្រូវការ | ចំនួនឯកតា | ម៉ោង/ថ្ងៃ/ខែ | អត្រា | សរុប ($) |
|---|---|---|---|---|
| គ្រូបង្រៀនមកពីតាមសហគមន៍ | ១០ | ៣០ ថ្ងៃ | $១/ថ្ងៃ | $៣០០.០០ |
| សៀវភៅសរសេរ | ៥០០ | -- | $០.៥០/ក្បាល | $២៥០.០០ |

| | | | | |
|---|---|---|---|---|
| ។ល។ | | | | |

នៅពេលអ្នកធ្វើផែនការបង្ហាញឱ្យឃើញនូវធនធានដែលត្រូវការតាមរបៀបនេះ ពួកគេត្រូវតែបញ្ជាក់អំពីចំនួនឯកតា ម៉ោង/ថ្ងៃ/ខែដែលត្រូវការ និងអត្រាសម្រាប់ឯកតានីមួយៗ ដើម្បីគណនាចំនួនថវិកាសរុបដែលត្រូវការសម្រាប់វាយមុខជាក់លាក់ណាមួយ។ សូមកត់ចំណាំថា អាស្រ័យលើវាយមុខដែលត្រូវការ វាពុំមែនចាំបាច់ត្រូវតែបញ្ជាក់ពេលវេលាដើម្បីគណនាចំនួនទឹកប្រាក់ដែលត្រូវការឡើយ។

## ឯកសារទី ២៥៖ តារាងម៉ាទ្រិចផែនការតាមក្របខ័ណ្ឌតក្ក

នៅពេលរៀបចំផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក សូមប្រើតារាងម៉ាទ្រិចមួយដែលមើលទៅដូចគ្នានឹងតារាងខាងក្រោមនេះ។ វត្ថុបំណង ជាតុចេញ សកម្មភាពទាំងអស់របស់អ្នក ។ល។ អាចមានភាពងាយស្រួលក្នុងការដាក់ទៅតាមក្រឡាសមស្របដែលមានផ្តល់ជូនខាងក្រោមនេះ។

<table>
<tr><td>វត្ថុបំណងរយៈពេលវែង</td><td>សូចនាករ</td><td rowspan="3">កត្តាខាងក្រៅ (ជម្រើស)<br>កត្តាខាងក្រៅ សំដៅទៅលើបណ្តាលក្ខខណ្ឌទាំងឡាយ ដែលយើងពុំអាចគ្រប់គ្រងបាន ប៉ុន្តែអាចប៉ះពាល់ដល់ការអនុវត្តផែនការ។ កត្តាខាងក្រៅហៅថា ការសន្មត់បែប "វិជ្ជមាន" ដែលអាចពិតឬមិនពិត។ ឧទាហរណ៍៖<ul><li>សាលារៀននឹងមិនត្រូវបានរំខានដោយជំងឺកូវីត-១៩ ទេ។</li><li>ទឹកជំនន់នឹងមិនអូសបន្លាយការបើកសាលារៀនយូរពេកទេ។</li><li>ការរំខានផ្នែកសេដ្ឋកិច្ចនៅក្នុងសហគមន៍មូលដ្ឋាន នឹងមិនប៉ះពាល់ទៅលើការចូលរៀនរបស់សិស្សច្រើនហួសហេតុពេកទេ។</li><li>។ល។</li></ul></td></tr>
<tr><td>វត្ថុបំណងរយៈពេលខ្លី</td><td>សូចនាករ</td></tr>
<tr><td>ជាតុចេញទី ១៖<br><br>ជាតុចេញទី ២៖<br><br>ជាតុចេញទី ៣៖<br><br>ជាតុចេញទី ៤៖<br><br>ជាតុចេញទី ៥៖</td><td>សូចនាករ</td></tr>
<tr><td>សកម្មភាព<br><br>១.១.<br><br>១.២.<br><br>១.៣.<br><br>២.១.<br><br>២.២<br><br>។ល។</td><td>ធនធាន</td><td>.</td></tr>
</table>

# ឯកសារទី ២៦៖ តារាង GANT សម្រាប់ធ្វើផែនការការងារ

| ល.រ | សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | | កុម្ភៈ | | | | មីនា | | | | មេសា | | | | ឧសភា | | | | មិថុនា | | | | កក្កដា | | | | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

## ឯកសារទី២៧កៈ ការសម្របសម្រួលសូចនាករកម្រិតសាលារៀន ជាមួយនឹងស្តង់ដាអនុវត្តន៍ការងារសាលារៀនថ្នាក់ជាតិ

### ហេតុអ្វីប្រើប្រាស់សូចនាករ?

ដំណាក់កាលចុងក្រោយនៅក្នុងដំណើរការធ្វើផែនការគឺ កំណត់សូចនាករ។ មានមូលហេតុមួយចំនួនដែលសំខាន់ក្នុងការដាក់បញ្ចូលសូចនាករទៅក្នុងផែនការ។ មូលហេតុទាំងនេះរួមមានដូចជា៖

- សូចនាករជួយឱ្យអ្នកធ្វើផែនការបានដឹងថាតើមានការឆ្លើយតបតាមគោលដៅដែរឬទេ។ ព័ត៌មាននេះ សំខាន់បំផុតសម្រាប់ការធ្វើឱ្យសាលារៀនទទួលខុសត្រូវចំពោះការបំពេញការងាររបស់ខ្លួន។ ដូច្នេះ យើងនិយាយថា សូចនាករគឺជាគន្លឹះឆ្ពោះទៅរកគោលការណ៍គណនេយ្យភាពនៅក្នុងការគ្រប់គ្រងតាមសាលារៀន។
- សូចនាករជួយឱ្យអ្នកធ្វើផែនការបានដឹងថាតើដំណោះស្រាយមានប្រសិទ្ធភាព ឬរួមចំណែកដល់គោលដៅរួមដែរឬទេ និងបានដល់កម្រិតណា។
- សូចនាករផ្តល់នូវការណែនាំដល់អ្នកធ្វើផែនការ អំពីរបៀបដែលផែនការគួរត្រូវបានត្រួតពិនិត្យ។ កិច្ចការនេះពាក់ព័ន្ធជាពិសេសទៅនឹងព័ត៌មាន ដែលត្រូវតែប្រមូលយូរៗម្តង ដើម្បីវាយតម្លៃវឌ្ឍនភាពនៃផែនការ។

### លំហាត់៖ ការសម្របសម្រួលសូចនាការតាមសាលារៀនជាមួយនឹងស្តង់ដាជាតិ

គម្រោងជាក់លាក់មួយចំនួន ដែលកំពុងតែផ្តល់មូលនិធិដល់សាលារៀនរបស់អ្នក អាចនឹងតម្រូវឱ្យអ្នកសម្របសម្រួលសូចនាករនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក ជាមួយនឹងក្របខ័ណ្ឌសូចនាកររបស់ពួកគេ។ នៅក្នុងករណីបែបនេះ អ្នកអាចនឹងត្រូវបង្កើតទម្រង់មួយនៅក្នុងផែនការរបស់អ្នក ដែលអ្នកត្រូវផ្ទៀងផ្ទាត់សូចនាករតាមសាលារៀនជាមួយនឹងស្តង់ដាអនុវត្តន៍ការងារថ្នាក់ជាតិ ឬជាមួយនឹងស្តង់ដាអនុវត្តន៍ការងារទូទាំងគម្រោង។ មានឧទាហរណ៍មួយផ្តល់ជូនដល់អ្នកនៅខាងក្រោមនេះ។ ដោយប្រើបញ្ជីស្តង់ដាជាតិដែលមានផ្តល់ជូននៅផ្នែកខាងចុងនៃឯកសារនេះ ចូរព្យាយាមស្វែងរកស្តង់ដាជាតិផ្សេងទៀតពីបញ្ជីខាងក្រោមនេះ ដែលត្រូវនឹងឧទាហរណ៍អំពីសូចនាករតាមសាលារៀន៖

| សូចនាករតាមសាលារៀន (ឧទាហរណ៍) | ស្តង់ដាជាតិពាក់ព័ន្ធ | ផ្នែកនៃប្រតិបត្តិការសាលារៀនពាក់ព័ន្ធ[10] |
|---|---|---|
| 1. គណៈកម្មការគ្រប់គ្រងសាលារៀនជួបប្រជុំជាទៀងទាត់ យ៉ាងតិចមួយខែម្តងក្នុងរយៈពេល ១០ ខែ។ | ចំនួនកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនដែលបានបើកតាមការណែនាំ។ (សូចនាករ ៣.២) | រដ្ឋបាលសាលារៀន ការពិនិត្យតាមដាន និងទំនាក់ទំនងសហគមន៍ |
| 2. ចំនួនសិស្សបោះបង់ការសិក្សាគ្រប់កម្រិតថ្នាក់ ដែលបង្ហាញជាភាគរយមាន | ______________________ ______________________ | រដ្ឋបាលសាលារៀន ការពិនិត្យតាមដាន និង |

[10] សូមមើល ឯកសារទី ៥ក ។

| | | | |
|---|---|---|---|
| | ការថយចុះពីឆ្នាំមុនរៀងរាល់ឆ្នាំ។ | ______________ | ទំនាក់ទំនងសហគមន៍ |
| 3. | យ៉ាងតិច ៩០% នៃរបាយការណ៍ថ្នាក់រៀន ដែលមានសិស្ស ៤០ នាក់ ឬតិចជាងនេះជារៀងរាល់ឆ្នាំ។ | ______________<br>______________ | ការគ្រប់គ្រងការបង្រៀន |
| 4. | យ៉ាងតិច ២៥% នៃសិស្សនៅក្នុងសាលារៀន ទទួលបានវគ្គសិក្សាបំណិនជីវិតជារៀងរាល់ឆ្នាំ។ | ______________<br>______________<br>______________ | ការគ្រប់គ្រងការបង្រៀន |

តាមការរំពឹងទុករបស់អ្នក (ឧ. ទោះសាលារៀនមានធនធានច្រើនក្តី ឬធនធាននៅមានកម្រិតក្តី) និងវិសាលភាពនៃផែនការរបស់អ្នក សាលារៀនរបស់អ្នកអាចនឹងត្បូញត្បែរជាមួយនឹងស្តង់ដាអនុវត្តន៍ការងារថ្នាក់ជាតិតិចតួច ឬច្រើន។ ដូច្នេះ ចំនួននៃស្តង់ដាអនុវត្តន៍ការងារថ្នាក់ជាតិ ដែលសាលារៀនមួយអាចដោះស្រាយអាចនឹងខុសគ្នាពីសាលារៀនមួយទៅសាលារៀនមួយទៀតទៅតាមលទ្ធភាពធនធាន។

## ការកំណត់ស្តង់ដាអនុវត្តន៍ការងារដោយប្រើស្តង់ដាជាតិ និងប្រតិមតិ SBM (SBM Paradox)

មិត្តអ្នកអានប្រហែលជានៅចាំបញ្ញត្តិមួយ ដែលបានណែនាំឱ្យស្គាល់ពីខាងដើមហៅថា '**ប្រតិមតិSBM**' (សូមមើល ឯកសារទី ៤)។ បញ្ញត្តិនេះ មានភាពពាក់ព័ន្ធយ៉ាងខ្លាំងនៅពេលព្យាយាមស្វែងយល់អំពីអារម្មណ៍តានតឹងដែលអ្នកពាក់ព័ន្ធតាមសាលារៀនអាចនឹងជួប នៅពេលពួកគេព្យាយាមប្រើប្រាស់ស្វ័យភាពរបស់ខ្លួនក្នុងការកំណត់ស្តង់ដាវាយតម្លៃ និងសូចនាករផ្ទាល់ខ្លួនផង ស្របពេលដែលពួកគេត្រូវគោរពតាមក្របខ័ណ្ឌជាតិផង។

ជាការល្អ អ្នកពាក់ព័ន្ធនៅតាមសាលារៀនគួរព្យាយាម**ស្វែងរកតុល្យភាពមួយ**រវាងការកំណត់សូចនាករផ្ទាល់ខ្លួន និងការធ្វើការនៅក្នុងក្របខ័ណ្ឌស្តង់ដាជាតិ។ ក្នុងនាមជាសាលារៀនសាធារណៈ យើងត្រូវតែធ្វើការនៅក្នុងប្រព័ន្ធជាតិ ដែលមានគោលនយោបាយ និងស្តង់ដាដែលបានកំណត់ជារួម។ នេះហើយគឺជាហេតុផលដែលសាលារៀនទាំងឡាយគួរតែកំណត់សូចនាករផ្ទាល់ខ្លួន ដូចដែលបានពន្យល់ពីខាងលើ ប៉ុន្តែព្យាយាមតម្រូវសូចនាករទាំងនេះឱ្យបានច្រើនតាមដែលអាចធ្វើបាន ជាមួយនឹងស្តង់ដាជាតិដើម្បីបង្ហាញថា សាលារៀននៅតែធ្វើការនៅក្នុងក្របខ័ណ្ឌជាតិ ប៉ុន្តែរក្សាបាននូវស្វ័យភាពរបស់ខ្លួនក្នុងការកំណត់សូចនាការអនុវត្តការងាររបស់ខ្លួនផងដែរ។

## ការដឹងថាស្តង់ដាជាតិគឺជាឯកសារយោងមួយនៅក្នុងការបង្កើតសូចនាករតាមសាលារៀន

បញ្ជីស្តង់ដាអនុវត្តន៍ការងារថ្នាក់ជាតិទាំង ៦៥ ខាងក្រោមនេះ អាចនឹងមានសារៈប្រយោជន៍សម្រាប់ឱ្យអ្នកពាក់ព័ន្ធនៅកម្រិតសាលារៀនបានដឹង នៅពេលបង្កើតសូចនាករតាមសាលារៀន។ ទោះបីជាសាលារៀនរបស់អ្នកអាចនឹងមានអាទិភាពខុសៗគ្នាក៏ដោយ ជាការសំខាន់ណាស់ដែលត្រូវព្យាយាមធានាថា ផែនការសាលារៀនរបស់អ្នកបានរួមចំណែកតាមវិធីមួយចំនួន ក្នុងការសម្រេចបាន

នូវស្តង់ដាអនុវត្តន៍ការងារថ្នាក់ជាតិ។

សូមមើលតារាងខាងក្រោម៖

**បញ្ជីស្តង់ដាជាតិ**[11]

| ស្តង់ដាទី ១៖ វត្ថុបំណងគោលនយោបាយសាលារៀន | | លេខយោង |
|---|---|---|
| 1.1 | ការកែលម្អនូវការចុះឈ្មោះចូលរៀន ត្រួតថ្នាក់ បោះបង់ការសិក្សា និងការឡើងថ្នាក់ (ចំនួនសិស្ស) | 1. |
| 1.2 | ភាគរយសិស្សដែលសម្រេចលទ្ធផលតេស្តប្រចាំឆ្នាំ មានពិន្ទុលើស ៦០% លើមុខវិជ្ជាគោល។ | 2. |
| 1.3 | ភាគរយសិស្សដែលសម្រេចលទ្ធផលតេស្តប្រចាំឆ្នាំ មានពិន្ទុលើស ៦០% លើមុខវិជ្ជាវិទ្យាសាស្ត្រ។ | 3. |
| 1.4 | ភាគរយសិស្សថ្នាក់ទី ៩ ដែលជាប់ល្បឿនអំណាន និងការអានដោយយល់ន័យស្តង់ដា (លើស ២០០ ពាក្យក្នុងមួយនាទី)។ | 4. |
| 1.5 | ភាគរយសិស្សថ្នាក់ទី ៩ ដែលជាប់ការប្រឡងថ្នាក់ជាតិ។ | 5. |
| **ស្តង់ដាទី ២៖ ការបង្រៀន និងកាលវិភាគបង្រៀន** | | |
| 2.1 | សាលារៀនមានកាលវិភាគបង្រៀនតាមមុខវិជ្ជា | 6. |
| 2.1.1 | ចំនួនកិច្ចតែងការបង្រៀនដែលបានធ្វើ ដោយគិតតាមមុខវិជ្ជាគោលនៅថ្នាក់ទី ៧ តាមចំណុចដៅផែនការប្រចាំឆ្នាំ។ | 7. |
| 2.1.2 | ចំនួនកិច្ចតែងការបង្រៀនដែលបានធ្វើ ដោយគិតតាមមុខវិជ្ជាគោលនៅថ្នាក់ទី ៨ តាមចំណុចដៅផែនការប្រចាំឆ្នាំ។ | 8. |
| 2.1.3 | ចំនួនកិច្ចតែងការបង្រៀនដែលបានធ្វើ ដោយគិតតាមមុខវិជ្ជាគោលនៅថ្នាក់ទី ៩ តាមចំណុចដៅផែនការប្រចាំឆ្នាំ។ | 9. |
| 2.3 | ភាគរយសិស្សជាប់មុខវិជ្ជាគោល | 10. |
| 2.3.1 | ភាគរយសិស្សថ្នាក់ទី ៧ ជាប់ពិន្ទុតេស្តមុខវិជ្ជាគោល ប្រៀបធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ។ | 11. |
| 2.2.2 | ភាគរយសិស្សថ្នាក់ទី ៨ ជាប់ពិន្ទុតេស្តមុខវិជ្ជាគោល ប្រៀបធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ។ | 12. |
| 2.2.3 | ភាគរយសិស្សថ្នាក់ទី ៩ ជាប់ពិន្ទុតេស្តមុខវិជ្ជាគោល ប្រៀបធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ។ | 13. |
| 2.4 | ភាគរយសិស្សថ្នាក់ទី ៩ ប្រឡងធមាសជាប់ | 14. |
| 2.5 | កំណើនចំនួនថ្នាក់រៀនដែលមានការជួបគ្នារវាងគ្រូបង្រៀន ឪពុកម្តាយ និងសិស្សដែលជាអ្នករៀនយឺត (សិស្សត្រួតមកពីឆ្នាំសិក្សាចាស់ សិស្សដែលមានពិន្ទុតេស្តដំណាច់ឆ្នាំសិក្សាចាស់ និងពិន្ទុតេស្តដើមឆ្នាំសិក្សាក្រោម ៦០%) ប្រៀបធៀបជាមួយចំណុចដៅនៃផែនការ | 15. |
| 2.6 | ការថយចុះកង្វះចំនួនម៉ោងបង្រៀនគិតជាមធ្យម។ | 16. |
| 2.7 | ការថយចុះកង្វះចំនួនម៉ោងបង្រៀនគិតជាមធ្យមនៅថ្នាក់ទី ៧ | 17. |
| 2.8 | ការថយចុះកង្វះចំនួនម៉ោងបង្រៀនគិតជាមធ្យមនៅថ្នាក់ទី ៨ | 18. |
| 2.9 | ការថយចុះកង្វះចំនួនម៉ោងបង្រៀនគិតជាមធ្យមនៅថ្នាក់ទី ៩ | 19. |
| 2.10 | ភាគរយអវត្តមានសិស្សថយចុះ | 20. |
| 2.11 | ភាគរយកម្រិតថ្នាក់/សិស្ស ដែលទទួលកិច្ចការផ្ទះ | 21. |
| 2.11.1 | ភាគរយកិច្ចការផ្ទះសិស្សដែលផ្តល់ឱ្យសិស្សថ្នាក់ទី ៧ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ | 22. |

[11] ដកស្រង់ពី៖ SEIP (2017) *School-based Management Manual,* Phnom Penh: MoEYS.

| | | |
|---|---|---|
| 2.11.2 | ភាគរយកិច្ចការផ្ទះសិស្សដែលផ្តល់ឱ្យសិស្សថ្នាក់ទី ៨ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ | 23. |
| 2.11.3 | ភាគរយកិច្ចការផ្ទះសិស្សដែលផ្តល់ឱ្យសិស្សថ្នាក់ទី ៩ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ | 24. |
| 2.12 | ភាគរយការងារជាគម្រោងរបស់សិស្ស | 25. |
| 2.12.1 | ភាគរយការងារជាគម្រោងរបស់សិស្ស ដែលផ្តល់ឱ្យសិស្សថ្នាក់ទី ៧ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ | 26. |
| 2.12.2 | ភាគរយការងារជាគម្រោងរបស់សិស្ស ដែលផ្តល់ឱ្យសិស្សថ្នាក់ទី ៨ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ | 27. |
| 2.12.3 | ភាគរយការងារជាគម្រោងរបស់សិស្ស ដែលផ្តល់ឱ្យសិស្សថ្នាក់ទី ៩ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយចំណុចដៅផែនការប្រចាំឆ្នាំ | 28. |
| 2.14 | ចំនួនគ្រូគោលដៅដែលទទួលបានការបណ្តុះបណ្តាល និងការបង្វឹកពេលកំពុងបំពេញការងារ | 29. |
| 2.15 | ចំនួនថ្នាក់រៀនឆ្លើយតបរដ្ឋបាលថ្នាក់តាមគោលការណ៍ណែនាំក្រសួងអប់រំ តាមចំណុចដៅផែនការ | 30. |
| 2.16 | ចំនួនថ្នាក់រៀនឆ្លើយតបរដ្ឋបាលថ្នាក់តាមគោលការណ៍ណែនាំក្រសួងអប់រំ តាមចំណុចដៅផែនការ | 31. |
| 2.17 | ចំនួនមុខវិជ្ជាអប់រំកាយ កីឡា និងសិល្បៈដែលបានរៀបចំតាមចំណុចដៅផែនការ (សរុប១៤ មុខវិជ្ជា) | 32. |
| **ស្តង់ដាទី ៣៖ ឪពុកម្តាយ និងសហគមន៍ទ្រទ្រង់ការសិក្សារបស់សិស្ស** | | |
| 3.1 | ភាគរយថ្នាក់រៀនដែលបានប្រជុំប្រឹក្សាយោបល់រវាងឪពុកម្តាយ គ្រូបង្រៀន និងសិស្ស (ដើមឆ្នាំសិក្សា និងប្រចាំត្រីមាស) | 33. |
| 3.2 | ចំនួនកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនដែលបានបើកតាមការណែនាំ (ដើមឆ្នាំសិក្សា ដំណាច់ឆមាសទី ១ និងឆមាសទី ២) | 34. |
| 3.3 | ភាគរយសិស្សមករៀនយឺត | 35. |
| 3.4 | ភាគរយសិស្សធ្វើកិច្ចការផ្ទះ និងការងារជាគម្រោង | 36. |
| **ស្តង់ដាទី ៤៖ សិស្ស និងសេវាគាំទ្រសិស្ស** | | |
| 4.1 | ភាគរយសិស្សប្រើបណ្ណាល័យ (ត្រួតពិនិត្យប្រចាំត្រីមាស) | 37. |
| 4.2 | ភាគរយសិស្សប្រើបន្ទប់វិទ្យាសាស្ត្រ | 38. |
| 4.3 | ភាគរយសិស្សប្រើកុំព្យូទ័រ | 39. |
| 4.4 | ភាគរយថ្នាក់រៀនមានក្លឹបសិក្សាសិស្សកំពុងដំណើរការ (ប្រតិបត្តិការតាមក្រសួងអប់រំណែនាំ) | 40. |
| 4.5 | ភាគរយសិស្សខ្សោយគំហើញ និងខ្សោយស្តាប់ ដែលបានទទួលការគាំទ្រដើម្បីកែលម្អលទ្ធផលសិក្សា | 41. |
| 4.6 | ភាគរយសិស្សទទួលអាហារូបករណ៍ដែលបានបោះបង់ការសិក្សា | 42. |
| 4.7 | ចំនួនទស្សនកិច្ចសិក្សាគ្រូបង្រៀន | 43. |
| 4.8 | ចំនួនទស្សនកិច្ចសិក្សាសិស្ស | 44. |
| **ស្តង់ដាទី ៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន** | | |
| 5.1 | ចំនួនសូចនាកររដ្ឋបាលសាលារៀនដែលសម្រេចបានតាមក្រសួងអប់រំណែនាំ (សរុប ១០ សូចនាករ) | 45. |
| 5.2 | ផែនការអធិការកិច្ចគ្រូបង្រៀនរបស់នាយកសាលារៀន/នាយករង | 46. |
| 5.3 | ចំនួនដងនៃការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួងអប់រំ (សរុប ៧ ដងក្នុងមួយឆ្នាំ) | 47. |

| | | |
|---|---|---|
| 5.4 | ចំនួនការបណ្តុះបណ្តាល និងការបង្វឹកពេលអនុវត្តការងារសម្រាប់នាយកសាលារៀន / គណៈកម្មការគ្រប់គ្រងសាលារៀនដោយមន្ត្រីថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អសូចនាកររដ្ឋបាលសាលារៀន | 48. |
| 5.5 | ភាគរយគ្រូដែលបានកែលម្អការអនុវត្តការងាររបស់ខ្លួនតាមរយៈការវាយតម្លៃការអនុវត្តការងារគ្រូបង្រៀនប្រចាំឆ្នាំ | 49. |
| 5.6 | កាត់បន្ថយបាតុភាពមិនប្រក្រតីក្នុងសាលារៀន (មានបាតុភាពមិនប្រក្រតីសរុបចំនួន ៩) | 50. |
| 5.7 | ចំនួនការចុះត្រួតពិនិត្យ និងចុះជួយពីការិយាល័យអប់រំស្រុក, មន្ទីរអប់រំខេត្ត-រាជធានី និងក្រសួងអប់រំ | 51. |
| **ស្តង់ដាទី ៦៖ ធនធានមនុស្ស** | | |
| 6.1 | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនរបស់ក្រសួងអប់រំ | 52. |
| 6.2 | កង្វះគ្រូមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រមានការថយចុះ បើធៀបជាមួយនិយាម | 53. |
| 6.3 | គុណវុឌ្ឍិនាយកសាលារៀនធៀបជាមួយនឹងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងរបស់ក្រសួងអប់រំ | 54. |
| **ស្តង់ដាទី ៧៖ សៀវភៅសិក្សាគោល សម្ភារបង្រៀន និងរៀន** | | |
| 7.1 | សិស្សមានសៀវភៅសិក្សាគោលតាមមុខវិជ្ជា និងកម្រិតថ្នាក់ត្រឹមត្រូវតាមនិយាម | 55. |
| 7.2 | ចំនួនគ្រូមុខវិជ្ជាគោលដែលទទួលបានការបណ្តុះបណ្តាលឱ្យប្រើប្រាស់សៀវភៅលំហាត់ | 56. |
| 7.3 | បានបង្កើត និងកែលម្អបណ្ណាល័យដើម្បីតម្រូវតាមស្តង់ដា | 57. |
| **ស្តង់ដាទី ៨៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន** | | |
| 8.1 | កង្វះបន្ទប់រៀនត្រូវបានកាត់បន្ថយដើម្បីតម្រូវតាមនិយាមសិស្ស – សមាមាត្រសិស្ស | 58. |
| 8.2 | បានសាងសង់អន្តេវាសិកដ្ឋានដែលត្រូវការសម្រាប់គ្រូបង្រៀន | 59. |
| 8.3 | មានការផ្តល់ជូនការិយាល័យរដ្ឋបាលសាលារៀន និងគ្រឿងសង្ហារិមដើម្បីបំពេញតាមតម្រូវការ | 60. |
| 8.4 | បន្ទប់ទឹកត្រូវបានសាងសង់ដើម្បីបំពេញតាមស្តង់ដា និងនិយាមសិស្ស – បន្ទប់ទឹកបុរស និងនារី | 61. |
| 8.5 | សូចនាករបរិស្ថានសាលារៀន (សរុប ១៦) មានការកែលម្អ | 62. |
| **ស្តង់ដារទី ៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ** | | |
| 9.1 | ថវិកាសាលារៀន ប្រភពថវិកា និងថវិកាជាក់ស្តែងដែលទទួលបានប្រចាំត្រីមាស មានការកែលម្អ | 63. |
| 9.2 | សូចនាករអំពីការចាត់ចែងថវិកាសាលារៀន ការអនុវត្ត និងតម្លាភាពមានការកែលម្អ (សរុប ៥) | 64. |
| 9.3 | ការរាយការណ៍អំពីការអនុវត្តថវិកាតាមប្រភេទធំៗ (រដ្ឋបាល បង្រៀន និងរៀន និងបរិស្ថាន) មានការកែលម្អដោយផ្តោតលើការបង្រៀន និងរៀន | 65. |

## ឯកសារទី២៧ខ៖ គោលការណ៍ណែនាំសម្រាប់ការកំណត់សូចនាករ

### ១. លក្ខណៈនៃសូចនាករ

និយមន័យមូលដ្ឋាន៖ សូចនាករគឺជាឧបករណ៍ត្រួតពិនិត្យ ដែលប្រាប់យើងអំពីពេលដែលគោលដៅ វត្ថុបំណង ឬដំណោះស្រាយអ្វីមួយសម្រេចបានជាក់ស្តែង។ សូចនាករគឺជា **ស្តង់ដា** ដែលអ្នកធ្វើផែនការកំណត់ដើម្បីជួយដល់ពួកគេក្នុងការវាស់ស្ទង់ប្រសិទ្ធភាពនៃសកម្មភាពរបស់ខ្លួន ក្នុងការសម្រេចវត្ថុបំណង។

ការវាស់វែង និងសូចនាករ៖ សូចនាករអាចមានរូបភាពជាច្រើន។ សូចនាករមួយចំនួនប្រើប្រាស់ស្តង់ដាដែល *ប្រៀបធៀប ឬពាក់ព័ន្ធ* (ឧ. អត្រាបោះបង់ការសិក្សាថយចុះ ៥% នៅតាមសាលារៀនទាំងអស់ ពីអត្រាដែលបានកត់ត្រាពីមុនមក); សូចនាករផ្សេងទៀតប្រើប្រាស់ស្តង់ដា *ដាច់ខាត* (ឧ. យ៉ាងហោចណាស់ ៤០% នៃសិស្សនៅក្នុងសាលារៀនគឺជានារី)។

វត្ថុបំណងមួយចំនួន ដែលពាក់ព័ន្ធទៅនឹងអ្វីៗដូចជា *គុណភាពអប់រំ ឬ ឥរិយាបថ* អាចមានការពិបាកក្នុងការវាស់វែង (ឧ. សិស្សឱ្យតម្លៃខ្ពស់លើការអប់រំ)។ សម្រាប់វត្ថុបំណងទាំងនេះ អ្នកសិក្សាប្រើប្រាស់អ្វីដែលយើងស្គាល់ថាជា *សូចនាករជំនួស*។ ទាំងនេះគឺជាសូចនាករ "ជំនួស" ដើម្បីវាស់វែងផលសម្រេចជាប្រយោល។ ឧទាហរណ៍ ប្រសិនបើសិស្សឱ្យតម្លៃការអប់រំច្រើនជាងមុន ដែលជាលទ្ធផលនៃអន្តរាគមន៍របស់កម្មវិធីនោះ ប្រហែលជាអត្រាបោះបង់ការសិក្សារបស់កូនពួកគេនឹងមានការថយចុះ។ ទាក់ទងនឹងគុណភាពនៃការអប់រំ ប្រសិនបើគុណភាពមានការប្រសើរឡើងនោះ ប្រហែលជាការសិក្សានឹងប្រសើរឡើងផងដែរ។ ដូច្នេះអត្រាបោះបង់ការសិក្សា ឬពិន្ទុតេស្តរបស់សិស្សអាចប្រើជាសូចនាករជំនួសសម្រាប់វាស់វែងការសម្រេចវត្ថុបំណងដែលទាក់ទងនឹងឥរិយាបថរបស់ឪពុកម្តាយសិស្សអំពីការអប់រំ ឬគុណភាពនៃការអប់រំ។

### ២. ការសរសេរសូចនាករ

**សមាសភាគនៃសូចនាករ៖** នៅពេលសរសេរសូចនាករមួយ អ្នកធ្វើផែនការត្រូវតែយកចិត្តទុកដាក់ថា វាដាក់បញ្ចូលនូវរឿងយ៉ាងតិច ៤ យ៉ាង។ រឿងទាំងនេះរួមមានដូចជា៖

- *អ្វី*ដែលគួរកើតឡើង (ឧ. សិស្សទទួលបានពិន្ទុយ៉ាងតិច ៥ លើតេស្ត ១០ ពិន្ទុ)
- *តើវាគួរកើតឡើងច្រើនប៉ុនណា ឬដល់កម្រិតណា* (ឧ. ៦០% នៃសិស្ស)
- *សម្រាប់នរណាខ្លះ* (ឧ. សិស្សគ្រប់កម្រិតថ្នាក់)
- *ត្រឹមពេលណា* (ឧ. ត្រឹមដំណាច់ឆ្នាំសិក្សា)

**ភាពប្រាកដនិយម៖** នៅពេលសរសេរសូចនាករមួយ ត្រូវប្រាកដថា ស្តង់ដាទាំងឡាយដែលអ្នកបានកំណត់សុទ្ធតែអាចសម្រេចបាន។ សូមកុំកំណត់ស្តង់ដារបស់អ្នកខ្ពស់ពេក ដែលមិនអាចសម្រេចទៅបាន។ ចូរចងចាំថា អ្នកនឹងវិនិច្ឆ័យទៅលើភាពជោគជ័យ ឬបរាជ័យនៃផែនការរបស់អ្នកធៀបនឹងសូចនាកររបស់អ្នក ដូច្នេះបើស្តង់ដារបស់អ្នកខ្ពស់ពេក ផែនការរបស់អ្នកនឹងត្រូវបានវិនិច្ឆ័យថាជាបរាជ័យមួយ។

### ៣. សូចនាករ និងការពិនិត្យតាមដាន

សូចនាករអាចមានប្រយោជន៍ជួយដល់អ្នកធ្វើផែនការក្នុងការបង្កើតផែនការត្រួតពិនិត្យមួយ។ វាបង្ហាញនូវ៖

- ព័ត៌មានប្រភេទណាខ្លះដែលយើងត្រូវត្រួតពិនិត្យ (ឧ. អត្រាចុះឈ្មោះចូលរៀន ចំនួនគ្រូបង្រៀននារី។ល។)
- កន្លែងដែលយើងអាចស្វែងរកព័ត៌មានបាន (ឧ. កំណត់ហេតុសាលារៀន) ឬត្រូវប្រមូលព័ត៌មាននោះដោយ

របៀបណា (ឧ. ការស្ទង់មតិពិសេស)។

- ភាពញឹកញាប់ដែលយើងត្រូវប្រមូលព័ត៌មាន (នៅដំណាច់ឆ្នាំ ពីរដងក្នុងមួយឆ្នាំ។ល។)

## ៤. លំហាត់

ចូរធ្វើលំហាត់ខាងក្រោមនេះតាមក្រុមតូចៗ។ ប្រៀបធៀបចម្លើយរបស់ក្រុមនីមួយៗជាមួយនឹងការគោរពតាមគោលការណ៍ណែនាំដែលផ្តល់ជូនខាងលើ។

**សេចក្តីណែនាំ៖** ចូរអានដំណោះស្រាយដែលមានសរសេរនៅក្នុងតារាងខាងក្រោម។ បន្ទាប់មក ពិនិត្យមើលសមាសភាគសូចនាករដែលមានសរសេរពីក្រោមតារាងនោះ។ ព្យាយាមផ្គូរផ្គងសមាសភាគដែលមានផ្តល់ជូនជាមួយនឹងដំណោះស្រាយដែលសមស្រប និងប្រភេទសូចនាករ (កម្រិតណា ច្រើនប៉ុនណា ពេលណា) ដែលវាពន្យល់ប្រាប់។ នៅពេលអ្នកបានធ្វើកិច្ចការនេះរួចហើយ ចូរសំយោគផ្នែកសមាសភាគនីមួយៗនៃសូចនាករទៅជាសូចនាករជាលាយលក្ខណ៍អក្សរពេញលេញមួយ។

| វត្ថុបំណង | *តើអ្វីគួរកើតឡើង* | *តើវាគួរកើតឡើងច្រើនប៉ុនណា ឬដល់កម្រិតណា* | *តើការផ្លាស់ប្តូរគួរកើតឡើងចំពោះនរណា* | *តើការផ្លាស់ប្តូរគួរកើតឡើងនៅពេលណា* |
|---|---|---|---|---|
| ១. ចំនួនសិស្សច្រើនណែនណាន់តាន់តាប់ក្នុងថ្នាក់រៀនត្រូវបានកាត់បន្ថយ។ | | | | |
| សរសេរសូចនាករពេញលេញទីនេះ ៖ | **សូចនាករទី ១៖** ____________ | | | |
| ២. កុមារក្រីក្រស្នាក់នៅក្នុងសាលារៀន។ | | | | |
| សរសេរសូចនាករពេញលេញទីនេះ ៖ | **សូចនាករទី ២៖** ____________ | | | |

### សមាសភាគសូចនាករទី ១

- រហូតដល់ដំណាច់ឆ្នាំ
- នៅគ្រប់ថ្នាក់រៀនទាំងអស់
- ផលធៀបសិស្ស-គ្រូគឺ ៤៥:១ ឬតិចជាងនេះ
- សម្រាប់គ្រូបង្រៀនទាំងអស់

### សមាសភាគសូចនាករទី ២

- យ៉ាងតិច ៩៥%
- កុមារដែលកំណត់អត្តសញ្ញាណថាក្រីក្រ
- នៅបន្តចុះឈ្មោះចូលរៀននៅក្នុងសាលារៀន
- រៀងរាល់ឆ្នាំ

## ឯកសារទី ២៨ក៖ តើបញ្ជីសកម្មភាពគឺជាអ្វី?

### អំពីការផ្តល់សិទ្ធិអំណាច កម្មសិទ្ធិភាព និងនិរន្តរភាព៖

ការប្រើប្រាស់បញ្ជីសកម្មភាព គឺជាឧបករណ៍ធ្វើផែនការមួយដែលគោរពតាមគោលការណ៍នៃការគ្រប់គ្រងតាមសាលារៀនបានយ៉ាងល្អ ដូចជា **ការផ្តល់សិទ្ធិអំណាច កម្មសិទ្ធិភាព** និង **ការសម្រេចចិត្តក្នុងមូលដ្ឋាន**។ ក្រោយការអភិវឌ្ឍដោយមានការជំរុញពីថ្នាក់កណ្តាលអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ដែលនៅពុំទាន់ទទួលបានជោគជ័យខ្លាំងក្លានោះ ឥឡូវនេះយើងបានដឹងថា អ្នកពាក់ព័ន្ធត្រូវតែមានអារម្មណ៍ថាមានសិទ្ធិអំណាច នៅពេលធ្វើផែនការអភិវឌ្ឍន៍សាលារៀន។ យើងអាចសម្រេចបានស្មារតីនៃការផ្តល់សិទ្ធិអំណាចនេះបាន នៅពេលណាអ្នកពាក់ព័ន្ធមានអារម្មណ៍ថា ពួកគេបានធ្វើការសម្រេចចិត្ត និងជ្រើសរើសដោយខ្លួនឯងនូវអ្វីដែលខ្លួនចង់ធ្វើក្នុងការដោះស្រាយបញ្ហាដែលពួកគេបានកំណត់រកឃើញដោយខ្លួនឯង។ ត្រឡប់មកវិញ ស្មារតីនៃការផ្តល់សិទ្ធិអំណាច នឹងធានាថា ក្រុមការងារថ្នាក់មូលដ្ឋានមានផែនការអនុវត្តរបស់ខ្លួនឯងផ្ទាល់។ ពេលមានកម្មសិទ្ធិភាពលើផែនការមួយ អ្នកពាក់ព័ន្ធទំនងជានឹងខិតខំប្រឹងប្រែងកាន់តែខ្លាំង ដើម្បីទ្រទ្រង់ឱ្យសកម្មភាពនៅក្នុងផែនការមាននិរន្តរភាព។ ដូច្នេះ យើងអាចមើលឃើញសំណុំទំនាក់ទំនងដ៏សំខាន់រវាងបញ្ញត្តិទាំងនេះ ៖

**ការផ្តល់សិទ្ធិអំណាច ⇨ ធ្វើឱ្យយើងមានអារម្មណ៍ថាមានកម្មសិទ្ធិភាព ⇨ យើងចង់ទ្រទ្រង់ផែនការឱ្យមាននិរន្តរភាព**

### ការប្រើប្រាស់បញ្ជីមុខម្ហូប និងជម្រើស៖

យើងទាំងអស់គ្នាដឹងហើយថា "បញ្ជី" សុទ្ធតែនិយាយអំពីជម្រើស។ នៅពេលយើងទៅភោជនីយដ្ឋានណាមួយ ហើយអានបញ្ជី យើងមានជម្រើសទៅលើមុខម្ហូបជាច្រើនប្រភេទដែលត្រូវហូប។ ប្រសិនបើនរណាម្នាក់ផ្សេងទៀតកុម្ម៉ង់ម្ហូបឱ្យយើងហូប យើងទំនងជានឹងមានអារម្មណ៍មិនសូវសប្បាយចិត្តនឹងអ្វីដែលយើងកំពុងហូបទេ។ យើងនឹងសប្បាយចិត្តខ្លាំងនៅពេលយើងអាចកុម្ម៉ង់ម្ហូបដោយខ្លួនឯងបាន។ បញ្ជីសកម្មភាពមានប្រសិទ្ធភាពតាមរបៀបដូចគ្នានេះដែរ។ ការអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធជ្រើសរើសសកម្មភាពដែលពួកគេមានអារម្មណ៍ថាពាក់ព័ន្ធបំផុតជាមួយនឹងស្ថានភាពរបស់ពួកគេ យើងធានាថា ពួកគេនឹង "សប្បាយចិត្ត" ជាមួយនឹងសកម្មភាពដែលបានជ្រើសរើស។ ដូច្នេះ យើងសង្ឃឹមថា ការប្រើម៉ឺនុយសកម្មភាពសម្រាប់ដំណើរការធ្វើផែនការអភិវឌ្ឍន៍សាលារៀន នឹងបង្កើតបាននូវសំណុំសកម្មភាពពាក់ព័ន្ធក្នុងមូលដ្ឋានមួយ ដែលទោះជាយ៉ាងណានឹងមាននៅក្នុងក្របខ័ណ្ឌកម្មវិធីស្ថិតស្ថេរមួយ ដែលស្របតាមគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា។



### ទស្សនវិជ្ជានៅក្រោយការប្រើប្រាស់បញ្ជីសកម្មភាព

ទស្សនវិជ្ជាដែលគាំទ្រការប្រើប្រាស់បញ្ជីផែនការនៅក្នុងការអនុវត្តគម្រោង អាចសង្ខេបបានយ៉ាងល្អដោយពាក្យ "សេរីភាពនៅក្នុងរចនាសម្ព័ន្ធ" ។ ប្រព័ន្ធសាលារៀនគួរព្យាយាមចៀសវាងគោលវិធីអភិវឌ្ឍន៍បែបបញ្ជា (ឧ. គោលវិធីដែលយើងប្រាប់ដល់អ្នកពាក់ព័ន្ធអំពីអ្វីដែលត្រូវធ្វើដោយពុំបានប្រឹក្សាជាមួយពួកគេ)។ ស្របពេលជាមួយគ្នានេះ យើងត្រូវទទួលស្គាល់ឧបសគ្គនៃការអនុវត្តនៅក្នុងគម្រោងដែលជំរុញដោយអ្នកពាក់ព័ន្ធក្នុងបរិបទកម្ពុជា។ ការណ៍នេះ និយាយសំដៅដល់ការខ្វះបទពិសោធន៍ និងការប្រឈមរបស់សាលារៀន និង

សហគមន៍ជាមួយនឹងរបៀបធ្វើការងារបែបថ្មី។ ការប្រើបញ្ជីសកម្មភាពផ្តល់ឱកាសសម្រាប់ការផ្តល់សិទ្ធិអំណាចនៅក្នុងរចនាសម្ព័ន្ធមួយដែលទទួលស្គាល់ឧបសគ្គក្នុងមូលដ្ឋានទាំងនេះ។ វាផ្តល់នូវ**ផ្លូវកណ្តាល**មួយ រវាងបញ្ហាពីរគឺ "ចៀសវាងការបញ្ហា" និង "ទទួលស្គាល់ថាអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានតែងតែខ្វះបទពិសោធន៍ និងការប្រឈមនឹងគំនិតថ្មីៗ"។

**លំហាត់៖** ចូរក្រឡេកមើលដ្យាក្រាមទទេខាងក្រោមនេះ និងបញ្ជីបញ្ញត្តិគន្លឹះដែលផ្តល់ជូននៅក្នុងតារាងនៅផ្នែកខាងក្រោមនៃទំព័រនេះ។ ចូរពិភាក្សាក្នុងក្រុមរបស់អ្នកអំពីទីតាំងដែលបញ្ញត្តិនីមួយៗអាចស្ថិតនៅក្នុងដ្យាក្រាមដែលផ្តល់ជូននេះ។ ផ្នែកខ្លះនៃដ្យាក្រាមមានបំពេញរួចហើយ ដើម្បីជួយដល់ការប្រឹងប្រែងរបស់អ្នកក្នុងការបង្ហាញនូវទំនាក់ទំនងរវាងបញ្ញត្តិខុសគ្នានេះ។




| | | | |
|---|---|---|---|
| បញ្ជីសកម្មភាព | ការសម្រេចចិត្តក្នុងមូលដ្ឋាន | ជម្រើសដោយសេរី | ការអភិវឌ្ឍ |
| ការផ្តល់សិទ្ធិអំណាច | សេរីភាពនៅក្នុងរចនាសម្ព័ន្ធ | កម្មសិទ្ធិភាព | មាននិរន្តរភាព |

**ឯកសារទី ២៨ខ៖ ទំនាក់ទំនងរវាង SBM និងបញ្ជីសកម្មភាព**

ចូរពិនិត្យមើលដ្យាក្រាមដែលបានបំពេញរួចខាងក្រោមនេះ។ បន្ទាប់មក ពិភាក្សាគ្នាជាមួយសមាជិកក្នុងក្រុមរបស់អ្នក ថាតើវាខុសគ្នាយ៉ាងណាខ្លះពីដ្យាក្រាមរបស់អ្នក ដែលអ្នកបានធ្វើនៅក្នុងលំហាត់មុន នៅក្នុង**ឯកសារទី ២៨ក** និងមូលហេតុដែលនាំឱ្យមានការយល់ឃើញខុសគ្នានេះ។



# ឯកសារទី ២៩៖ រចនាសម្ព័ន្ធនៃបញ្ជីសកម្មភាព

## ឧទាហរណ៍អំពីបញ្ជីសកម្មភាព

នៅក្នុងបញ្ជីសកម្មភាពដែលបង្ហាញជូននៅក្នុងគំរូដែលបានផ្តល់ជូននេះ អ្នកសម្របសម្រួលត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាតារាងម៉ាទ្រិចមួយដែលមានប្រាំមួយកូឡោន។ ឧទាហរណ៍អំពីបញ្ជីនេះមានផ្តល់ជូននៅក្នុងការទស្សនាបញ្ជីដែលមានបង្ហាញខាងក្រោមនេះ។ ដើម្បីលើកកម្ពស់គោលនយោបាយសាលារៀនកុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា រាល់សកម្មភាពទាំងអស់ត្រូវបានរៀបចំក្នុងន័យសមាសភាគសាលារៀនកុមារមេត្រី (CFS) ដែលវាតំណាងឱ្យ។ សរុបមក មានសមាសភាគចំនួនប្រាំមួយគឺ៖

1. ការអប់រំជាបរិយាបន្ន (និងសមភាពយេនឌ័រ) — កូដពណ៌៖ ខៀវ
2. ការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព — កូដពណ៌៖ ត្នោត
3. សុខភាព សុវត្ថិភាព និងការការពារកុមារ — កូដពណ៌៖ បៃតង
4. សមភាពយេនឌ័រ (រួមគ្នាជាមួយនឹងសមាសភាគទី ១) — កូដពណ៌៖ --
5. ការចូលរួមរបស់កុមារ ឪពុកម្តាយ និងសហគមន៍ — កូដពណ៌៖ ទឹកសមុទ្រ
6. បរិយាកាសអំណោយផល៖ អភិបាលកិច្ចសាលារៀន — កូដពណ៌៖ ទឹកក្រូច

## ការផ្តល់នូវភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់បញ្ជីសកម្មភាព



គំរូបញ្ជីសកម្មភាពដែលមានផ្តល់ជូននេះ ត្រូវបានកំណត់នូវរចនាសម្ព័ន្ធដើម្បីឱ្យវាងាយស្រួលសម្រាប់បណ្តាអ្នកពាក់ព័ន្ធក្នុងសហគមន៍ដែលប្រើប្រាស់វានៅកម្រិតសាលារៀន។ ឧទាហរណ៍សកម្មភាពមានការរៀបចំជា **សមាសភាគសាលារៀនកុមារមេត្រី** ហើយពណ៌មានកូដ ដូចដែលបានកត់ចំណាំខាងលើ ដើម្បីងាយស្រួលរកមើល ។ សមាសភាគសាលារៀនកុមារមេត្រី គឺជាកូឡោនទីមួយដែលគេមើលឃើញនៅក្នុងតារាងម៉ាទ្រិចនៅឆ្វេងដៃគេបង្អស់។ សកម្មភាពក៏មានការរៀបចំទៅតាមបញ្ហាដែលវាជួយដោះស្រាយផងដែរ។ បញ្ហានីមួយៗ មានរាយបញ្ជីនៅក្នុងកូឡោនមួយហៅថា **ផ្នែកនៃបញ្ហា** របស់តារាងម៉ាទ្រិចបញ្ជីសកម្មភាព។ បន្ទាប់ពីអ្នកពាក់ព័ន្ធបានកំណត់រកបញ្ហារបស់ខ្លួនរួចហើយ ពួកគេអាចបើកសៀវភៅបញ្ជី ហើយព្យាយាមផ្គូរផ្គងបញ្ហារបស់ខ្លួនជាមួយនឹងសកម្មភាពសមស្របមួយដែលបានជ្រើសរើសយកមកដោះស្រាយបញ្ហានោះ។

*Cross-referencing Problems to Solutions: Plan… …ures as solutions to the problems they have identi…*



**ផ្នែកសកម្មភាពនៃបញ្ជី ជួយកសាងផែនការអភិវឌ្ឍន៍សាលារៀន៖** អ្នកពាក់ព័ន្ធអាចសម្រេចចិត្តក្នុងចំណោមពួកគេថាតើពួកគេចូលចិត្តសកម្មភាពនោះ ឬ តើវាពាក់ព័ន្ធនឹងបរិបទរបស់ពួកគេដែរឬទេ ដោយអាននូវ **ការបរិយាយសកម្មភាព** ដែលអមមកជាមួយនឹងសកម្មភាពនីមួយៗ។ នៅក្នុងការបរិយាយសកម្មភាព មានពាក្យមួយ ឬច្រើនដែលផ្ដល់ជូនជា*អក្សរទ្រេត* ដើម្បីសង្កត់ធ្ងន់ទៅលើសកម្មភាពទាំងឡាយដែលត្រូវតែធ្វើ ដើម្បីធ្វើឱ្យសកម្មភាពនេះកើតឡើងបាន។ ពាក្យជាអក្សរទ្រេតទាំងនេះ ជាធម្មតាគឺជាកិរិយាសព្ទដូចជា *ផ្ដល់, កសាង, បង្កើត, រៀបចំ ។ល។* ការប្រាស់ប្រើពាក្យសកម្មភាពទាំងនេះនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ជួយធ្វើឱ្យផែនការនោះផ្ដោតទៅលើ*សកម្មភាពជាក់ស្ដែង* និងចៀសវាងការប្រើប្រាស់នូវអ្វីមួយដែលយើងហៅថា ពាក្យផែនការ "ក្លែងក្លាយ"។ ពាក្យផែនការក្លែងក្លាយ រួមមានពាក្យទាំងឡាយដូចជា *ពង្រឹង, លើកទឹកចិត្ត, ផ្សព្វផ្សាយ ។ល។* តើអ្នកធ្លាប់បានឃើញពាក្យទាំងនេះនៅក្នុងផែនការ ហើយឆ្ងល់អំពីអ្វីដែលអ្នកនឹងត្រូវធ្វើដើម្បីឱ្យសកម្មភាពកើតឡើងបានដែរឬទេ? តើការ "ពង្រឹង" អ្វីមួយ មានន័យដូចម្ដេច? តើខ្ញុំ *បណ្ដុះបណ្ដាល* នរណាម្នាក់ តើខ្ញុំត្រូវ*បង្កើតប្រព័ន្ធមួយ* តើខ្ញុំត្រូវ*ជួប* ជាមួយនរណាម្នាក់? ជាការប្រសើរក្នុងការប្រើប្រាស់ពាក្យណាមួយដែលបរិយាយនូវ **សកម្មភាពជាក់ស្ដែង** ដែលអ្នកត្រូវតែធ្វើ ជាជាងការប្រើពាក្យផែនការ "ក្លែងក្លាយ" ដូចជាពាក្យ ពង្រឹង ឬ ផ្សព្វផ្សាយ។ ពាក្យសកម្មភាពជាអក្សរទ្រេតនៅក្នុងការបរិយាយសកម្មភាព ជួយដល់អ្នកក្នុងការធ្វើសកម្មភាពនោះ។

**ការប្រើប្រាស់រូបភាពនៅក្នុងបញ្ជី៖** ដោយសារតែការបរិយាយសកម្មភាពខ្លីពេក ក៏មានការផ្ដល់ជូននូវរូបភាពជាមួយនឹងសកម្មភាពនីមួយៗផងដែរ ដើម្បីជួយឱ្យអ្នកអានយល់បានកាន់តែប្រសើរអំពីសកម្មភាពនោះ។ រូបភាពមាននៅក្នុងកូឡោន **រូបភាព** នៅខាងស្ដាំដៃគេបង្អស់នៃតារាងម៉ាទ្រិច។ រូបភាពទាំងនេះ អាចមានប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធទាំងនោះ ដែលបំណិនអាន និងសរសេររបស់ពួកគេនៅមានកម្រិត។

**លេខយោងប្រើសម្រាប់សកម្មភាព៖** សកម្មភាពនៅក្នុងបញ្ជីនីមួយៗសុទ្ធតែមាន**លេខយោង**មួយ ដើម្បីងាយស្រួលរកវា។ ប្រសិនបើសមាជិកក្រុមធ្វើផែនការរបស់អ្នកស្នើសុំឱ្យអ្នករកមើលសកម្មភាពជាក់លាក់ណាមួយ ជាការល្អ ត្រូវស្វែងយល់ថាតើពួកគេអាចប្រាប់អ្នកអំពីលេខយោងសកម្មភាពនោះដែរឬទេ។ នៅពេលអ្នកស្គាល់លេខយោងសកម្មភាពហើយ អ្នកគ្រាន់តែបើកទៅកាន់ទំព័រនោះ នៅត្រង់កន្លែងដែលមានលេខយោងនោះ។ សរុបមកមានសកម្មភាពខុសៗគ្នាចំនួន xx ដែលមានរាយបញ្ជីនៅក្នុងម៉ឺនុយសកម្មភាព។

**ការកំណត់ធនធានដែលត្រូវការសម្រាប់សកម្មភាពមួយ៖** ជាចុងក្រោយ សកម្មភាពនីមួយៗនៅក្នុងបញ្ជី ក៏មានបញ្ជីខ្លីមួយនូវ**ធនធាន** ដែលអ្នកត្រូវការដើម្បីអនុវត្តសកម្មភាពនោះផងដែរ។ នៅក្នុងផែនការណាមួយក៏ដោយ គេត្រូវធ្វើផែនការថវិកាដែលរៀបរាប់អំពីធនធានទាំងឡាយដែលអ្នកត្រូវការដើម្បីអនុវត្តសកម្មភាពនោះ។ កូឡោនធនធាន ជួយឱ្យអ្នកកំណត់រកធនធានទាំងនេះបានយ៉ាងងាយស្រួល ដើម្បីឱ្យអ្នកអាចរាយឈ្មោះវានៅក្នុងផែនការថវិការបស់អ្នក។ ធនធានទាំងនេះអាចរួមបញ្ចូលនូវសម្ភារជាក់លាក់មួយចំនួន (ឧ. ឧបករណ៍កាត់សក់) សម្ភារការិយាល័យ សាច់ប្រាក់សម្រាប់គោលបំណងផ្សេងៗគ្នា (ឧ. សោហ៊ុយធ្វើដំណើរ) និងធនធានមនុស្សផងដែរ។ ដើម្បីវាស់បរិមាណចំណាយជារូបិយវត្ថុនៃធនធាននីមួយៗ មានតារាងម៉ាទ្រិចផ្នែកចំណាយជាឯកតាមួយ ដែលមានផ្ដល់ជូននៅផ្នែកខាងចុងនៃបញ្ជីគំរូ ដើម្បីជួយដល់អ្នកជាមួយនឹងដំណើរការនេះផងដែរ។

**សូមមើលទស្សនកិច្ចបញ្ជីដែលមានផ្ដល់ជូនខាងក្រោមនេះ ដើម្បីផ្ដល់គំនិតដល់អ្នកកាន់តែប្រសើរអំពីរបៀបដែលសកម្មភាពមួយត្រូវបានរៀបចំ។**

# <u>បញ្ជីសកម្មភាព</u>

## គំរូបញ្ជីសកម្មភាព ( សមាសភាគ៖ សុខភាព និងអាហារូបត្ថម្ភ )

***<u>ផ្នែកនៃបញ្ហា៖</u>***
*ប្រាប់អ្នកអំពីបញ្ហា ដែលសកម្មភាពនឹងជួយដោះស្រាយ។*

***<u>ការបរិយាយសកម្មភាព៖</u>***
*ប្រាប់អ្នកដោយសង្ខេបថាតើសកម្មភាពនោះនិយាយអំពីអ្វី។ កិរិយាស័ព្ទគន្លឹះសរសេរជាអក្សរទ្រេត ដើម្បីបង្ហាញថាតើត្រូវចាត់វិធានការអ្វីខ្លះ ដើម្បីអនុវត្តសកម្មភាព។*

| សមាសភាគ សាលារៀនកុមារមេត្រី | ល.រ | ផ្នែកនៃបញ្ហា | ការបរិយាយសកម្មភាព | ធនធាន | រូបភាព |
|---|---|---|---|---|---|
| សមាសភាគទី ៣៖ សុខភាព និងអាហារូបត្ថម្ភ | 23 | សាលារៀនពុំឆ្លើយតបនឹងតម្រូវការសុខភាពរបស់កុមារ | **ប្រអប់សង្គ្រោះបឋម៖** សាលារៀន *ផ្តល់* ប្រអប់សង្គ្រោះបឋមដល់កុមារ ដើម្បីឆ្លើយតបនឹងបញ្ហាសុខភាពពិសេស ដែលកើតឡើងនៅសាលារៀន។ | ◦ សម្ភារសម្រាប់ការសង្គ្រោះបឋម |  |
| | 24 | កុមារស្រេកឃ្លាន និងខ្វះអាហារូបត្ថម្ភ | **កម្មវិធីអាហារពេលព្រឹកនៅសាលារៀន៖** ដោយមានការយល់ព្រមពីកម្មវិធីស្បៀងអាហារពិភពលោក គណៈកម្មការសហគមន៍មូលដ្ឋាន *រៀបចំ* និង *ផ្តល់* អាហារពេលព្រឹកដល់កុមារទាំងអស់នៅសាលារៀនជនបទ។ | ◦ សម្ភារចម្អិន<br>◦ ចង្ក្រាន<br>◦ អង្ករ/ត្រីមកពីកម្មវិធីស្បៀងអាហារពិភពលោក |  |
| | 25 | សាលារៀនពុំឆ្លើយតបតាមតម្រូវការសុខភាពរបស់កុមារ | **បង្គន់អនាម័យ និងទឹកស្អាតក្នុងសាលារៀន៖** សាលារៀន *សង់* អណ្តូង និង បង្គន់ ដើម្បីពង្រឹងទម្លាប់អនាម័យ។ | ○ ចំណាយពលកម្ម<br>○ សម្ភារសំណង់ |   |

***<u>កូឡោនសមាសភាគ៖</u>***
*ប្រាប់អ្នកអំពីសមាសភាគនៃសកម្មភាព ស្របតាមក្របខ័ណ្ឌគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ*

***<u>លេខយោងសកម្មភាព៖</u>***
*ជួយដល់អ្នកក្នុងការស្វែងរកសកម្មភាពមួយនៅក្នុងបញ្ជីបានយ៉ាងងាយស្រួលនៅពេលអ្នកពិភាក្សាជាមួយសហការីដទៃទៀត*

***<u>ធនធាន៖</u>***
*ផ្តល់គំនិតដល់អ្នកអំពីការគ្រោងថវិកាសម្រាប់ធ្វើសកម្មភាព*

***<u>រូបភាព៖</u>***
*ផ្តល់គំនិតដ៏ឆាប់រហ័សដល់អ្នក តាមរយៈមធ្យោបាយឃើញផ្ទាល់ភ្នែកថាតើនិយាយអំពីអ្វីខ្លះ*

## ឯកសារទី ៣០៖ ការប្រើប្រាស់បញ្ជីសកម្មភាពដើម្បីកំណត់សកម្មភាព និងធនធានសម្រាប់ផែនការអភិវឌ្ឍន៍សាលារៀន

## លំហាត់ក្រុម

**ចំណាំ៖ ដើម្បីធ្វើលំហាត់ជាក្រុមខាងក្រោមនេះ អ្នកសម្របសម្រួលគួរចែកចាយគំរូបញ្ជីសកម្មភាព (ឧបសម្ព័ន្ធ ១) និងតារាងម៉ាទ្រិចចំណាយគិតជាឯកតានៃបញ្ជីសកម្មភាព (ឧបសម្ព័ន្ធ ២)។ ឯកសារទាំងនេះមាននៅក្នុងឧបសម្ព័ន្ធនៃសៀវភៅណែនាំនេះ។**

**លំហាត់ធ្វើជាក្រុមទី ១៖** ចូរអានសំណួរខាងក្រោម និងពិភាក្សារកចម្លើយក្នុងក្រុមតូចៗរបស់អ្នក ។ ចូរប្រើគំរូបញ្ជីសកម្មភាពដែលចែកចាយដោយអ្នកសម្របសម្រួល ដើម្បីរកចម្លើយរបស់អ្នក។

1. ដោយប្រើគំរូបញ្ជីសកម្មភាពដែលផ្តល់ជូនដោយអ្នកសម្របសម្រួល ចូរព្យាយាមស្វែងរកសកម្មភាពឱ្យបានច្រើនតាមដែលអាចធ្វើបាន ដែលបានរៀបចំឡើងដើម្បីដោះស្រាយរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹង "សិស្សបោះបង់ការសិក្សា"។ តើអ្នកអាចស្វែងរកសកម្មភាពបានប៉ុន្មាន? តើសកម្មភាពទាំងនេះផ្តល់គំនិតដល់អ្នកអំពីសកម្មភាពបន្ថែមដែលអ្នកអាចរកឃើញដោយខ្លួនឯងដែរឬទេ?
2. ចំពោះសកម្មភាពដែលអ្នកបានរកឃើញ ចូរក្រឡេកមើលទៅធនធានដែលត្រូវការ។ តើអ្នកយល់ថាសាលារៀនអ្នកនឹងត្រូវចំណាយអស់ប៉ុន្មាន ដើម្បីអនុវត្តសកម្មភាពទាំងនេះបាន?
3. តើអ្នកមានចំណូលចិត្តសម្រាប់សកម្មភាពទាំងឡាយដែលអ្នកបានរកឃើញនៅក្នុងបញ្ជីសកម្មភាពដែលដោះស្រាយបញ្ហាសិស្សបោះបង់ការសិក្សាដែរឬទេ? នេះមានន័យថា តើសកម្មភាពមួយណាដែលល្អបំផុតសម្រាប់សាលារៀនរបស់អ្នក។ ចូរពន្យល់អំពី "មូលហេតុ"។

**លំហាត់ធ្វើជាក្រុមទី ២៖** ចូរពិនិត្យមើលបញ្ហាទាំងឡាយដែលអ្នកបានរកឃើញសម្រាប់ផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក ដោយប្រើក្របខ័ណ្ឌតក្ក។ ចូរព្យាយាមផ្ទៀងផ្ទាត់បញ្ហាទាំងឡាយដែលអ្នកបានរកឃើញជាមួយនឹងបញ្ហាមួយចំនួនដែលមានរាយឈ្មោះនៅក្នុងបញ្ជីសកម្មភាព។ តើអ្នកមើលឃើញសកម្មភាពថ្មីៗ ដែលគួរឱ្យចាប់អារម្មណ៍នៅក្នុងបញ្ជីដែលអ្នកពុំបានគិតឃើញកាលពីមុនមកដែរឬទេ?តើអ្នកចង់បន្ថែមសកម្មភាពទាំងនេះចូលទៅក្នុងផែនការរបស់អ្នកដែរឬទេ?ចូរធ្វើបែបនេះ ប្រសិនបើក្រុមរបស់អ្នកយល់ស្របក្នុងការផ្លាស់ប្តូរ និងរាយការណ៍ការផ្លាស់ប្តូររបស់អ្នកទៅកាន់ក្រុមទាំងមូលវិញ។

**លំហាត់ធ្វើជាក្រុមទី ៣៖** ចូរពិនិត្យសកម្មភាពទាំងឡាយដែលអ្នកបានសម្រេចចិត្តដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក។ ចូរប្រើ*តារាងម៉ាទ្រិចចំណាយគិតជាឯកតានៃបញ្ជីសកម្មភាព* ដែលភ្ជាប់ជាមួយនឹងគំរូបញ្ជីសកម្មភាព ដើម្បីព្យាយាមកំណត់ថាតើវានឹងត្រូវចំណាយអស់ប៉ុន្មាន និងធនធានអ្វីផ្សេងទៀតដែលអ្នកត្រូវការដើម្បីអនុវត្តផែនការថ្មីមួយ។ តើតារាងម៉ាទ្រិច នេះមានប្រយោជន៍សម្រាប់ការគ្រោងថវិកាសម្រាប់សកម្មភាពថ្មីៗនៅក្នុងផែនការរបស់អ្នកដែរឬទេ? ហេតុអ្វីមានប្រយោជន៍ ឬ ហេតុអ្វីពុំមានប្រយោជន៍?

## ឯកសារទី ៣១៖ ការកំណត់និយមន័យនៃការគ្រប់គ្រងការផ្លាស់ប្តូរ

ការគ្រប់គ្រងការផ្លាស់ប្តូរនៅក្នុងវិស័យអប់រំអាចមានន័យថា៖ ការអនុវត្តសំណុំឧបករណ៍ ដំណើរការ ជំនាញ និងគោលការណ៍ទាំងឡាយសម្រាប់គ្រប់គ្រងផ្នែកផ្លាស់ប្តូររបស់មនុស្សដើម្បីសម្រេចលទ្ធផលដែលត្រូវការ។[12]

ការគ្រប់គ្រងការផ្លាស់ប្តូរ គឺជាដំណើរការ យុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយដែលគាំទ្រ ជំរុញ លើកទឹកចិត្ត និងធ្វើឱ្យមនុស្សមាននិរន្តរភាពនៅក្នុងអន្តរកាលពីស្ថានភាពបច្ចុប្បន្នទៅជាស្ថានភាពដែលចង់បាននាពេលអនាគត។ គោលបំណងនៃការផ្លាស់ទីពី "ទីនេះ" (ស្ថានភាពបច្ចុប្បន្ន) ទៅកាន់ "ទីនោះ" (ស្ថានភាពដែលចង់បាននាពេលអនាគត) គឺដើម្បីសម្រេចគោលដៅ/ចក្ខុវិស័យដែលបានដាក់ចេញដោយ [សាលារៀន / ក្រសួងអប់រំ]។ ដំណើរផ្លាស់ទីពី "ទីនេះ" ទៅកាន់ "ទីនោះ" ហៅថា "អន្តរកាល"។




| សំណួរគន្លឹះ ៖ | ចម្លើយខ្ញុំ ៖ |
|---|---|
| 1. **ហេតុអ្វី** បានជាយើងចង់ផ្លាស់ប្តូរ? (តើអ្វីជាគោលដៅ ឬចក្ខុវិស័យនៃការផ្លាស់ប្តូរនេះ?) | |
| 2. តើយើងចង់ឱ្យមានការផ្លាស់ប្តូរ**អ្វី**? (តើយើងត្រូវការផ្លាស់ប្តូរដំណើរការរៀបចំទេ? តើយើងត្រូវការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ ការអនុវត្តរបស់បុគ្គលដែរឬទេ។ល។?) | |
| 3. តើយើងនឹងធ្វើការផ្លាស់ប្តូរ**ដោយរបៀបណា**? (តាមមធ្យោបាយ ឬដំណើរការ ឬសកម្មភាពណាខ្លះដែលយើងអាចសម្រេចកិច្ចការ ដែលជួយឱ្យយើងឈានដល់គោលដៅរបស់យើងបាន? ហើយតើយើងត្រូវការធ្វើសកម្មភាពផ្សេងៗតាមលំដាប់លំដោយណាខ្លះ?) | |
| 4. តើ **នរណាខ្លះ** នឹងចូលរួមនៅក្នុងការផ្តួចផ្តើមគំនិត ការរៀបចំ និងការសម្រេចឱ្យបាននូវការផ្លាស់ប្តូរ និងវាយតម្លៃប្រសិទ្ធភាពរបស់វា? | |

[12] ដកស្រង់ពី Prosci Organisation, អាចរកបានតាមរយៈ: https://www.prosci.com/

## ឯកសារទី ៣២៖ ដំណើរការភ្ជាប់ការគ្រប់គ្រងការផ្លាស់ប្តូរ និងការគ្រប់គ្រងតាមសាលារៀន

គោលដៅមួយក្នុងចំណោមគោលដៅគ្រប់គ្រងតាមសាលារៀនគឺ ប្រឈមនឹងស្ថានភាពបច្ចុប្បន្ន (Status Quo)។ ស្ថានភាពបច្ចុប្បន្នបង្ហាញឱ្យឃើញពីបរិយាកាសបង្រៀន និងរៀនបែបថេរ។ ការគ្រប់គ្រងតាមសាលារៀនស្វែងរកការផ្លាស់ទីសាលារៀនពីបរិយាកាសបង្រៀន និងរៀនបែប "ថេរ" ទៅជា "ឌីណាមិច"។ នៅពេលមានឌីណាមិចនៅក្នុងសាលារៀន ការផ្លាស់ប្តូរជាវិជ្ជមានកើតឡើងកាន់តែងាយស្រួល។ តាមរយៈការបំបាត់ចោលឱ្យអស់នូវការគ្រប់គ្រងពីថ្នាក់កណ្តាល ដែលនៅរក្សាស្ថានភាពបច្ចុប្បន្ន ការគ្រប់គ្រងតាមសាលារៀនចង់លើកកម្ពស់បរិយាកាសបង្រៀន និងរៀនបែបឌីណាមិច ដែលជំរុញការផ្លាស់ប្តូរជាវិជ្ជមាន។




ប្រសិនបើផែនការផ្លាស់ប្តូរប្រព័ន្ធអប់រំ ឬផែនការអភិវឌ្ឍន៍សាលារៀនមួយមានឱកាសទទួលបានជោគជ័យនោះ ជាការចាំបាច់ណាស់ដែលត្រូវពិភាក្សា ស្វែងយល់ និងអប់រំបម្រែបម្រួលផ្លូវចិត្ត និងអាកប្បកិរិយារបស់មនុស្សពេញវ័យ — ទាំងអស់នេះសុទ្ធតែបម្រើឱ្យទស្សនវិស័យផ្លាស់ប្តូរដែលមានរៀបរាប់នៅក្នុងផែនការរបស់យើង។

ដូចដែលបានបរិយាយនៅក្នុងឯកសារជាសាកល បម្រែបម្រួលផ្លូវចិត្តដែលត្រូវការដើម្បីជួយឱ្យសាលារៀនមួយផ្លាស់ទីឆ្ពោះទៅរកការផ្តល់ការអប់រំសតវត្សរ៍ទី ២១ ប្រកបដោយគុណភាពខ្ពស់ រួមមាន៖

| ពី | ទៅជា |
|---|---|
| ចៀសវាងការហ៊ានប្រថុយ | ចាប់យកការហ៊ានប្រថុយ |
| ដាក់ការគ្រប់គ្រង | ផ្តល់ស្វ័យភាព |
| ពីថ្នាក់លើចុះក្រោម | សហការដើម្បីទទួលបានគំនិតមកពីប្រភពផ្សេងៗគ្នា |
| ចំណេះដឹងបែបថេរ | រៀនអ្វីៗដែលថ្មី |
| ដឹងចម្លើយទាំងអស់ | សួរសំណួរ |
| ស្ថិតក្នុងផ្នែកតែមួយ | ធ្វើការច្រើនផ្នែក |
| ផ្តល់តម្លៃ និងអាទិភាពតែលើអ្វីដែលយើងអាចវាយតម្លៃបាន (ឧ. ការធ្វើតេស្ត) | ផ្តល់អាទិភាពលើអ្វីដែលយើងផ្តល់តម្លៃ និងស្វែងរកវិធីវាយតម្លៃវា |
| "នៅស្ងៀម" | រុញគ្រឡប់មកវិញ នៅពេលណាចាំបាច់ដើម្បីបម្រើដល់ចក្ខុវិស័យ |

## ឯកសារទី ៣៣ក៖ ការឆ្លុះបញ្ចាំងខ្លួនឯងអំពីរបៀបដឹកនាំ

សេចក្តីសម្រេចរបស់ក្រសួងអប់រំ ដើម្បីលើកកម្ពស់ការគ្រប់គ្រងតាមសាលារៀន គឺផ្អែកទៅលើការសន្និដ្ឋានដែលថា អ្នកដឹកនាំសាលារៀន និងអ្នកដឹកនាំសហគមន៍នឹងប្រើស្វ័យភាពថ្មី ដែលពួកគេបានទទួលក្នុងការសម្រេចចិត្តឱ្យបានមុតមាំ និងលើកកម្ពស់ការផ្លាស់ប្តូរ។ ប៉ុន្តែការសន្និដ្ឋាននេះ អាចនឹងមិនត្រឹមត្រូវចំពោះគ្រប់សាលារៀនឡើយ ពីព្រោះមិនមែនគ្រប់សាលារៀនទាំងអស់សុទ្ធតែមានថ្នាក់ដឹកនាំរឹងមាំឡើយ។

**សេចក្តីណែនាំ៖** ចូរអានសំណួរនីមួយៗខាងក្រោមនេះ និងឆ្លើយដោយស្មោះត្រង់ថាតើអ្នកមានអារម្មណ៍បែបណាអំពីអ្វីដែលកំពុងសួរ។ ដាក់សញ្ញា (✓) នៅក្នុងប្រអប់ដែលបរិយាយល្អបំផុតអំពីអារម្មណ៍ផ្ទាល់ខ្លួន**របស់អ្នក**អំពីល្បះនីមួយៗ។ នៅពេលអ្នកឆ្លើយរួចរាល់ហើយ ចូររាប់ចំនួនសញ្ញាធីក ដែលស្ថិតក្រោមពិន្ទុនីមួយៗ រួចហើយគុណវាជាមួយនឹងចំនួនដែលបានបញ្ជាក់ប្រាប់។ បន្ទាប់មក បូកសរុបពិន្ទុរបស់អ្នកសម្រាប់កូឡោនទាំងអស់ដើម្បីរកពិន្ទុសរុបរបស់អ្នក។

| | | មិនពិតសោះ | មិនពិត | ពិតខ្លះ | ពិត | ពិតណាស់ |
|---|---|---|---|---|---|---|
| 1. | ខ្ញុំយល់ថាការហ៊ានប្រថុយជារឿងអាក្រក់ដែលត្រូវចៀសវាង។ | | | | | |
| 2. | នៅពេលត្រូវធ្វើអ្វីមួយ ខ្ញុំយល់ថាជាការល្អបំផុតដែលត្រូវធ្វើវាដោយខ្លួនឯង ដើម្បីឱ្យវារួចរាល់បានត្រឹមត្រូវ។ | | | | | |
| 3. | ខ្ញុំចង់រក្សាទុកស្ថានភាពបច្ចុប្បន្ននៅសាលារៀនខ្ញុំ ជាជាងទទួលយកគំនិតថ្មីៗច្រើនពេក ដែលអាចធ្វើឱ្យអ្នកដទៃទៀតមានការធុញទ្រាន់។ | | | | | |
| 4. | ខ្ញុំធ្វើតាមគំនិតរបស់ខ្ញុំផ្ទាល់ ពីព្រោះជាទូទៅខ្ញុំដឹងអ្វីដែលល្អបំផុតសម្រាប់សាលារៀនខ្ញុំ។ | | | | | |
| 5. | ឥឡូវនេះ ខ្ញុំដឹងស្ទើរតែទាំងអស់ថា មានអ្វីមួយដែលត្រូវដឹងអំពីការបង្កើតបរិយាកាសសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពនៅសាលារៀនខ្ញុំ។ | | | | | |
| 6. | ក្នុងនាមជាអ្នកដឹកនាំសាលារៀនខ្ញុំ ខ្ញុំត្រូវតែបង្ហាញឱ្យអ្នកដទៃបានដឹងថា ខ្ញុំយល់អ្វីៗគ្រប់បែបយ៉ាង។ | | | | | |
| 7. | អ្វីដែលសំខាន់បំផុតអំពីការធ្វើជាអ្នកដឹកនាំគឺ ត្រូវមានអ្នកដទៃចូលចិត្តច្រើន។ | | | | | |
| 8. | នៅពេលអនុវត្តគម្រោងមួយ ឬសម្រេចចិត្តមួយ ជាការល្អបំផុត ដែលត្រូវធ្វើការដោយពុំមានមនុស្សច្រើនចូលរួម។ | | | | | |
| 9. | ពិន្ទុតេស្តសិស្សនៅលើតេស្តរបស់រដ្ឋ គួរតែជាអាទិភាព នៅពេលគិតអំពីការអប់រំប្រកបដោយគុណភាព។ | | | | | |
| 10. | ជាការល្អបំផុតដែលត្រូវរក្សាឱ្យមានភាពសុខដុមមេនានៅក្នុងសាលារៀន ទោះបីជាពេលខ្លះអ្នកត្រូវសម្របទៅតាមចក្ខុវិស័យរបស់សាលារៀនក៏ដោយ។ | | | | | |
| | បូកចំនួននៃសញ្ញាធីកនៅក្នុងកូឡោននីមួយៗ | | | | | |
| | **គុណនឹង** | x5 | x4 | x3 | x2 | x1 |
| | **សរុប** | | | | | |

បូកសរុបជួរចុងក្រោយបង្អស់ដើម្បីទទួលបានពិន្ទុសរុបរួមរបស់អ្នក។ បន្ទាប់មក ដាក់សញ្ញា “x” នៅលើបន្ទាត់ខាងក្រោម ដើម្បីផ្តល់ជាសញ្ញាអំពីទីតាំងរបស់អ្នកនៅលើបន្ទាត់ក្រិតនេះ។

## បន្ទាត់កក្រិតនៃឥរិយាបថគាំទ្រដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM)




**ចំណាំ:** ពិន្ទុខ្ពស់ជាង ២៥ បង្ហាញនូវនិន្នាការដែលចេញពីមធ្យមទៅខ្លាំង ដើម្បីទទួលការផ្លាស់ប្តូរ។

បន្ទាប់ពីសិក្ខាកាមបានដាក់ពិន្ទុខ្លួនឯងរួចហើយ អ្នកសម្របសម្រួលគួរផ្តួចផ្តើមការសន្ទនាអំពីប្រភេទនៃការផ្លាស់ប្តូរផ្លូវចិត្ត និងអាកប្បកិរិយា ដែលចាំបាច់សម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាព។ សិក្ខាកាមមិនចាំបាច់ចែករំលែកពិន្ទុរបស់ខ្លួនជាមួយគ្នាទេ ប៉ុន្តែពិន្ទុនេះគឺសម្រាប់ឱ្យពួកគេឆ្លុះបញ្ចាំងខ្លួនឯងឱ្យបានស៊ីជម្រៅទៅលើប្រភេទនៃការផ្លាស់ប្តូរអ្វីខ្លះ ដែលចាំបាច់ផ្នែកផ្លូវចិត្ត អាកប្បកិរិយា ចំណេះដឹង ។ល។ ដើម្បីដឹកនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ដែល SBM អាចជំរុញនៅក្នុងសាលារៀនពួកគេ។

## ឯកសារទី ៣៣ខ៖ តួនាទីនៃភាពជាអ្នកដឹកនាំ នវានុវត្តន៍ និងឆន្ទៈនៅក្នុងការលើកកម្ពស់ការគ្រប់គ្រងតាមសាលារៀន

មានការកត់សម្គាល់ពីខាងដើមមកថា ការគ្រប់គ្រងតាមសាលារៀនផ្អែកលើការសន្មតដែលថាសាលារៀននឹងប្រើប្រាស់ឱកាសស្វ័យភាពកាន់តែច្រើន ក្នុងការលើកកម្ពស់ការផ្លាស់ប្ដូរ។ ប៉ុន្តែដើម្បីឱ្យកិច្ចការនេះកើតឡើងបាន ជាទូទៅយើងសង្ឃឹមថា នឹងមានកិច្ចការចំនួនបីនៅនឹងកន្លែង ក្នុងចំណោមអ្នកដឹកនាំភាគច្រើននៅកម្រិតសាលារៀន។ កិច្ចការទាំងនេះរួមមានដូចតទៅ៖

| ការដឹកនាំ និងការគ្រប់គ្រង | នវានុវត្តន៍អប់រំ | ឆន្ទៈ |
|---|---|---|
| ↓ | ↓ | ↓ |
| "**អ្នកដឹកនាំអស្ចារ្យ**មានចក្ខុវិស័យច្បាស់លាស់ មានភាពក្លាហាន មានសុចរិតភាព ភាពស្មោះត្រង់ សុភាពរាបសារ និងការផ្ដោតអារម្មណ៍ច្បាស់លាស់ ។ ... អ្នកដឹកនាំអស្ចារ្យ ជួយឱ្យមនុស្សឈានដល់គោលដៅរបស់ពួកគេ ដោយពុំខ្លាចការជួលមនុស្សដែលប្រសើរជាងខ្លួន និងមានមោទនភាពចំពោះការសម្រេចលទ្ធផលរបស់អ្នកទាំងនោះ ដែលខ្លួនបានជួយកន្លងមក។ | **នវានុវត្តន៍អប់រំ**ពិតប្រាកដ គឺជាផលិតផល ដំណើរការ យុទ្ធសាស្ត្រ និងគោលវិធីទាំងឡើយណាដែលកែលម្អបានយ៉ាងច្រើនចំពោះស្ថានភាពបច្ចុប្បន្ន និងឈានដល់កម្រិតមាត្រដ្ឋាន។ នៅពេលនវានុវត្តន៍មួយអាចប្រើប្រាស់ក្នុងបរិបទផ្សេងកាន់តែទូលំទូលាយ នវានុវត្តន៍នោះកាន់តែប្រសើរឡើង។ | **ឆន្ទៈ** គឺជាដំណើរការមួយដែលផ្ដួចផ្ដើម ដឹកនាំ និងរក្សាបាននូវអាកប្បកិរិយាតម្រង់ទៅរកគោលដៅ. ... វាគឺជាសន្ទះនៃចិត្តដែលចង់សម្រេចអ្វីៗប្រកបដោយគុណភាពកម្រិតខ្ពស់តាមដែលអាចធ្វើទៅបាន។ |

កំណែទម្រង់អប់រំនៅកម្ពុជាតែងតែបរាជ័យ ដោយសារតែលក្ខណៈមួយ ឬច្រើនក្នុងចំណោមលក្ខណៈទាំងនេះដែលពុំមាននៅតាមសាលារៀន។ ប៉ុន្តែលក្ខណៈនីមួយៗទាំងនេះ ពុំមែនជាលក្ខណៈខ្មៅ និងស នៃការគ្រប់គ្រងសាលារៀនឡើយ។ អ្នកដឹកនាំសាលារៀនមួយចំនួន មានលក្ខណៈទាំងនេះតាមកម្រិតខុសៗគ្នា។ ពេលខ្លះ ជាការល្អក្នុងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យខ្លីៗ ដើម្បីជួយឱ្យយើងយល់បានកាន់តែប្រសើរថាតើសាលារៀននឹងមានរូបរាងបែបណា ជាមួយនឹងកម្រិតខ្លាំង មធ្យម និងខ្សោយនៃលក្ខណៈនីមួយៗទាំងនេះ។ ក្របខ័ណ្ឌលក្ខណៈវិនិច្ឆ័យដែលអ្នកឃើញនៅទំព័របន្ទាប់ អាចជួយឱ្យអ្នកធ្វើស្វ័យវាយតម្លៃការគ្រប់គ្រងនៅតាមសាលារៀនរបស់អ្នកផ្ទាល់។ ចូរព្យាយាមអានក្របខ័ណ្ឌលក្ខណៈវិនិច្ឆ័យខាងក្រោមនេះ ដើម្បីកំណត់ថាតើសាលារៀនអ្នកស្ថិតនៅត្រង់ចំណុចណា។

សម្រាប់ជាកិច្ចការតាមដាន អ្នកក៏អាចផ្ដល់ក្របខ័ណ្ឌនេះដល់សហការីនៅសាលារៀនរបស់អ្នកផងដែរ ដើម្បីទទួលបានយោបល់ស្មោះត្រង់របស់ពួកគេអំពីការដឹកនាំ នវានុវត្តន៍ និងឆន្ទៈនៅសាលារៀនរបស់អ្នក។ ប្រសិនបើអ្នកពិតជាបានចែករំលែកក្របខ័ណ្ឌនេះជាមួយអ្នកដទៃ ចូរស្នើសុំឱ្យសហការីបំពេញវាជាលក្ខណៈ "អនាមិក" ដើម្បីកុំឱ្យពួកគេផ្ដល់ចម្លើយដែលយល់ស្របតាមអ្នក (ពោលគឺ ក្រែងចិត្ត)។

### ស្វ័យវាយតម្លៃ៖

ខ្ញុំវាយតម្លៃការដឹកនាំ និងការគ្រប់គ្រងនៅសាលារៀនខ្ញុំថា៖ ________________

ខ្ញុំវាយតម្លៃនវានុវត្តន៍នៅសាលារៀនខ្ញុំថា៖ ________________

ខ្ញុំវាយតម្លៃឆន្ទៈនៅសាលារៀនខ្ញុំថា៖ _______________

# លក្ខណៈវិនិច្ឆ័យវាយតម្លៃសម្រាប់ការដឹកនាំ នវានុវត្តន៍ និងឆន្ទៈ[13]

| មាត្រដ្ឋាន | ការដឹកនាំ និងការគ្រប់គ្រង | នវានុវត្តន៍ | ឆន្ទៈ |
|---|---|---|---|
| ០-២: ខ្សោយណាស់ | ភាគច្រើននៃអ្នកគ្រប់គ្រង មានចក្ខុវិស័យតិចតួចនៅសាលារៀន ហើយទុកការងារគ្រប់គ្រងសាលារៀនឱ្យអ្នកដទៃធ្វើ។ ភាគច្រើន សាលារៀនដំណើរការដោយស្វ័យប្រវត្តិ ហើយអ្នកគ្រប់គ្រងភាគច្រើន រួមទាំងនាយកសាលារៀនកម្រនឹងឃើញមុខនៅសាលារៀនណាស់។ | ពុំមានការប្រតិបត្តិថ្មីៗនៅសាលារៀនទេ ហើយអ្នកគ្រប់គ្រងសាលារៀន ចង់រក្សាស្ថានភាពបច្ចុប្បន្នឱ្យនៅដដែល ហើយរារាំងអ្នកដទៃដែលអាចនឹងមានគំនិតថ្មីៗ ឬចង់ធ្វើការផ្លាស់ប្តូរជាវិជ្ជមាននៅសាលារៀន។ | ភាគច្រើននៃអ្នកគ្រប់គ្រងបង្ហាញចំណាប់អារម្មណ៍តិចតួចនៅក្នុងការប្រើប្រាស់ស្វ័យភាពដែលទទួលបានពីថ្នាក់កណ្តាល។ អ្នកគ្រប់គ្រងភាគច្រើន (រួមទាំងនាយក) ខកខានការប្រជុំ ចេញពីប្រជុំមុនម៉ោង និង/ឬ ទុកការងារគ្រប់គ្រងសាលារៀនឱ្យអ្នកដទៃជាអ្នកធ្វើជំនួស។ |
| ៣-៤: ខ្សោយ | ការបំពេញកិច្ចការគ្រប់គ្រងជាមូលដ្ឋាន (ឧ. រៀបចំការប្រជុំ របាយការណ៍ហិរញ្ញវត្ថុ ស្ថិតិ ។ល។) ត្រូវបានធ្វើឡើងនៅកម្រិតមួយដែលគួរជាទីពេញចិត្តតិចតួច។ មានតម្លាភាពតិចតួចនៅក្នុងការគ្រប់គ្រង ការប្រាស្រ័យទាក់ទងខ្សោយ ពុំមានការសម្រេចចិត្តច្បាស់លាស់ ហើយរបៀបរបបដឹកនាំពុំជំរុញឱ្យមានទំនុកចិត្តពីអ្នកដទៃឡើយ។ | មានការផ្លាស់ប្តូរ និងគំនិតថ្មីៗមួយចំនួនដែលទាក់ទងនឹងការប្រតិបត្តិអប់រំនៅសាលារៀននោះ ប៉ុន្តែភាគច្រើនពុំមានការគ្រោងទុកជាមុនទេ មកពីថ្នាក់ក្រោម ហើយជាទូទៅ ពុំសូវមានការយកចិត្តទុកដាក់ពីអ្នកគ្រប់គ្រងនៅសាលារៀន។ | ភាគច្រើននៃអ្នកគ្រប់គ្រងបង្ហាញឱ្យឃើញនូវចំណាប់អារម្មណ៍ធម្មតានៅក្នុងការប្រើប្រាស់ស្វ័យភាពដែលទទួលបានមកពីថ្នាក់កណ្តាល ប៉ុន្តែល្មមត្រឹមតែបំពេញចិត្តថ្នាក់លើប៉ុណ្ណោះ។ អ្នកគ្រប់គ្រងពុំធ្វើកិច្ចការទាំងឡាយដែលគាំទ្រដល់កំណែបំប្លែងអប់រំទេ គឺធ្វើតិចតួចជាអប្បបរិមា ហើយភាគច្រើនតិចជាងកម្រិតអប្បបរមា។ |
| ៥-៧: មធ្យម | កិច្ចការគ្រប់គ្រងជាមូលដ្ឋានត្រូវបានបំពេញនៅកម្រិតមួយដែលជាទីពេញចិត្ត ហើយលើសពីស្តង់ដាអប្បបរិមា។ ទោះបីជាការដឹកនាំនៅសាលារៀននោះអាចនឹងមានអ្នកចូលចិត្ត ឬមានការចូលចិត្តច្រើនពីអ្នកក្រោមឱវាទក៏ដោយ ពុំមានស្មារតីឱណាមិចទេ (ឧ. ការហ៊ានប្រថុយនឹងហានិភ័យ) នៅក្នុងការដឹកនាំសាលារៀន។ | មានការផ្លាស់ប្តូរ និងគំនិតថ្មីៗមួយចំនួនដែលទាក់ទងនឹងការប្រតិបត្តិអប់រំដែលកើតឡើងនៅសាលារៀន ដែលកើតចេញពីអ្នកគ្រប់គ្រង និងអ្នកក្រោមឱវាទ។ ទោះជាយ៉ាងណា ជាទូទៅវាគឺជាការផ្លាស់ប្តូរដោយឯកឯង ដែលពុំមានការគ្រោងទុក ឬសម្របសម្រួលបានល្អឡើយ។ | កម្រិតឆន្ទៈនៃអ្នកដឹកនាំភាគច្រើនគឺគួរជាទីពេញចិត្ត។ ពួកគេបង្ហាញនូវចំណាប់អារម្មណ៍ និងការគាំទ្រកំណែបំប្លែងអប់រំបានសមរម្យ ប៉ុន្តែនៅតែមានឧបសគ្គនៅក្នុងការគាំទ្រនេះ ដែលប្រហែលមកពីពួកគេខ្វះសមត្ថភាព ឬពុំបានយល់អំពីកម្មវិធីនេះបានពេញលេញ។ |
| ៨-៩: ខ្លាំង | កិច្ចការគ្រប់គ្រងត្រូវបានបំពេញតាមរបៀបមួយដែលមានប្រសិទ្ធភាពបំផុត។ អ្នកគ្រប់គ្រងមានអ្នកចូលចិត្តច្រើន មានតម្លាភាពមានការសម្រេចចិត្តច្បាស់លាស់ និងជំរុញឱ្យមានទំនុកចិត្តពីអ្នកដទៃ។ អ្នកគ្រប់គ្រងបង្ហាញឱ្យឃើញនូវបំណិនការប្រាស្រ័យទាក់ទង និងចរចារល្អ ហើយអាចចេះបន្ទាបខ្លួននៅពេលត្រូវការ។ | មាននវានុវត្តន៍ជាប្រព័ន្ធនៅសាលារៀនដែលបានមកពីគ្រប់កម្រិតទាំងអស់។ នវានុវត្តន៍មានការគ្រោងទុក និងសម្របសម្រួលយ៉ាងល្អ ហើយដោះស្រាយប្រកបដោយមនសិកានូវបញ្ហាដែលបានរកឃើញដោយសាលារៀន អំឡុងពេលប្រជុំធ្វើផែនការ និងការពិភាក្សាផ្សេងៗតាមរចនាសម្ព័ន្ធ។ | កម្រិតឆន្ទៈរបស់អ្នកគ្រប់គ្រងភាគច្រើនគឺខ្លាំងបំផុត។ អ្នកគ្រប់គ្រងចំណាយពេលច្រើនជាងបរិមាណពេលវេលាដែលបានតម្រូវសម្រាប់ធ្វើការនៅសាលារៀនពួកគេខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជំរុញចិត្តអ្នកដទៃនៅសាលារៀន និងបង្ហាញឱ្យឃើញនូវស្មារតីកម្មសិទ្ធិភាពរឹងមាំលើសាលារៀនរបស់ពួកគេ។ |
| ១០: ល្អប្រសើរ | កិច្ចការគ្រប់គ្រងត្រូវបានបំពេញតាមរបៀបមួយដែលមានប្រសិទ្ធភាពល្អបំផុត។ អ្នកគ្រប់គ្រងបង្ហាញឱ្យឃើញនូវលក្ខណៈសម្បត្តិទាំងអស់នៃអ្នកដឹកនាំខ្លាំងពូកែ ដូចមានបរិយាយនៅខាងលើ ប៉ុន្តែបោះមួយជំហានទៅមុខទៀត ដោយបង្កើតការច្នៃប្រឌិតកម្រិតខ្ពស់នៅក្នុងការគ្រប់គ្រងសាលារៀនរបស់ខ្លួន។ | មាននវានុវត្តន៍ជាប្រព័ន្ធនៅសាលារៀនប្រកបដោយគុណភាពខ្ពស់បំផុត។ ក្នុងន័យបរិស្ថានសាលារៀនក្នុងមូលដ្ឋាន នវានុវត្តន៍មិនត្រឹមតែមានការគ្រោងទុក និងសម្របសម្រួលបានយ៉ាងល្អប៉ុណ្ណោះទេ នវានុវត្តន៍ទាំងនេះមានភាពទាក់ទងកម្រិតខ្ពស់សម្រាប់ចម្លើយតបទូទាំងខេត្ត និងទូទាំងប្រទេសផងដែរ។ | កម្រិតឆន្ទៈនៃអ្នកគ្រប់គ្រងភាគច្រើន ខ្លាំងជាទីបំផុត ដូចមានបរិយាយខាងលើនេះ ហើយអ្នកគ្រប់គ្រងខិតខំប្រឹងប្រែងធ្វើឱ្យសាលារៀនរបស់ខ្លួនមិនត្រឹមតែល្បីល្បាញ និងជាគំរូនៃការអប់រំដ៏ឆ្នើមនៅក្នុងតំបន់ពួកគេប៉ុណ្ណោះទេ ថែមទាំងនៅលើឆាកអន្តរជាតិផងដែរ។ |

[13] ដកស្រង់ចេញពី *ក្របខ័ណ្ឌវាយតម្លៃការគ្រប់គ្រងសាលារៀនជំនាន់ថ្មី* ។

## ឯកសារទី ៣៤៖ មូលហេតុដែលការផ្លាស់ប្តូរបរាជ័យ (ករណីសិក្សា)

**សេចក្តីណែនាំ៖** ក្រុមនីមួយៗយកសេណារីយ៉ូមួយខាងក្រោមនេះ ហើយប្រើប្រាស់ព័ត៌មាននៅក្នុងសេណារីយ៉ូដើម្បីបំពេញតារាងនៅទំព័របន្ទាប់។ សេណារីយ៉ូនីមួយៗព្យាយាមធ្វើឱ្យមានការផ្លាស់ប្តូរនៅសាលារៀន។ ការព្យាយាមទាំងអស់សុទ្ធតែបរាជ័យ ប៉ុន្តែមានមូលហេតុផ្សេងៗគ្នា។ ដោយប្រើអ្វីដែលបានរៀនអំពីមូលហេតុដែលការផ្លាស់ប្តូរបរាជ័យ ចូរវិភាគស្ថានភាព និងសរសេរមូលហេតុមួយ ឬច្រើន ដែលបរាជ័យនៅក្នុងកូឡោនកណ្តាល ។ បន្ទាប់មក នៅក្នុងកូឡោនចុងក្រោយ ចូរសរសេរអ្វីដែលអាចធ្វើខុសៗគ្នាដើម្បីជួយសម្រេចបាននូវការផ្លាស់ប្តូរដែលកំពុងស្វែងរក។ ចំណាំ៖ អ្នកប្រហែលជាមិនចាំបាច់បំពេញគ្រប់ប្រអប់សម្រាប់សេណារីយ៉ូនីមួយៗទេ។

**សេណារីយ៉ូទី ១៖** នៅសាលារៀនមួយ សិស្សជាច្រើនរៀនសូត្រពុំបានល្អ។ នាយកសាលារៀនដែលបានទទួលការបណ្តុះបណ្តាលផ្នែក SBM មានបំណងចង់រកដំណោះស្រាយមួយក្នុងមូលដ្ឋានដើម្បីកែលម្អពិន្ទុសិស្ស។ ផែនការអភិវឌ្ឍន៍សាលារៀនត្រូវបានបង្កើតឡើងជាមួយគ្រូបង្រៀន និងព្រះសង្ឃមកពីទីវត្តអារាមក្នុងមូលដ្ឋាន។ ពួកគេបានសម្រេចចិត្តថា សាលារៀនត្រូវការបង្គោលការពាររន្ទះថ្មីមួយដើមពីព្រោះប្រសិនបើបានដំឡើងវា សិស្សនឹងមិនភ័យខ្លាចខ្យល់ព្យុះ ហើយអាចផ្តោតអារម្មណ៍លើមេរៀនរបស់ពួកគេបានប្រសើរជាងមុន។ ក្រោយពីបានពិនិត្យរដ្ឋបាល គេរកឃើញថា ពិន្ទុរបស់សិស្សពុំមានការកែលម្អជាក់ស្តែងទេ។

**សេណារីយ៉ូទី ២៖** នៅសាលារៀនមួយ សិស្សភាគច្រើនប្រឡងថ្នាក់ជាតិមិនជាប់ទេ។ គ្រូមានគំនិតមួយចង់កែលម្អពិន្ទុសិស្ស។ ពួកគេមិនបានប្រាប់នាយកសាលារៀនទេ ពីព្រោះពួកគេដឹងថានាយកសាលារៀនរវល់ខ្លាំងណាស់។ គ្រូបានសម្រេចចិត្តបង្រៀនបំប៉នដោយផ្ទាល់ និងផ្តល់វគ្គសិក្សាចុងសប្តាហ៍នៅសាលារៀន។ ពួកគេជ្រើសរើសសិស្សដែលមានចំណាប់អារម្មណ៍ (ទាំងគ្រូ និងសិស្ស) ដោយការសន្ទនាមិនផ្លូវការ។ ដល់ពេលចាប់ផ្តើមកម្មវិធី សិស្សបង្ហាញខ្លួននៅសាលារៀន ប៉ុន្តែរកឃើញថា ថ្នាក់រៀនកំពុងត្រូវបានប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាល ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ទៅវិញ។ ដូចគ្នានេះដែរ នៅថ្ងៃដដែលនោះ ឪពុកម្តាយសិស្សបានទូរសព្ទទៅប៉ូលីស ដោយឆ្ងល់ថាកូនៗពួកគេទៅណាខ្លះ។

**សេណារីយ៉ូទី ៣៖** នៅសាលារៀនមួយ នាយកសាលារៀនជួបជាមួយសហគមន៍ដើម្បីនិយាយអំពីរបៀបកែលម្អបំណិនគិតដោយការវិភាគរបស់សិស្ស។ ពួកគេសម្រេចចិត្តបង្កើតនូវក្លឹបសិក្សាក្រៅម៉ោង។ នាយកសាលារៀនពុំបានជូនដំណឹងដល់គ្រូបង្រៀនអំពីសេចក្តីសម្រេចនេះទេ។ ដល់ពេលត្រូវមករៀបចំក្លឹប នាយកសាលារៀនប្រាប់គ្រូបង្រៀនអំពីផែនការ និងចាត់តាំងគ្រូឱ្យដំណើរការក្លឹបផ្សេងៗទាំងនោះ។ គ្រូបង្រៀនម្នាក់បានចង្អុលបង្ហាញថា វានឹងត្រូវចំណាយពេល ៦ ម៉ោង/សប្តាហ៍ ដើម្បីរៀបចំសម្រាប់ក្លឹប និង ២ ម៉ោង/សប្តាហ៍ដើម្បីដំណើរការក្លឹប។ គាត់ពុំមានពេលវេលាបន្ថែមច្រើនបែបនោះទេ។ គ្រូបង្រៀនម្នាក់ទៀតនិយាយថា ប្រាកដណាស់ក្លឹបរបស់គាត់នឹងត្រូវការលុយ ១០ ដុល្លារ/ជួបម្តង សម្រាប់ទិញសម្ភារផ្សេងៗ។ គាត់ពុំមានធនធានហិរញ្ញវត្ថុនោះទេ។ គ្រូបង្រៀនទីបីម្នាក់ទៀត និយាយថា គាត់ពុំមានទំនុកចិត្ត

ក្នុងការដំណើរការក្លឹបសហគ្រិនភាពទេ ពីព្រោះគាត់ពុំមានចំណេះដឹងគ្រប់គ្រាន់អំពីមុខវិជ្ជានោះ។ គ្រូបង្រៀនបានឯកភាពគ្នាថា ក្លឹបទាំងនេះពុំអាចអនុវត្តទៅរួចទេ។

**សេណារីយ៉ូទី ៤៖** អ្នកធ្វើផែនការនៅថ្នាក់កណ្តាលបានសម្រេចធ្វើការវិនិយោគទម្រង់ធំនៅក្នុងសាលារៀន ដើម្បីលើកកម្ពស់ការអប់រំ STEM។ ការណ៍នេះរាប់បញ្ចូលទាំងបន្ទប់វិទ្យាសាស្ត្រ និងបន្ទប់កុំព្យូទ័រផងដែរ។ អ្នកគ្រប់គ្រងសាលារៀន ស្វាគមន៍ការវិនិយោគនោះដោយមានវគ្គសិក្ខាសាលារៀនរយៈពេលមួយសប្តាហ៍ផងដែរ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនអំពីរបៀបប្រើប្រាស់បន្ទប់ពិសោធន៍។ បន្ទាប់ពីការវិនិយោគទាំងអស់បានបញ្ចប់សព្វគ្រប់ អ្នកធ្វើផែនការថ្នាក់កណ្តាលបានរកឃើញថា បន្ទប់ពិសោធន៍មានការប្រើប្រាស់តិចតួចបំផុត ។ គ្រូបង្រៀនពុំប្រើប្រាស់បន្ទប់ពិសោធន៍ដោយសារតែពួកគេផ្តល់អាទិភាពខ្ពស់ទៅលើថ្នាក់សិក្សាឯកជនរបស់ខ្លួន ហើយពុំមានពេលវេលាប្រើប្រាស់បន្ទប់ពិសោធន៍ទេ។ នាយកសាលារៀនបានព្យាយាមបង្ខំឱ្យគ្រូប្រើប្រាស់បន្ទប់ពិសោធន៍ ប៉ុន្តែវាបានត្រឹមតែធ្វើឱ្យគ្រូបង្រៀនខឹងសម្បារតែប៉ុណ្ណោះ ពីព្រោះពួកគេបានបាត់បង់នូវលុយជាច្រើន ដោយសារការកាត់បន្ថយពេលវេលាសម្រាប់ថ្នាក់សិក្សាឯកជនរបស់ពួកគេ។ លើសពីនេះ ភ្លាមៗក្រោយមកទៀត បន្ទប់ពិសោធន៍មានសភាពរញ៉េរញ៉ៃ និងកខ្វក់ ពីព្រោះពុំមានការចាត់តាំងឱ្យនរណាម្នាក់ថែទាំវាទេ។ ចុងក្រោយសិស្សបានរអ៊ូរទាំថាពួកគេពុំបានរៀនចេះអ្វីសោះពីបន្ទប់ពិសោធន៍ដោយសារតែការសិក្សាមានរយៈពេលខ្លីពេក មានការពិសោធន៍តិចតួចប៉ុណ្ណោះដែលអាចបញ្ចប់ជាស្ថាពរបាន។

**សេចក្តីណែនាំ៖** ចូរសរសេរលេខសេណារីយ៉ូដែលអ្នកបានអាន និងធ្វើការវិភាគអំពីមូលហេតុដែលការផ្លាស់ប្តូរនោះទំនងជាបរាជ័យ ដោយប្រើក្របខ័ណ្ឌដែលមានផ្តល់ជូនខាងក្រោមនេះ ៖

**សេណារីយ៉ូទី ៖** ______________

| មូលហេតុ/បញ្ហា | ប្រសិនបើមានបញ្ហាអ្វីមួយនៅក្នុងផ្នែកនេះ សូមពន្យល់។ | តើអាចធ្វើអ្វីផ្សេងពីនេះ ដើម្បីឱ្យការផ្លាស់ប្តូរជោគជ័យ? |
|---|---|---|
| ការវិភាគស្ថានភាពមានកម្រិតខ្សោយ។ | | |
| ការគាំទ្រពីគណៈគ្រប់គ្រងសាលារៀននៅមានកម្រិត | | |
| ខ្វះយុទ្ធសាស្រ្ត | | |
| ការស្វែងយល់អំពីវឌ្ឍនភាព (មាត្រដ្ឋាន និងវិសាលភាព) | | |
| អ្នកពាក់ព័ន្ធមិនយកចិត្តទុកដាក់ | | |
| ការប្រាស្រ័យទាក់ទងខ្សោយ | | |

| មូលហេតុ/បញ្ហា | ប្រសិនបើមានបញ្ហាអ្វីមួយនៅក្នុងផ្នែកនេះ សូមពន្យល់។ | តើអាចធ្វើអ្វីផ្សេងពីនេះ ដើម្បីឱ្យការផ្លាស់ប្តូរជោគជ័យ? |
|---|---|---|
| | | |
| ខ្វះចក្ខុវិស័យ | | |
| ខ្វះការត្រៀមរៀបចំ | | |

## ឯកសារទី ៣៥៖ គំរូការគ្រប់គ្រងការផ្លាស់ប្តូរ

យើងគិតថា **ការគ្រប់គ្រងការផ្លាស់ប្តូរ** ជាដំណើរការមួយដែលមាន ៣ ដំណាក់កាល។

**ទីមួយ** យើងត្រូវ**ត្រៀម**សម្រាប់ការផ្លាស់ប្តូរ។ ការណ៍នេះមានន័យថា ការកំណត់នូវ "អ្វី" ដែលត្រូវផ្លាស់ប្តូរ និងការបង្កើតការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រការផ្លាស់ប្តូរនោះ។ ប្រសិនបើអ្នកពាក់ព័ន្ធ មិនគាំទ្រការផ្លាស់ប្តូរដែលបានស្នើទេនោះ វាទំនងជាពុំអាចកើតឡើងបានឡើយ។ ដូច្នេះយើងត្រូវតែបញ្ចុះបញ្ចូលឱ្យមានមនុស្សគាំទ្រ និងចូលរួមនៅក្នុងការផ្លាស់ប្តូរ។

**ទីពីរ** យើងត្រូវតែ**គ្រប់គ្រង**ការផ្លាស់ប្តូរ។ ការនេះមានន័យថា ការប្រាស្រ័យទាក់ទងញឹកញាប់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដែលរងផលជះពីការផ្លាស់ប្តូរដែលបានស្នើឡើង ដោយផ្តល់អំណាចឱ្យអ្នកពាក់ព័ន្ធធ្វើការផ្លាស់ប្តូរតាមការគ្រោងទុក និងដោះស្រាយបញ្ហានៅពេលណាមានឧបសគ្គកើតឡើង។

**ទីបី** យើងត្រូវតែ**ពង្រឹង**ការផ្លាស់ប្តូរ។ នៅពេលការផ្លាស់ប្តូរចាប់ផ្តើមកើតឡើង ប្រហែលជាវានៅពុំទាន់បានបង្កើតឡើងពេញលេញនៅឡើយទេ។ យើងត្រូវធ្វើឱ្យប្រាកដថា អ្នកដែលរក្សានូវការប្រតិបត្តិតាមការផ្លាស់ប្តូរ ត្រូវទទួលបានរង្វាន់ចំពោះការធ្វើបែបនោះ (ពុំមែនរិះគន់ទេ)។ យើងក៏ត្រូវជានាផងដែរថា ការប្រតិបត្តិថ្មីៗនឹងក្លាយទៅជាទម្លាប់ជាប្រចាំនៅក្នុងសាលារៀន និងជាផ្នែកមួយនៃវប្បធម៌សាលារៀនផងដែរ។

**ដ្យាក្រាមខាងក្រោមនេះ សង្ខេបអំពីដំណើរការគ្រប់គ្រងការផ្លាស់ប្តូរ៖**



## ឯកសារទី ៣៦៖ ក្របខ័ណ្ឌដើម្បីត្រៀមសម្រាប់ការផ្លាស់ប្តូរ

តារាងខាងក្រោមនេះ ផ្តល់នូវក្របខ័ណ្ឌអនុវត្តមួយសម្រាប់អាជ្ញាធរសាលារៀនដែលចូលរួមនៅក្នុងការគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីឆ្លុះបញ្ចាំងអំពីរបៀបដែលពួកគេអាចចាត់វិធានការអនុវត្តដើម្បីគ្រប់គ្រងការផ្លាស់ប្តូរក្នុងសាលារៀនរបស់ខ្លួន។ បន្ទាប់ពីអ្នកបានធ្វើផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នកហើយ ចូរកំណត់រកការផ្លាស់ប្តូរសំខាន់ៗមួយចំនួនដែលបានគ្រោងទុក និងឆ្លើយសំណួរខាងក្រោម ដើម្បីធានាថាសាលារៀនរបស់អ្នកបានត្រៀមខ្លួនរួចរាល់ក្នុងការ '**គ្រប់គ្រង**' ការផ្លាស់ប្តូរជាក់ស្តែង។

| ការត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរនៅសាលារៀនរបស់អ្នក | |
|---|---|
| **សំណួរ** | **ការឆ្លើយតបពីសាលារៀនរបស់អ្នក** |
| 1) តើអ្នកចង់ធ្វើការផ្លាស់ប្តូរអ្វី?ចូររៀបរាប់យ៉ាងតិច **រឿងថ្មីប្លែកចំនួន ៣ នៅសាលារៀនរបស់អ្នក** ដែលបណ្តាលមកពីការសម្រេចបាននូវការផ្លាស់ប្តូរ។ | |
| 2) ចូររៀបរាប់យ៉ាងតិច **៣ មូលហេតុគន្លឹះ** សម្រាប់ការផ្លាស់ប្តូរ។ | |
| 3) ចូររៀបរាប់យ៉ាងតិច **៣ មូលហេតុ** ដែលត្រូវធ្វើការផ្លាស់ប្តូរ **ឥឡូវនេះ** (ឬនៅក្នុងខែក្រោយ)។ | |
| 4) ចូររៀបរាប់យ៉ាងតិច **ការហ៊ានប្រថុយចំនួន៣ ដែលត្រូវធ្វើ ប្រសិនបើមានការពន្យារពេល** ក្នុងការផ្លាស់ប្តូរ។ | |
| 5) ចូរៀបរាប់យ៉ាងតិចរឿង **៥ យ៉ាងដែលសាលារៀនត្រូវការដើម្បីអនុវត្ត** ការផ្លាស់ប្តូរ។ | |
| 6) ចូររៀបរាប់យ៉ាងតិចរឿង **៥ យ៉ាងដែលសាលារៀនត្រូវធ្វើដើម្បីរក្សានិរន្តភាព**ការផ្លាស់ប្តូរ។ | |
| 7) ចូររៀបរាប់យ៉ាងតិច **៥ ចំណុចគន្លឹះដែលសាលារៀនត្រូវតែប្រាស្រ័យទាក់ទង** និងជាមួយនរណាខ្លះ **មុនការផ្លាស់ប្តូរ**។ | |
| 8) ចូររៀបរាប់យ៉ាងតិច **៥ ចំណុចគន្លឹះដែលសាលារៀនត្រូវតែប្រាស្រ័យ** | |

| ការត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរនៅសាលារៀនរបស់អ្នក | |
|---|---|
| **សំណួរ** | **ការឆ្លើយតបពីសាលារៀនរបស់អ្នក** |
| **ទាក់ទង** និងជាមួយនរណាខ្លះ<br>**អំឡុងពេលផ្លាស់ប្តូរ។** | |
| 9) ចូររៀបរាប់យ៉ាងតិច **៥ ចំណុចគន្លឹះ ដែលសាលារៀនត្រូវតែប្រាស្រ័យ ទាក់ទង** និងជាមួយនរណាខ្លះ **ក្រោយការផ្លាស់ប្តូរ។** | |
| 10) ចូររៀបរាប់យ៉ាងតិច **៥ វេទិកាដែល ត្រូវធ្វើការប្រាស្រ័យទាក់ទង។** | |
| 11) សម្រាប់វេទិកាប្រាស្រ័យទាក់ទងនីមួយៗ ចូររៀបរាប់ដូចតទៅ៖<br>▪ **បុគ្គលដែលធ្វើការប្រាស្រ័យទាក់ទង**<br>▪ **បុគ្គលដែលទទួលការប្រាស្រ័យ ទាក់ទង**<br>▪ **ផលអវិជ្ជមានលើបុគ្គលដែលទទួល ការប្រាស្រ័យទាក់ទង**<br>▪ **របៀប ៣ យ៉ាងក្នុងការកាត់បន្ថយ ផលអវិជ្ជមាន** សម្រាប់បុគ្គលដែល ស្ថិតនៅក្នុងត្រែទី៣ ខាងលើ ឧ. បុគ្គលដែលអាចនឹងមានអារម្មណ៍ថា ខ្លួននឹងរងការប៉ះពាល់អវិជ្ជមាន ឧ. បន្ទុកការងារបន្ថែម ទំនួលខុសត្រូវ បន្ថែម។ | |
| 12) ចូររៀបរាប់យ៉ាងតិច **៣ វេទិកា**ដែល បុគ្គលិកអាច**ផ្តល់ព័ត៌មានត្រឡប់។** | |
| 13) ចូររៀបរាប់យ៉ាងតិច**មធ្យោបាយ ២ យ៉ាង** ដែលសាលារៀននឹង**តបទៅ កាន់បុគ្គលិក**ដែលបានផ្តល់ព័ត៌មាន ត្រឡប់វិញ។ | |
| 14) ចូររៀបរាប់យ៉ាងតិច**របៀប ៣ យ៉ាង** ដែល**សាលារៀនអាចកំណត់បានថា តើសាលារៀនបានប្រាស្រ័យទាក់ទង ការផ្លាស់ប្តូរដោយជោគជ័យដែរឬ ទេ។** | |

| ការត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរនៅសាលារៀនរបស់អ្នក | |
|---|---|
| **សំណួរ** | **ការឆ្លើយតបពីសាលារៀនរបស់អ្នក** |
| 15) ចូររៀបរាប់យ៉ាងតិច ៣ **កត្តាផ្ទៃក្នុង** ដែលសាលារៀនគួរពិចារណានៅពេលគិតអំពី**ពេលវេលាត្រូវផ្លាស់ប្តូរ។** | |
| 16) ចូររៀបរាប់យ៉ាងតិច ៣ **យុទ្ធសាស្រ្តដើម្បីដោះស្រាយហានិភ័យនៃកត្តាផ្ទៃក្នុងនីមួយៗ។** | |
| 17) ចូររៀបរាប់ ៣ **កត្តាផ្ទៃក្រៅ** ដែលសាលារៀនគួរពិចារណានៅពេលគិតអំពី**ពេលវេលាត្រូវផ្លាស់ប្តូរ។** | |
| 18) ចូររៀបរាប់យ៉ាងតិច ៣ **យុទ្ធសាស្រ្តដើម្បីដោះស្រាយហានិភ័យនៃកត្តាផ្ទៃក្រៅនីមួយៗ។** | |